ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ចក្ខុវិស័យនិងយុទ្ធសាស្ត្រ
ស្តីពី
សុខដុមនីយកម្មការកែទម្រង់ ៣ ក្នុង ១

២០២២

ភ្នំពេញ លើកទី១

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

ឆោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

បុព្វកថា

"**ការបង្កើតល្បឿននៃការកែទម្រង់អភិបាលកិច្ច**" ត្រូវបានកំណត់យកជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលប្រការនេះជាសក្ខីកម្មអំពីរបៀបវារៈគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមិនត្រឹមតែបន្តយកចិត្តទុកដាក់លើការងារកែទម្រង់ តែលើសពីនេះ គឺការបង្កើនអាទិភាពលើការងារកែទម្រង់ ជាងពេលណាៗទាំងអស់។

ទន្ទឹមនេះ អភិក្រម ៥ ប្រការ គឺ "**ទ្លុះកញ្ចក់ ខ្ចូតធ្មឹក ជុំសក្បែល ញ្ញាណ និងវ៉ះកាត់**" ដែលខ្ញុំបានដាក់ចេញកាលពីដើមអាណត្តិទី៥នៃរាជរដ្ឋាភិបាល នៅតែជាអភិក្រមកែទម្រង់ដ៏មុតស្រួចនិងត្រូវបន្តប្រកាន់យកសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ដើម្បីចូលរួមចំណែកដល់ការសម្រេចបានន្ទវគោលដៅនៃការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចនេះ។

ការកែទម្រង់បានក្លាយទៅជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក៏ប៉ុន្តែការកែទម្រង់មិនមែនទើបតែត្រូវបានចាប់ផ្តើមនោះឡើយ ផ្ទុយទៅវិញ យើងបានធ្វើការងារនេះអស់រយៈពេល ៤ ទសវត្សមកហើយ។ ហេតុនេះ ក្នុងនាមជាប្រមុខដឹកនាំរាជរដ្ឋាភិបាល ខ្ញុំតែងមានទស្សនៈមួយថា "**រដ្ឋាភិបាលរបស់ប្រជាជន ដោយសារប្រជាជន និងដើម្បីប្រជាជន**" ដ៏ពិតប្រាកដគឺជារដ្ឋាភិបាលដែលយល់ច្បាស់អំពីតុណតម្លៃនៃការកែទម្រង់និងមោះមុតក្នុងការងារនេះជាប់ជាប្រចាំទៅតាមតម្រូវការនៃគ្រប់កាលៈទេសៈ ដើម្បីធានាចីរភាពនៃរដ្ឋបាលសាធារណៈ ប្រសិទ្ធភាពនៃសេវាសាធារណៈ និងសុខុមាលភាពនិងជីវភាពកាន់តែប្រសើររបស់ប្រជាពលរដ្ឋ។

យើងបានចាប់ផ្តើមការងារកែទម្រង់តាំងពីក្នុងគ្រាដែលកម្ពុជាទើបរួចចាកផុតពីរបបប្រល័យពូជសាសន៍មកម្ល៉េះ ដែលពេលនោះអាទិភាពចាំបាច់ទីមួយរបស់យើងមិនមែនការអភិវឌ្ឍធនធានមនុស្ស ផ្លូវ ទឹក និងភ្លើងដូចសព្វថ្ងៃនេះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ អាទិភាពដែលយើងត្រូវដោះស្រាយជាចាំបាច់ គឺបញ្ចប់ការអត់ឃ្លាន ហើយគោលដៅសំខាន់បំផុតនៃការកែទម្រង់របស់យើងនាពេលនោះ គឺ *ការរកដំណោះស្រាយបញ្ចប់ភាពក្រីក្ររបស់ប្រជាជនយើង*។ ចំណុចនេះជាការបកស្រាយមួយទៅលើប្រវត្តិនៃទិសស្លោកគន្លឹះដែលខ្ញុំតែងតែលើកឡើងនិងរំលឹកជាប់ជាប្រចាំថា "**កែទម្រង់ រស់, មិនកែទម្រង់ ស្លាប់**"។ ក្នុងសម័យសន្តិភាព ថ្ងៃត្បិតអាទិភាពនៃការកែទម្រង់របស់យើងមានការផ្លាស់ប្តូរទៅតាមតម្រូវការសង្គមកំពុងអភិវឌ្ឍលូតលាស់ ទិសស្លោកមួយនេះនៅតែជាគំនិតដឹកនាំដ៏ត្រឹមត្រូវនិងប្រកបដោយសក្ខិភាពមិ ដែលថ្នាក់ដឹកនាំនិងមន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ត្រូវឈ្វេងយល់និងប្រកាន់ខ្ជាប់ ជាពិសេស ត្រូវចៀសវាងសេចក្ដីយល់ខុសថាការងារកែទម្រង់គឺជាបន្ទុកបន្ថែមលើការបំពេញមុខងារនិងភារកិច្ចប្រចាំថ្ងៃ។

ជាសត្យានុម័ត រដ្ឋាភិបាលនៃប្រទេសនីមួយៗ បានចាប់យកការកែទម្រង់លើវិស័យអាទិភាពរបស់ខ្លួនទៅតាមវិធីសាស្ត្រដោយឡែកៗពីគ្នា អាស្រ័យលើបរិបទសង្គម ប្រពៃណីស្ថាប័ន និងបែបបទរដ្ឋបាលរៀងៗខ្លួន។ ដោយឡែក សម្រាប់កម្ពុជា យើងបានរៀបចំការងារកែទម្រង់ជាកម្មវិធីរយៈពេលវែង ដោយមានការកំណត់ចក្ខុវិស័យវែងឆ្ងាយ មានការបែងចែកជាដំណាក់កាល

ប្រកបដោយតថភាពនិយមនិងគោលដៅជាក់លាក់ មានរចនាសម្ព័ន្ធដឹកនាំនិងយន្តការអនុវត្តច្បាស់លាស់។ វិធីសាស្ត្រកែទម្រង់នេះបានបង្ហាញអំពីសេចក្ដីក្លាហាន មហិច្ឆតា និងឆន្ទៈមោះមុតរបស់យើងលើការកែទម្រង់ ដោយអាចអនុវត្តទៅបានតាមបរិបទកម្ពុជានិងឆ្លើយតបបានទ្រវសេចក្ដីត្រូវការរបស់កម្ពុជា ប្រកបដោយមោទនភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកលើទស្សនៈវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាកម្មវិធីកែទម្រង់រយៈពេលវែងជាច្រើនលើគ្រប់វិស័យ ជាពិសេសការដាក់ចេញនូវកម្មវិធីកែទម្រង់ពាក់ព័ន្ធនឹងការបង្កើនគុណភាពអភិបាលកិច្ច ឬការកែទម្រង់លើរចនាសម្ព័ន្ធ ឬនិយាយម្យ៉ាងទៀតការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធដែលមានចំនួន ៤ សំខាន់ៗ គឺ **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**។ កម្មវិធីកែទម្រង់នីមួយៗខាងលើនេះ មានរចនាសម្ព័ន្ធដឹកនាំ យន្តការអនុវត្ត និងផែនការសកម្មភាពយ៉ាងលម្អិត រហូតទទួលបានការសាទរនិងការគាំទ្រពីដៃគូអភិវឌ្ឍន៍នានារួមមានទាំងការផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុជាបន្តបន្ទាប់ ក្នុងភាពជាដៃគូ កិច្ចសហប្រតិបត្តិការ និងការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា។

កម្មវិធីកែទម្រង់ទាំង ៤ នេះ បានវិវត្តរីកចំរើនទៅមុខ ដោយស្រង់បានទ្រឹសបទពិសោធន៍ជាមេរៀនល្អៗជាច្រើនជាមូលដ្ឋានគន្លឹះនៃការកែទម្រង់កម្មវិធីរបស់ខ្លួនសម្រាប់ដំណាក់កាលបន្តបន្ទាប់មកទៀត។ ក្នុងន័យនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានចាប់ផ្តើមអនុវត្តជាផ្លូវការនៅឆ្នាំ២០១០ តាមរយៈកម្មវិធីជាតិ ១០ ឆ្នាំ លើកទី១ (២០១០-២០១៩) របស់ខ្លួន មុននឹងបោះជំហានមកដល់កម្មវិធីជាតិ ១០ ឆ្នាំលើកទី២ (២០២១-២០៣០) ដែលទើបត្រូវបានចាប់ផ្តើមកាលពីពេលថ្មីៗនេះ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានចាប់ផ្តើមជាផ្លូវការនៅក្នុងឆ្នាំ២០០៤ និងត្រូវបានកំណត់ថាត្រូវអនុវត្តរហូតដល់ឆ្នាំ២០២៥ ដោយចែកជា ៤ ដំណាក់កាល ដែលបច្ចុប្បន្ន កម្មវិធីកែទម្រង់នេះកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល ៣ ឬក ២ មុននឹងទៅចាប់ផ្តើមជាផ្លូវការដំណាក់កាលទី៤ ជាដំណាក់កាលចុងក្រោយ ដែលផ្តោតលើការសម្រេចបានទ្រឹ "គណនេយ្យភាពសមិទ្ធកម្ម"។ ដោយឡែក កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដំណាក់កាលទី១ (២០១៥-២០១៨) ត្រូវបានបញ្ចប់រួចរាល់ និងកំពុងរៀបចំនូវកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥។ រីឯកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក៏កំពុងត្រូវបានរៀបចំជារចនាសម្ព័ន្ធដឹកនាំនិងយន្តការអនុវត្តឱ្យរស់រវើក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

បច្ចុប្បន្ន នៅក្នុងជំហានចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលមាន "**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**" ជាស្នូល រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគណៈកម្មាធិការកែទម្រង់ចំនួន ៤ របស់ខ្លួនបានបោះជំហានជាប្រវត្តិសាស្ត្រមួយកម្រិតទៀត នោះគឺការធានាសុខដុមនីយកម្មនៃការកែទម្រង់ទាំងនេះ ឱ្យមានសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ពាក់ព័ន្ធនឹងប្រសិទ្ធភាព ការកែទម្រង់អភិបាលកិច្ចរឹតតែមានសារៈសំខាន់ទ្វេដងដើម្បីពង្រឹងសមត្ថភាពនិងភាពរឹងមាំរបស់ស្ថាប័នសាធារណៈ ក្នុងការឆ្លើយតបបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហានានាជាច្រើនដែល

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

អាចកើតឡើងដោយមិនអាចស្មានទុកបាននិងមានលក្ខណៈកាន់តែស្មុគស្មាញ់ខ្លាំងឡើង ជាក់ស្តែង សកលលោកបាននិងកំពុងប្រឈមនឹងវិបត្តិជាច្រើន ដូចជា វិបត្តិជំងឺកូវីដ-១៩, វិបត្តិសង្គ្រាមអ្ស៊ីនៅអ៊ុយក្រែនដែលបង្ក្ការឱ្យមានវិបត្តិជាសកលផ្សេងៗទៀត និងការត្រៀមខ្លួនទប់ស្កាត់នូវជំងឺឆ្លងផ្សេងទៀតនាពេលអនាគត ព្រមទាំងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាក្នុងយុគសម័យបដិវត្តឧស្សាហកម្ម ៤.០។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ ឃ្លក ១** នេះ គឺជាសក្តានុពលនៃការបន្តគោលនយោបាយចាស់ គឺគោលនយោបាយកែទម្រង់ផង និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មី គឺយុទ្ធសាស្ត្រសុខដុមនីយកម្មនៃការកែទម្រង់ ដោយយកសមិទ្ធផលនិងបទពិសោធន៍កន្លងមកធ្វើជាមូលដ្ឋានឈានឆ្ពោះទៅសម្រេចបាននូវគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ ឃ្លក ១** ត្រូវបានរៀបចំឡើងដោយអនុលោមតាមអភិក្រមចំនួន ៤ គឺ ÷ **ទី១) អភិក្រមរក្សាកំហើញទាំងមូល** ដែលសំដៅប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងមិនអាចខ្វះបាន, **ទី២) អភិក្រមចូលរួមចំណែកតាមតួនាទី** សំដៅដល់កម្មវិធីកែទម្រង់នីមួយៗបំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទីនិងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន, **ទី៣) អភិក្រមរក្សាភាពជាម្ចាស់និងគាំទ្រកិច្ចសហការ** គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាពនិងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផង និងផ្តល់ការគាំទ្រនិងកិច្ចសហការប្រកបដោយឆន្ទៈជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀតផង និង **ទី៤) អភិក្រមបុរេសកម្ម** គឺការប្រមើលមើលត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នាតាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ្លក ១ ដោយមិនរង់ចាំបញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អុន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកឧត្តម **ង្ហ ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលបានដឹកនាំ ណែនាំ និងតម្រង់ទិសជាប់ជាប្រចាំរហូតសម្រេចបាននូវឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ ឃ្លក ១**។ ខ្ញុំក៏សូមកោតសរសើរចំពោះក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន និងអង្គភាពនានាជាពិសេសថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ដែលបានសហការនិងពុះពារម្នាក់ ប្រកបដោយសាមគ្គីភាព ស្មារតីទទួលខុសត្រូវ និងឆន្ទៈកែទម្រង់ខ្ពស់ ក្នុងនាមជាសេនាធិការដ៏ចំណានរបស់គណៈកម្មាធិការកែទម្រង់រៀងៗខ្លួន ដែលនេះគឺជាកត្តាដ៏ចម្បងនាំឱ្យសម្រេចបាននូវឯកសារដ៏មានសារៈសំខាន់នេះ។

ខ្ញុំរំពឹងថាឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ ឫក ១** នេះ ជាមគ្គទេសក៍បង្ហាញផ្លូវដ៏ល្អសម្រាប់ការអនុវត្តយន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ សំដៅសម្រេចបានន្ទូវចក្ខុវិស័យ សុខដុមនីយកម្ម នៃការកែទម្រង់ ៣ ឫក ១ ដូចដែលបានកំណត់រួមគ្នា។ ជាមួយគ្នានេះ ខ្ញុំសូមលើកទឹកចិត្តឱ្យស្ថាប័ននិងអង្គភាពដែលជាតួអង្គពាក់ព័ន្ធទាំងអស់ដកស្រង់បទពិសោធន៍និងមេរៀនល្អៗ ដែលកើតចេញពីកិច្ចដំណើរការនិងការអនុវត្តនៃឯកសារនេះ ធ្វើជាមូលដ្ឋានក្នុងការកែទម្រង់សម្រាប់ការបោះជំហានបន្ទាប់ ជាបន្តទៀត សំដៅពង្រឹងគុណភាពអភិបាលកិច្ច ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា ឱ្យបានកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ២កើត ខែ ចិត្តសា ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២២ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

មាតិកានុក្រម

បុព្វកថា I

បញ្ជីពាក្យកាត់ VII

សេចក្តីផ្តើម ១

ជំពូកទី១. ក្របខ័ណ្ឌស្ថាប័ន សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ននៃកម្មវិធីកែទម្រង់ ៣ ឫ ១ ..... ៥

១.១. ក្របខ័ណ្ឌស្ថាប័ន ៥

១.១.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៥

១.១.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៨

១.១.៣. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ១៣

១.១.៤. កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ១៤

១.២. សមិទ្ធផល ១៦

១.២.១. សមិទ្ធផលនិងបញ្ហាប្រឈមនៃកម្មវិធីកែទម្រង់នីមួយៗ ១៦

១.២.២. សមិទ្ធផលនិងបញ្ហាប្រឈមនៃយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឫ ១ ..... ៣៩

១.៣. ស្ថានភាពបច្ចុប្បន្ន ៤០

១.៣.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៤០

១.៣.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៤២

១.៣.៣. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ៥០

១.៣.៤. កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ៥០

ជំពូកទី២. ចក្ខុវិស័យស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឫ ១ ..... ៥៣

១.១. ចក្ខុវិស័យនិងបេសកកម្មសម្រាប់កម្មវិធីកែទម្រង់ ៣ ឫ ១ ..... ៥៣

១.១.១. ចក្ខុវិស័យ ៥៣

១.១.២. បេសកកម្ម ៥៤

១.២. ក្របខ័ណ្ឌផែនការសកម្មភាពរួមនិងប្រភពធនធានថវិកា ៥៤

១.២.១. ក្របខ័ណ្ឌផែនការសកម្មភាពរួម ៥៤

១.២.២. ប្រភពធនធានថវិកាគាំទ្រ ៦៣

១.៣. យន្តការសម្របសម្រួលការកែទម្រង់ ៣ ឫ ១ នៃរាជរដ្ឋាភិបាល ៦៥

១.៣.១. សាវតារ ៦៥

១.៣.២. មុខងារនិងភារកិច្ច ៦៦

១.៣.៣. ការរៀបចំផែនការសកម្មភាពនិងរបបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ៦៧

១.៣.៤. កិច្ចប្រជុំប្រចាំត្រីមាស ៦៧

១.៣.៥. យន្តការសម្របសម្រួលកម្រិតមន្ត្រីបង្គោលបច្ចេកទេស ៦៨

សន្និដ្ឋាន ៧១

បញ្ជីឧបសម្ព័ន្ធ ៧៣

ឧបសម្ព័ន្ធទី១. អនុក្រឹត្យលេខ២៤១ អនក្រ.បក. ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ..... ៨១

ឧបសម្ព័ន្ធទី២. ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ លើលិខិតលេខ ១០៩១៥ សហវ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ..... ៨៧

ឧបសម្ព័ន្ធទី៣. ផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ ឫក ១ ..... ៩១

ឧបសម្ព័ន្ធទី៤. របាយការណ៍លេខ ៣៩៤ លស/គ.ជ.អ.ប. ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ..... ១០៣

ឧបសម្ព័ន្ធទី៥. របាយការណ៍ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ..... ១០៩

ឧបសម្ព័ន្ធទី៦. របាយការណ៍ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ..... ១១៥

ឧបសម្ព័ន្ធទី៧. របាយការណ៍ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ..... ១២១

ឧបសម្ព័ន្ធទី៨. របាយការណ៍ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ..... ១២៧

ឧបសម្ព័ន្ធទី៩. របាយការណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ..... ១៣៥

ឧបសម្ព័ន្ធទី១០. របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ ..... ១៤១

ឧបសម្ព័ន្ធទី១១. របាយការណ៍ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ..... ១៤៧

ឧបសម្ព័ន្ធទី១២. របាយការណ៍ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ ..... ១៥៣

ឧបសម្ព័ន្ធទី១៣. របាយការណ៍ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ..... ១៥៩

ឧបសម្ព័ន្ធទី១៤. របាយការណ៍ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ..... ១៦៣

ឧបសម្ព័ន្ធទី១៥. របាយការណ៍ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ..... ១៦៩

ឧបសម្ព័ន្ធទី១៦. របាយការណ៍ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ..... ១៧៣

ឧបសម្ព័ន្ធទី១៧. របាយការណ៍ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ..... ១៧៩

ឧបសម្ព័ន្ធទី១៨. សេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ..... ១៨៧

ឧបសម្ព័ន្ធទី១៩. សេចក្តីព្រាងបឋមទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រ កម្មវិធីកែទម្រង់ ៣ ឫក ១ (សិក្សាបឋម) ១៩១

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

បញ្ជីពាក្យកាត់

កសហវ.	: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក.ហ.ស.	: ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
គ.ក.រ.	: គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
គ.ក.ហ.	: គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គ.ច.ប្រ.	: គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
គ.ជ.អ.ប.	: គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
គ.ហ.ស.	: គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ផ.ស.ស.	: ផលិតផលក្នុងស្រុកសរុប
យ.ស.ក.	: យន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ នៃរាជរដ្ឋាភិបាល
អ.គ.រ.	: អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
អ.គ.ហ.	: អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អ.ព.ដ.	: អគ្គនាយកដ្ឋានពន្ធដារ
BSP	: Budget Strategic Plan ផែនការយុទ្ធសាស្ត្រថវិកា
CAP	: Consolidated Action Plan ផែនការសកម្មភាពរួម
FMIS	: Financial Management Information System ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
MTBF	: Medium Term Budget Framework ក្របខ័ណ្ឌថវិការយៈពេលមធ្យម
MTFF	: Medium Term Fiscal Framework ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
NRMIS	: Non-tax Revenue Management Information System ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
IPSAS Cash Basis	: International Public Sector Accounting Standards Cash Basis ស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ ផ្អែកលើមូលដ្ឋានសាច់ប្រាក់

SARMIS : ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
State Assets Register Management Information System

TSA : Treasury Single Account
គណនីទោលរតនាគារ

ឯកសារមានន័យសាធារណៈ | https://t.me/oa_channel

សេចក្តីផ្តើម

កម្មវិធីកែទម្រង់ ៣ ប្លុក ១ សំដៅដល់កម្មវិធីកែទម្រង់ដែលមានចរិតលក្ខណៈជាប្រព័ន្ធនិងប្រទាក់ក្រឡារបស់រាជរដ្ឋាភិបាល ដែលក្នុងនោះរួមមានកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់-ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ២០០៤ មក ដែលដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន។ កម្មវិធីកែទម្រង់នេះត្រូវបានកំណត់ជា ៤ ដំណាក់កាល តាំងពីការចាប់ផ្តើមដំបូង ពោលគឺត្រូវអនុវត្តរហូតដល់ឆ្នាំ២០២៥ ដើម្បីសម្រេចចក្ខុវិស័យ ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ។

កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានចាប់ផ្តើមដំបូងជាប្រវត្តិសាស្ត្រនៅឆ្នាំ២០០២ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់។ ផ្អែកតាមភាពជោគជ័យនៃកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានពង្រីកកំណែទម្រង់នេះទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០០៨ តាមរយៈការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងដំណាក់កាលនេះ មានលក្ខណៈកាន់តែសាំញ៉ាំ ស៊ីជម្រៅ ទូលំទូលាយ និងមានភាពប្រទាក់ក្រឡាគ្នាលើគ្រប់វិស័យ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ ដំណាក់កាលទី១ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០ និងបានដាក់ចេញនូវ កម្មវិធីជាតិដំណាក់កាលទី២ ដែលត្រូវអនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។ កម្មវិធីកែទម្រង់នេះ ដឹកនាំអនុវត្តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន។

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានចាប់ផ្តើមអនុវត្តជាផ្លូវការចាប់ពីឆ្នាំ២០១៥ តាមរយៈការដាក់ចេញនូវកម្មវិធីដំណាក់កាលទី១ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ បច្ចុប្បន្ន កម្មវិធីជាតិកែទម្រង់នេះកំពុងត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០៣៥។ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈដឹកនាំដោយគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ជាប្រធាន។

កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវបានចាប់ផ្តើមដំបូងនៅឆ្នាំ២០០០ ដែលកាលនោះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ចាប់ពីឆ្នាំ២០១៣ មក កម្មវិធីកែទម្រង់នេះត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងនិងដឹកនាំដោយក្រសួងយុត្តិធម៌វិញ។ បច្ចុប្បន្ន ក្រសួងយុត្តិធម៌កំពុងពិនិត្យនិងធ្វើបច្ចុប្បន្នភាពកម្មវិធីកែទម្រង់នេះ ព្រមទាំងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធស្ថាប័នអនុវត្ត។

ថ្វីត្បិតកម្មវិធីកែទម្រង់នីមួយៗខាងលើ ស្ថិតក្រោមសមត្ថកិច្ចដឹកនាំអនុវត្តដោយក្រសួងដោយឡែកពីគ្នាក៏ដោយ សកម្មភាពកែទម្រង់ជាក់ស្តែងភាគច្រើន គឺអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀត ដែលនេះគឺជាលក្ខណៈពិសេសជាប្រព័ន្ធនិងប្រទាក់ក្រឡានៃកម្មវិធីកែទម្រង់ ៣ ឫក ១ នេះ។

ទំនាក់ទំនងជាប្រព័ន្ធនិងប្រទាក់ក្រឡានេះ មានមិនត្រឹមតែរវាងក្រសួង ស្ថាប័នដឹកនាំការងារកែទម្រង់ ឬតួអង្គនិម្មាបនករកែទម្រង់ ជាមួយនឹងក្រសួង ស្ថាប័នអនុវត្តការងារកែទម្រង់ ដែលជាតួអង្គប្រតិបត្តិករកែទម្រង់ប៉ុណ្ណោះទេ តែលើសពីនេះនិងរឹតតែសំខាន់ជាងនេះ នោះគឺទំនាក់ទំនងនិងភាពប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់នីមួយៗ ឬនិម្មាបនកម្មនៃការកែទម្រង់នីមួយៗតែម្តង គឺ **ការកែទម្រង់ ៣ ឫក ១**។

ទំនាក់ទំនងនិងភាពប្រទាក់ក្រឡាគ្នានៃស្ថាប័ននិងនិម្មាបនកម្មរវាងកម្មវិធីកែទម្រង់ ៣ ឫក ១ អាចមានសសរស្តម្ភចំនួន ៤ គឺ÷

ទី១) មុខងារ÷ មុខងារនៅទីនេះ សំដៅដល់ការផ្ទេរមុខងាររវាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ការផ្ទេរមុខងារ ទាមទារនិងតែងតែត្រូវមានការគិតគូរជាកញ្ចប់ជាមួយនឹងការផ្ទេរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ដើម្បីគាំទ្រការអនុវត្តមុខងារដែលត្រូវបានផ្ទេរ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។ ទន្ទឹមនេះ ការពិនិត្យអំពីមុខងារស្ថាប័នក៏រួមចំណែកដល់ការធានាសង្គតិភាពនិងវិចារណកម្មនៃស្ថាប័នច្រើនដែលអាចមានមុខងារប្រហាក់ប្រហែលគ្នាផងដែរ។

ទី២) ហិរញ្ញវត្ថុ÷ ជាសត្យានុម័ត ការអនុវត្តមុខងារនិងភារកិច្ចរបស់ក្រសួង ស្ថាប័ន ត្រូវមានថវិកាគាំទ្រ។ នៅក្នុងបរិបទដែលសមិទ្ធកម្មក្លាយជាគោលដៅនៃការគ្រប់គ្រងក្នុងរដ្ឋបាលសាធារណៈកម្ពុជា ថវិកាមិនត្រឹមតែជាការគាំទ្រដល់ការបំពេញមុខងារនិងភារកិច្ចតែប៉ុណ្ណោះទេ តែថវិកាគឺជាឧបករណ៍នៃគោលនយោបាយ ឬថវិកាត្រូវផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ឬនិយាយម្យ៉ាងទៀត ថវិកាត្រូវប្រើប្រាស់ដើម្បីសម្រេចលទ្ធផលដែលបានគ្រោងទុក។ នេះគឺជាគោលនយោបាយថវិកាសមិទ្ធកម្ម នៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដោយឡែក នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ ៣ ឫក ១ ហិរញ្ញវត្ថុឬថវិកាត្រូវគាំទ្រនិងមានសង្គតិភាពទៅនឹងគោលនយោបាយវិមជ្ឈការ គោលនយោបាយធនធានមនុស្ស និងគោលនយោបាយច្បាប់និងប្រព័ន្ធយុត្តិធម៌។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ទី៣) ធនធានមនុស្ស÷ ការកែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតទៅលើសមាសធាតុគន្លឹះចំនួន ៣ គឺ ការកែទម្រង់និងអភិវឌ្ឍសមត្ថភាពស្ថាប័ន ការកែទម្រង់ប្រព័ន្ធបៀវត្ស និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលសំដៅដល់មន្ត្រីរាជការ។ បេសកកម្មទាំង ៣ នេះ មានទំនាក់ទំនងនិងគាំទ្រដល់កម្មវិធីកែទម្រង់ ២ ផ្សេងទៀតខាងលើ ឬសសរស្តម្ភទាំង ២ ខាងលើ គឺមុខងារ និងហិរញ្ញវត្ថុ។

ទី៤) ច្បាប់និងប្រព័ន្ធយុត្តិធម៌÷ ការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ អាចមានចរិតលក្ខណៈពិសេសពីសសរស្តម្ភ ៣ ផ្សេងទៀត ខាងលើ នៅត្រង់ការងារនេះ ផ្តោតទៅលើវិស័យយុត្តិធម៌ ឬនិយាយម្យ៉ាងទៀត ការកែទម្រង់សកម្មភាពការងារនៅក្នុងអំណាចមួយដោយឡែកផ្សេងពីអំណាចនីតិប្រតិបត្តិ ឬរដ្ឋាភិបាល នោះគឺអំណាចតុលាការ។ ទោះយ៉ាងណាក៏ដោយ កាលណានិយាយពីមុខងារ ហិរញ្ញវត្ថុឬថវិកា និងធនធានមនុស្ស ឬមន្ត្រីរាជការ ការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ នៅតែមានទំនាក់ទំនង ទោះដោយប្រយោល “**ឃ្លក ១**” ជាមួយនឹងសសរស្តម្ភ ៣ ផ្សេងទៀត ឬកម្មវិធីកែទម្រង់ ៣ ផ្សេងទៀត ដោយខានមិនបាន។

ក្នុងន័យនេះ បន្ទាប់ពីការអនុវត្តកម្មវិធីកែទម្រង់នីមួយៗនៅតាមការដ្ឋាននីមួយៗជាច់ដោយឡែកពីគ្នាអស់រយៈពេលប៉ុន្មានឆ្នាំកន្លងមក នៅឆ្នាំ២០១៥ តាមរយៈសេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ទាំង៣ បានបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្មនៃទំនាក់ទំនងការងារកែទម្រង់ទាំងបីនេះរបស់រាជរដ្ឋាភិបាល។ យន្តការសម្របសម្រួលនេះ ធ្វើឡើងក្រោមទម្រង់ជារបបប្រជុំប្តូរវេនប្រចាំត្រីមាស រវាងអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់នីមួយៗ។ ស្ថិតក្រោមវិធានៃសេចក្តីសម្រេចរួមនេះ កិច្ចប្រជុំប្តូរវេនត្រូវបានរៀបចំនិងបានសម្រេចសកម្មភាពជាបន្តបន្ទាប់ ដោយបានពិភាក្សាលើការងារសំខាន់ៗ ដោះស្រាយបញ្ហាប្រឈមគន្លឹះរួមគ្នា បានឈានទៅដល់ការរៀបចំផែនការសកម្មភាពរួមគ្នានិងបានរៀបចំសិក្ខាសាលារួមគ្នាផងដែរ។

នាឱកាសបិទបញ្ចប់សិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យ នៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី**៧** ខែមិថុនា ឆ្នាំ២០១៨ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ឱ្យពិនិត្យលទ្ធភាពបញ្ចូលលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ទៅក្នុងយន្តការសម្របសម្រួលនៃលេខាធិការដ្ឋានកែទម្រង់ជាប្រព័ន្ធទាំង ៣ ខាងលើ។ ដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់នេះ អគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់ទាំង៤ បានពិនិត្យ ពិភាក្សា និងរកឃើញថាការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មានលក្ខណៈពិសេស ដោយឡែកខុសប្លែក ពីការកែទម្រង់ ៣ ផ្សេងទៀត ទាំងរចនាសម្ព័ន្ធស្ថាប័ន ទាំងវិស័យការងារ។ ផ្អែកតាមរបកគំហើញនេះ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

យន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ្លក ១ ត្រូវបានបង្កើតឡើង តាមការសម្រេចឯកភាពគាំទ្រដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨។ ចាប់ពីពេលនោះមក កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ត្រូវបានបញ្ចូលទៅក្នុងយន្តការសម្របសម្រួលការងារកែទម្រង់ទាំង ៣ និងបានប្រែក្លាយប្រព័ន្ធសម្របសម្រួលនេះ ទៅជាយន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ្លក ១ របស់រាជរដ្ឋាភិបាល ដោយរក្សាបាននូវលក្ខណៈពិសេសនៃការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ នៅក្នុងយន្តការថ្មីនេះ ដែលត្រូវបានកំណត់ថាជាយន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ្លក ១ នៃរាជរដ្ឋាភិបាល ឬហៅកាត់ថា "**យ.ស.ក.**"។

បទពិសោធន៍រយៈពេល ៨ ឆ្នាំនៃការអនុវត្តយន្តការសម្របសម្រួលនេះ បានជំរុញអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ ៣ ឃ្លក ១ ឱ្យផ្តួចផ្តើមនិងសាកល្បងបោះជំហានទៅកាន់ដំណាក់-កាលថ្មីមួយកម្រិតទៀត នោះគឺការរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមគ្នាមួយ ទុកជាផែនទីបង្ហាញផ្លូវរួមគ្នា ដែលបង្ហាញអំពីទិសដៅនិងសកម្មភាពដែលត្រូវសហការ សម្របសម្រួល និង/ឬគាំទ្រជួនគ្នាទៅវិញទៅមក។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឃ្លក ១** នេះ ត្រូវបានសម្រេចឡើងបន្ទាប់ពីបានពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាច្រើនលើក រួមមាន÷

- ➢ កិច្ចប្រជុំផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់នីមួយៗ
- ➢ កិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ្លក ១
- ➢ វិបស្សនានៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ្លក ១
- ➢ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឃ្លក ១ ដែលមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលរាជធានី ខេត្តគន្លឹះចំនួន ១១។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឃ្លក ១** នេះមានគោលដៅនិងគោលបំណងចំនួន ៣ គឺ÷

ទី១. ជាឯកសារទស្សនាទានអំពីកម្មវិធីកែទម្រង់ ៣ ឃ្លក ១ របស់រាជរដ្ឋាភិបាល ដែលនៅក្នុងនោះមានបង្ហាញអំពីក្របខ័ណ្ឌស្ថាប័ន សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ននៃកម្មវិធីកែទម្រង់នីមួយៗ។

ទី២. ជាផែនទីបង្ហាញផ្លូវដែលមានការកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ កម្មវិធីការងារ និងយន្តការដើម្បីសម្រេចបាននូវចក្ខុវិស័យនោះ។

ទី៣. ជាកម្មវិធីការងារនិងផែនការសកម្មភាពរួមគ្នានៃកម្មវិធីកែទម្រង់ ៣ ឃ្លក ១ ដែលអាចជាកម្មវត្ថុនៃការកែសម្រួលនិងបំពេញបន្ថែម ទៅតាមកាលៈទេសៈចាំបាច់នៃដំណើរការអនុវត្ត ក្នុងស្មារតីចាត់ទុកឯកសារនេះជាឯកសាររស់។

ជំពូកទី១. ក្របខ័ណ្ឌស្ថាប័ន សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ន នៃកម្មវិធីកែទម្រង់ ៣ បូក ១

១.១. ក្របខ័ណ្ឌស្ថាប័ន

១.១.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានដាក់ចេញនិងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤។ ការកែទម្រង់នេះមានគោលដៅកសាងប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមស្តង់ដារអន្តរជាតិ ដែលនឹងផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូលនិងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅប្រព័ន្ធ ដែលផ្តោតលើធាតុចេញឬលទ្ធផល និងវិមជ្ឈការ។ ក្នុងបេសកកម្មនេះ ក្រុមការងារ ៣ កម្រិតផ្សេងគ្នាត្រូវបានបង្កើត រួមមាន÷ ១) គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលហៅកាត់ថា **គ.ហ.ស.**) ២) គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ដែលហៅកាត់ថា **គ.ក.ហ.**) និង៣) ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ននិងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ដែលហៅកាត់ថា **ក.ហ.ស.**)។

១.១.១.១. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហ-ប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។ **គ.ហ.ស.** នេះគឺជាវេទិកាកម្រិតបច្ចេកទេសខ្ពស់មួយដើម្បីតាមដាននិងសម្របសម្រួលក្នុងចំណោមអង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាលទាំងអស់។ **គ.ហ.ស.** មានសមាសភាព ដូចតទៅ÷

១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ		ប្រធាន
២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	មួយរូប	អនុប្រធានប្រចាំការ
៣. ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា	មួយរូប	អនុប្រធាន
៤. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំ ប្រហាក់ប្រហែលមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ		អនុប្រធាន

៥. អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៦. អង្គភាពប្រតិបត្តិនៃគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ដែលមានការពាក់ព័ន្ធផ្សេងទៀត	សមាជិក
៧. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	សមាជិកអចិន្ត្រៃយ៍។

១.១.១.២. គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ក.ហ.**) ជាគណៈកម្មការផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) ដែលដឹកនាំដោយ **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។ សមាសភាពនៃ **គ.ក.ហ.** គឺជាថ្នាក់ដឹកនាំនៃ **កសហវ.** ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអគ្គនាយកដ្ឋាន និងប្រធានអង្គភាពនានាក្រោមឱវាទ **កសហវ.** ដែលចូលរួមអនុវត្តការងារកែទម្រង់។ **គ.ក.ហ.** រៀបចំកិច្ចប្រជុំត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសនិងឆ្នាំ មុននឹងឈានដល់យន្តការនៃ **គ.ហ.ស.**។

១.១.១.៣. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

កសហវ. ក្នុងនាមជាតួអង្គនិម្មាបនករ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ត្រូវបានបង្កើតឡើង នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានរបស់ខ្លួន។ **ក.ហ.ស.** នៅក្នុង **កសហវ.** មានភារកិច្ចដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់សាមីអង្គភាពនីមួយៗ ដែលមានសមាសភាពដូចតទៅ÷

១. អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ		ប្រធាន
២. អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង	១ រូប	អនុប្រធានប្រចាំការ
៣. អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង	១ ឬ ច្រើនរូប	អនុប្រធាន
៤. ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទ	១ ឬ ច្រើនរូប	សមាជិក
៥. មន្ត្រីជំនាញពាក់ព័ន្ធក្រោមឱវាទ	១ ឬ ច្រើនរូប	សមាជិក
៦. មន្ត្រីបង្គោល ដែលជាអ្នកទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន	១ ឬ ច្រើនរូប	លេខាធិការ។

អគ្គនាយកដ្ឋាន ដែលមានមន្ត្រីបង្គោលច្រើនរូប អាចរៀបចំបង្កើតជាក្រុមមន្ត្រីបង្គោលបាន តាមសេចក្តី

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ត្រូវការចាំបាច់ជាក់ស្តែង ដើម្បីសម្របសម្រួលការងារផ្ទៃក្នុង និងជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**អ.គ.ហ.**"។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទនីមួយៗ នៃ **កសហវ.** ត្រូវតែងតាំងដោយរដ្ឋមន្ត្រី **កសហវ.**។ កិច្ចដំណើរការនៃ **ក.ហ.ស.** នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ **កសហវ.** ត្រូវកំណត់ដោយប្រធាន **ក.ហ.ស.** នីមួយៗ។

១.១.១.៤. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន (**ក.ហ.ស.**) ដែលត្រូវបានដឹកនាំដោយថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នសាមីនោះ ដែលជាសមាជិកនៃ **ក.ហ.ស.**។ កិច្ចដំណើរការនៃ **ក.ហ.ស.** នៅតាមក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន។ សមាសភាពនៃ **ក.ហ.ស.** នេះគួរតែយ៉ាងហោចណាស់ជាអនុប្រធានផ្នែកហិរញ្ញវត្ថុឬគណនេយ្យ។ សមាសភាពនៃ **ក.ហ.ស.** នៅតាមក្រសួង ស្ថាប័ន រួមមាន÷

១. ប្រធាន **ក.ហ.ស.** ១ រូប ត្រូវជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំមួយរូប ទទួលបន្ទុកផ្ទាល់ជួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន

២. អនុប្រធាន **ក.ហ.ស.** ១ រូប អាចជាអនុរដ្ឋលេខាធិការ ឬអគ្គលេខាធិការ ឬអគ្គនាយក ទទួលបន្ទុកហិរញ្ញវត្ថុ ឬថ្នាក់ដឹកនាំបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស.**

៣. សមាជិក **ក.ហ.ស.** មួយចំនួន ដែលត្រូវមាន÷

- តំណាង ១ រូប ពីគ្រប់អគ្គនាយកដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមឱវាទក្រសួង ស្ថាប័នផ្ទាល់ និង
- តំណាង ១ រូប ពីគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួង ស្ថាប័នសាមី នីមួយៗ
- លេខាធិការ **ក.ហ.ស.** ១ រូប ឬមួយចំនួន តាមការចាំបាច់ ដែលជាមន្ត្រីបង្គោលតែងតាំងដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ស្របតាមសំណើនិងលក្ខខណ្ឌយោងការងារ ដែលកំណត់ដោយប្រធាន **ค.ห.ส.**។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** នៅតាមក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ដោយមានការឯកភាពពីប្រធាន **ค.ห.ส.**។

១.១.១.៥. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.ค.ห.**)

ជាសេនាធិការរបស់ **គ.ហ.ស.** ក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ **គ.ហ.ស.** និងសម្របសម្រួលការងារជាមួយ **ក.ហ.ស.** នៃក្រសួង ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទ **កសហវ.** ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងសម្របសម្រួលការងារជាមួយស្ថាប័នកែទម្រង់ផ្សេងទៀតរបស់រាជ-រដ្ឋាភិបាល។

ទន្ទឹមនេះ **អ.គ.ហ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការងមួយចំនួនតាមការចាំបាច់ និងមានតួនាទីផ្តល់ការគាំទ្រជូនក្រសួង ស្ថាប័ន និងអង្គភាពនានាក្រោមឱវាទ **កសហវ.** ទាំងក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្របខ័ណ្ឌស្ថាប័ននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



១.១.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញ និងសាំញ៉ាំ អាស្រ័យហេតុនេះ ច្បាប់រៀបចំអង្គការ រួមមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំបង្កើតនូវគណៈកម្មាធិការអន្តរក្រសួងមួយសម្រាប់ការដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការងារកំណែទម្រង់នេះ។ ផ្អែកតាមការតម្រូវដោយច្បាប់រៀបចំអង្គការទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការរៀបចំបង្កើត "**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**" ដែលហៅកាត់ថា "**គ.ជ.អ.ប.**" សម្រាប់ដឹកនាំ សម្របសម្រួល និងគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ទោះយ៉ាងនេះក្តី ការវិវត្តនៃកំណែទម្រង់នេះកាន់តែស៊ីជម្រៅពីមួយដំណាក់កាលទៅមួយដំណាក់កាលបានតម្រូវឱ្យមានការកែសម្រួល

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ជាបន្តបន្ទាប់នូវសមាសភាពនៃ **គ.ជ.អ.ម.** ដែលបច្ចុប្បន្ននេះ យោងតាមព្រះរាជក្រឹត្យលេខ នស/រតត/០៥២០/៥០៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ សមាសភាពនៃ **គ.ជ.អ.ម.** រួមមានចំនួន **២៥រូប** ក្នុងនោះ÷

១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ		ជាប្រធាន
២. ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី		ជាអនុប្រធាន
៣. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ		ជាអនុប្រធាន
៤. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់		ជាអនុប្រធាន
៥. ទេសរដ្ឋមន្ត្រី	១រូប	ជាអនុប្រធាន
៦. រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ	ចំនួន ២០រូប	ជាសមាជិក។

គ.ជ.អ.ម. ត្រូវមានបេសកកម្មសំខាន់ពាក់ព័ន្ធនឹង ១.) ការរៀបចំតាក់តែង និងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២.) ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការពិនិត្យមើលឡើងវិញ និងកំណត់នូវមុខងារ ធនធាន (ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ) សិទ្ធិអំណាច និងការទទួលខុសត្រូវដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៣.) ការលើកអនុ-សាសន៍ជូនរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំតាក់តែង ឬការធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ៤.) ការធានាឱ្យមានការសម្របសម្រួល និងពិគ្រោះយោបល់អំពីគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានាដែលរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធានាឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៥.) ការធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការអនុវត្តច្បាប់ពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់-ក្រោមជាតិ។

ដើម្បីធានាដល់ការសម្រេចបេសកកម្មរបស់ខ្លួន **គ.ជ.អ.ម.** ចាំបាច់ត្រូវរៀបចំបង្កើតអនុគណៈកម្មាធិការនានា ដែលបច្ចុប្បន្ន **គ.ជ.អ.ម.** មានអនុគណៈកម្មាធិការក្រោមចំណុះចំនួន ៥ និងលេខាធិការដ្ឋានចំនួន ១ គឺ÷

១.១.២.១. អនុគណៈកម្មាធិការមុខងារ និងធនធាន

មានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ម.** លើកិច្ចការនានាពាក់ព័ន្ធនឹងប្រព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុគណៈកម្មាធិការមុខងារ និងធនធាននេះមានរដ្ឋមន្ត្រីក្រសួង

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

មហាផ្ទៃជាប្រធាន, រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ០១រូប ជាអនុប្រធានអចិន្ត្រៃយ៍, រដ្ឋលេខាធិការនៃ **កសហវ.** ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការ ឬអនុរដ្ឋ-លេខាធិការ ០១រូប នៃក្រសួងដែលជាសមាជិក **គ.ជ.អ.ប.**, តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត០១រូប និងតំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ០១រូបជា សមាជិក។

១.១.២.២. អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ

មានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ប.** លើកិច្ចការនានាពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុនេះរួមមាន រដ្ឋមន្ត្រី **កសហវ.** ជាប្រធាន, រដ្ឋលេខាធិការនៃ **កសហវ.** ០១រូប ជាអនុប្រធានអចិន្ត្រៃយ៍, រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការនៃក្រសួងផែនការ ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ០១រូប នៃក្រសួងដែលជាសមាជិក **គ.ជ.អ.ប.**, តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត០១រូប និងតំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ០១រូបជា សមាជិក។

១.១.២.៣. អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

មានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ប.** លើកិច្ចការនានាពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុគណៈកម្មាធិការនេះរួមមានទេសរដ្ឋមន្ត្រី ០១រូប ជាប្រធាន, រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈជាអនុប្រធានអចិន្ត្រៃយ៍, រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ០១រូប នៃក្រសួងដែលជាសមាជិក **គ.ជ.អ.ប.**, តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត០១រូប និងតំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ០១រូបជាសមាជិក។

១.១.២.៤. អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

មានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ប.** លើកិច្ចការនានាពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនេះរួមមាន រដ្ឋមន្ត្រីក្រសួងផែនការជាប្រធាន, រដ្ឋលេខាធិការនៃក្រសួងផែនការ ០១រូប ជាអនុប្រធានអចិន្ត្រៃយ៍, រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការនៃ **កសហវ.** ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ០១រូប នៃក្រសួងដែលជាសមាជិក **គ.ជ.អ.ប.**, តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត០១រូប និងតំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ០១រូប ជាសមាជិក។

១.១.២.៥. អនុគណៈកម្មាធិការសេវាយុត្តិធម៌

មានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ប.** លើកិច្ចការនានាពាក់ព័ន្ធនឹងការសម្រុះសម្រួលដោះស្រាយវិវាទ

រដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុ-គណៈកម្មាធិការនេះ រួមមានទេសរដ្ឋមន្ត្រី ០១រូប ជាប្រធាន, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ០១រូប ជាអនុប្រធានអចិន្ត្រៃយ៍, រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ០១រូប ជាអនុប្រធាន, រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ០១រូបនៃក្រសួងដែលជាសមាជិក **គ.ជ.អ.ម.**, តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត០១រូប និងតំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ០១រូបជា សមាជិក។

១.១.២.ខ. លេខាធិការដ្ឋាន

ជាមួយគ្នានេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏បានតម្រូវឱ្យរៀបចំបង្កើតនូវលេខាធិការដ្ឋាន **គ.ជ.អ.ម.** មួយ ដើម្បីធ្វើជាសេនាធិការឱ្យ **គ.ជ.អ.ម.** និងអនុគណៈកម្មាធិការនានារបស់ **គ.ជ.អ.ម.** ក្នុងការបំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ បច្ចុប្បន្ននេះ លេខាធិការដ្ឋាន **គ.ជ.អ.ម.** រួមមានអង្គភាពក្រោមចំណុះចំនួន ៥ គឺ÷

ក. អង្គភាពវិភាគនិងអភិវឌ្ឍន៍គោលនយោបាយ÷ មានតួនាទីសិក្សាស្រាវជ្រាវ វិភាគ រៀបចំ និងតម្រឹមក្របខ័ណ្ឌគតិយុត្តនានាពាក់ព័ន្ធនឹងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ រួមមានដូចជាការផ្ទេរមុខងារ និងធនធាន វិមជ្ឈការហិរញ្ញវត្ថុ ការកសាងផែនការ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងធនធានធម្មជាតិ ការបញ្ជាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ. អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី÷ មានតួនាទីសំខាន់ពាក់ព័ន្ធនឹងការរៀបចំនិងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកៀរគរធនធានសម្រាប់ការអនុវត្តកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.អ.ម.** និងការសម្របសម្រួលនិងតម្រឹមគម្រោងកម្មវិធីដោយឡែកនានាជាមួយកម្មវិធីជាតិ។

គ. អង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុ÷ មានតួនាទីសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តកម្មវិធីជាតិ ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងទ្រព្យ-សម្បត្តិរបស់ **គ.ជ.អ.ម.**។

ឃ. អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន÷ មានតួនាទីសំខាន់ៗពាក់ព័ន្ធនឹងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការប្រមូល ចងក្រងនិងផ្សព្វផ្សាយព័ត៌មាននិងឯកសារនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ង. ក្រុមសវនកម្មផ្ទៃក្នុង÷ មានតួនាទីពាក់ព័ន្ធនឹងការធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្តរបស់អង្គភាពទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលអនុវត្តកម្មវិធី ឬគម្រោងស្ថិតនៅក្រោមក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ **គ.ជ.អ.ម.**។

រចនាសម្ព័ន្ធដឹកនាំនៃ គ.ជ.អ.ម.



ក្រៅពីយន្តការដែលមានលក្ខណៈជាអន្តរស្ថាប័នខាងលើ ដើម្បីធានាដល់ការលើកកម្ពស់ការទទួលខុសត្រូវលើការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅតាមក្រសួងពាក់ព័ន្ធ ក៏ត្រូវបានណែនាំដោយរាជរដ្ឋាភិបាលឱ្យរៀបចំបង្កើតនូវគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅក្នុងក្រសួងសាមីនីមួយៗផងដែរ ហើយយន្តការនេះត្រូវស្ថិតក្រោមការដឹកនាំ និងការទទួលខុសត្រូវដោយផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងសាមីដោយត្រូវមានរដ្ឋលេខាធិការ ០១រូប ជាអនុប្រធានប្រចាំការដើម្បីសម្របសម្រួលការងារប្រចាំថ្ងៃ និងត្រូវមានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងទីប្រឹក្សាមួយចំនួន ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋាន និងអង្គភាព

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ពាក់ព័ន្ធនានាចំណុះក្រសួងសាមីនីមួយៗជាសមាជិក។

នៅតាមរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកនីមួយៗមានការរៀបចំបង្កើតនូវ "**គណៈកម្មការដឹកនាំការងារកំណែទម្រង់**" មួយ ដើម្បីដឹកនាំកិច្ចដំណើការជាទូទៅនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គណៈកម្មការនេះមានអភិបាលជាប្រធាន, អភិបាលរង ០១រូបជាអនុប្រធាន, និងប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធនានាជាសមាជិក។

១.១.៣. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.រ.**) ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានសមាសភាពអនុប្រធាន និងសមាជិក ជារដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ក្នុងនោះរួមមានទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងមុខងារសាធារណៈ, ក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងយុត្តិធម៌, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងរ៉ែនិងថាមពល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និងកីឬា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងបរិស្ថាន, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងព័ត៌មាន, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងសុខាភិបាល, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងវប្បធម៌និងវិចិត្រសិល្ប:, ក្រសួងទេសចរណ៍, ក្រសួងធម្មការនិងសាសនា, ក្រសួងកិច្ចការនារី, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវ:, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

ផ្អែកតាមអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននិងអនុគណៈកម្មាធិការនានារបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អនុគណៈកម្មាធិការចំនួនបួន ចំណុះឱ្យគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានបង្កើត រួមមាន÷

១. អនុគណៈកម្មាធិការកែទម្រង់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស និងបុគ្គលិករបស់ក្រសួង ស្ថាប័ន

២. អនុគណៈកម្មាធិការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស

៣. អនុគណៈកម្មាធិការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ

៤. អនុគណៈកម្មាធិការកែលម្អ និងវាយតម្លៃសេវាសាធារណៈ

គ.ក.រ. អាចបង្កើតអនុគណៈកម្មាធិការបន្ថែម តាមការចាំបាច់។

គ.ក.រ. មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីសម្របសម្រួលនិងគាំទ្រដល់ការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការនិងអនុគណៈកម្មាធិការនានា។

ទន្ទឹមនឹងនេះ នៅថ្នាក់ជាតិ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួង ស្ថាប័ន ត្រូវបានបង្កើតឡើង។ ក្រុមការងារនេះដឹកនាំដោយថ្នាក់ដឹកនាំជារដ្ឋលេខាធិការមួយរូបនៃក្រសួង ស្ថាប័នសាមីដែលជាអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។ នៅថ្នាក់ក្រោមជាតិ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជធានី ខេត្ត ត្រូវបានបង្កើតឡើង ដោយមានអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន។

រចនាសម្ព័ន្ធគ្រប់គ្រងនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ



១.១.៤. កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មានន្ទីរចនាសម្ព័ន្ធគ្រប់គ្រងដែលកំណត់ដោយអនុក្រឹត្យលេខ៤៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសមាសភាពថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌, អង្គការតុលាការ, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ,ក្រសួងពាណិជ្ជកម្ម, ក្រសួងមុខងារសាធារណៈ, អង្គភាពប្រឆាំងអំពើពុករលួយ និងប្រធានលេខាធិការដ្ឋាន។ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍នេះ គឺត្រូវរៀបចំដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

អង្គការលេខនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌



ដោយផ្អែកលើនិន្នាការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជាបច្ចុប្បន្ន និងបទពិសោធន៍របស់ប្រទេសមួយចំនួនជាពិសេសបទពិសោធន៍ល្អៗរបស់ស្ថាប័នកំណែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលដែលបានអនុវត្តនូវមុខងាររបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព និងដើម្បីឆ្លើយតបនឹងទំហំការងារនិងភាពចាំបាច់ក្នុងការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក៏ដូចជាពង្រឹងកិច្ចការងាររៀបចំគោលនយោបាយ ផែនការសកម្មភាព កម្មវិធីការងារ និងពង្រឹងនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ក្រសួងយុត្តិធម៌បាននិងកំពុងពិនិត្យលទ្ធភាពកែសម្រួលរចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដោយពិនិត្យនិងកែសម្រួលសមាសភាពឡើងវិញនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីបង្កើនការចូលរួមនិងលើកកម្ពស់កិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ជាមួយគ្នានេះ **លេខាធិការដ្ឋានអចិន្ត្រៃយ៍** នឹងត្រូវកែសម្រួលទៅជា **អគ្គលេខាធិការដ្ឋាន** ដោយពង្រឹងឡើងវិញនូវការប្រើប្រាស់ធនធានមនុស្ស ហិរញ្ញវត្ថុ និងកន្លែងធ្វើការ ដើម្បីអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព និងដើរស្របតាមកម្មវិធីកំណែទម្រង់ក្នុងវិស័យផ្សេងៗ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌នឹងបំពេញតួនាទីជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃ និងបំពេញមុខងារចម្បង ដូចខាងក្រោម÷

- ➢ ដើរតួនាទីជាអ្នកសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ដើម្បីសម្រេចបានគោលដៅទាំងឡាយនៃផែនការយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

- សហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ក្នុងការកៀរគរនូវជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងសម្របសម្រួលការងារជាមួយកំណែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។
- ដើរតួនាទីជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនិងពិនិត្យមើលចំណុចខ្វះខាតដែលត្រូវកែទម្រង់ចំពោះការអនុវត្ត និងការប្រតិបត្តិរបស់អង្គភាពក្រោមវិស័យយុត្តិធម៌។
- ទន្ទឹមនេះ អគ្គលេខាធិការដ្ឋាន ក៏មានតួនាទីផ្តល់ការគាំទ្រនិងជំរុញដល់ក្រសួង ស្ថាប័ន និងអង្គភាពនានាក្រោមឱវាទក្រសួងយុត្តិធម៌ក្នុងការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ វាយតម្លៃ និងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

១.២. សមិទ្ធផល

១.២.១. សមិទ្ធផលនិងបញ្ហាប្រឈមនៃកម្មវិធីកែទម្រង់នីមួយៗ

១.២.១.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក. សមិទ្ធផលតាមដំណាក់កាល

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា កាលថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងស្មារតីប្រកាន់ខ្ជាប់ទៅតាមអភិក្រមជាខ្សែ (Platform Approach) ដោយបែងចែកជាបួនខ្សែនឬដំណាក់កាលតាមក្របខ័ណ្ឌពេលវេលាជាក់លាក់ ដូចខាងក្រោម÷

- ដំណាក់កាលទី១ **"ការបង្កើនភាពជឿទុកចិត្តនៃថវិកា"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ និងបានផ្តល់អាទិភាពបន្ទាន់លើវិន័យថវិកា ដែលផ្តោតលើការពង្រឹងការប្រមូលនិងគ្រប់គ្រងចំណូល, ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកំណត់និងដាក់ចេញវិធានការជាច្រើន ដែលនាំឱ្យរាជរដ្ឋាភិបាលសម្រេចដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់ កង្វះសាច់ប្រាក់ដ៏ភ្ជាប់ដ៏ រ៉ៃ វិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការលទ្ធកម្មសាធារណៈ។
- ដំណាក់កាលទី២ **"ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដែលមានគោលដៅចម្បងលើការរៀបចំ ការកែលម្អ ការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដារអន្តរជាតិ។ ជាលទ្ធផល គណនីទោលរតនាគារ (TSA) ត្រូវបានរៀបចំ និងអនុវត្ត, មូលដ្ឋានគ្រឹះនៃគណនេយ្យហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានរៀបចំនិងកសាងឡើងតាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ស្តង់ដារគណនេយ្យនិងប្លង់គណនីថ្មី អង្គភាព

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី រួមនឹងការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលជា **"ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល"** ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការហិរញ្ញវត្ថុ និងពិនិត្យតាមដាន, កែលម្អចំណាត់ថ្នាក់ថវិកា វាយតម្លៃ ប្រមូលផ្តុំ និងផ្ទៀងផ្ទាត់ និងវិភាគសម្រាប់ការរៀបចំផែនការ ការរៀបចំថវិកា ការធ្វើសេចក្តីសម្រេចចិត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍។

- ដំណាក់កាលទី៣ **"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ ដែលចាប់ផ្តើមកែទម្រង់លើប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅកាន់ប្រព័ន្ធដែលផ្តោតលើលទ្ធផល សមិទ្ធកម្ម និងវិមជ្ឈការ។ ដំណាក់កាលនេះ ផ្តោតអាទិភាពយ៉ាងសំខាន់លើការអនុវត្តប្រព័ន្ធថវិកាកម្មវិធី ការបង្កើតអង្គភាពថវិកា និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលជាគន្លឹះក្នុងការផ្សារភ្ជាប់រវាងគោលនយោបាយវិស័យនិងអនុវិស័យរបស់ក្រសួង ស្ថាប័នទៅនឹងគោលនយោបាយនៃរាជរដ្ឋាភិបាល។ ក្នុងដំណាក់កាលនេះផងដែរ ឯកសារយុទ្ធសាស្ត្រគន្លឹះមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តក្នុងគោលបំណងកំណត់អាទិភាពកែទម្រង់ជាយុទ្ធសាស្ត្រទៅតាមការដ្ឋានកែទម្រង់សំខាន់នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន÷ យុទ្ធ-សាស្ត្រកៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, និងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥។
- ដំណាក់កាលទី៤ **"គណនេយ្យភាពសមិទ្ធកម្ម"** ត្រូវបានគ្រោងអនុវត្តចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧ ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានគោលដៅសំខាន់មួយគឺការកសាងបាននូវ **"វប្បធម៌សមិទ្ធកម្ម"**។ **"វប្បធម៌សមិទ្ធកម្ម"** មានលក្ខណៈទូលំទូលាយជាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយហេតុថាវិសាលភាពនេះពាក់ព័ន្ធផងដែរទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ការគ្រប់គ្រងមុខងារ និងការគ្រប់គ្រងធនធានមនុស្ស។

ខ. សមិទ្ធផលគន្លឹះលម្អិត

ទី១). ការអនុវត្តចំណូល÷ ចំណូលថវិការដ្ឋឆ្នាំ២០២១ សម្រេចបាន ២១ ៧៣៣ ៦៣៩ លានរៀល ឬស្មើនឹង ១០២,៥០% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណូលចរន្តសម្រេចបាន ២១ ៦៧៦ ៧៥៧ លានរៀល ឬស្មើ ១០២,៥០% នៃច្បាប់ហិរញ្ញវត្ថុ និងចំណូលមូលធនក្នុងប្រទេសសម្រេចបាន ៥៦ ៨៨២ លានរៀល ឬស្មើ ២៥,៧១% នៃច្បាប់ហិរញ្ញវត្ថុ។ ចំពោះចំណូលសារពើពន្ធថ្នាក់ជាតិសម្រេចបាន ១៨ ២៨៩ ៤៨១ លានរៀល ឬស្មើ ១០៤,៣៩% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះអគ្គនាយកដ្ឋានពន្ធដារ (**អ.ព.ដ.**) សម្រេចបាន ៩ ១៤៩ ១២៧

លានរៀល ឬស្មើ ១១៤,០២% នៃច្បាប់ហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) សម្រេចបាន ៩ ១៤០ ៣៥៤ លានរៀល ឬស្មើ ៩៦,២៥% នៃច្បាប់ហិរញ្ញវត្ថុ។ ការប្រមូលចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិសម្រេចបាន ១ ៦២០ ៥០២ លានរៀល ឬស្មើ ៧៤,១៣% នៃច្បាប់ហិរញ្ញវត្ថុ។ ចំណែកឯការអនុវត្តចំណូលថវិកាថ្នាក់រដ្ឋបាលរាជធានី ខេត្ត សម្រេចបាន ១ ៧៦៦ ៧៧៤ លានរៀល ឬស្មើនឹង ១៣៨,៣៩% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ ចំណូលសារពើពន្ធសម្រេចបាន ១ ៥៩៨ ៣០៣ លានរៀល ឬស្មើនឹង ១៥២,១៧% នៃច្បាប់ហិរញ្ញវត្ថុ និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ១៦៨ ៤៧២ លានរៀល ឬស្មើនឹង ៧៤,៤៤% នៃច្បាប់ហិរញ្ញវត្ថុ។

ទី២). ការអនុវត្តចំណាយ÷ ចំណាយថវិការដ្ឋក្នុងឆ្នាំ២០២១ សម្រេចបាន ២៦ ៤៧២ ៧៤៦ លានរៀល ឬស្មើ ៨៨,១៦% នៃច្បាប់ហិរញ្ញវត្ថុ (ប្រសិនបើធៀបនឹងថវិកាបន្ទាប់ពីធ្វើវិចារណកម្មចំណាយការអនុវត្តថវិកាឆ្នាំ២០២១ សម្រេចបាន ៩១,៣៣%)។ រីឯការចំណាយប្រចាំត្រីមាស មានភាពយឺតយ៉ាវជាងគោលដៅ ដែលបានកំណត់ក្នុងកម្មវិធីកែទម្រង់ (គោលដៅត្រីមាសទី ១=១៥%, ត្រីមាសទី ២=៤៥%, ត្រីមាសទី ៣=៦៧% និងត្រីមាសទី ៤=៩៦%)។ ចំណែកឯ ចំណាយថវិកាតាមប្រភេទសម្រេចបាន÷ (១) បៀវត្សសម្រេចបាន ៩៤,៧០% នៃច្បាប់ហិរញ្ញវត្ថុ, ទំនិញ/សេវាសម្រេចបាន ៨២,៧០%នៃច្បាប់ហិរញ្ញវត្ថុ (គោលដៅកំណត់មិនត្រូវតិចជាង ៩៨% សម្រាប់បៀវត្ស, ៩៥%សម្រាប់ទំនិញ/សេវា និង ៨៥% សម្រាប់មូលធន)។ ប៉ុន្តែបើធៀបនឹងថវិកាក្រោយវិចារណកម្មចំណាយសម្រេចបាន ១០៦,៦១%។ ចំណាយមូលធនសម្រេចបាន ៨០,៧០% នៃច្បាប់ហិរញ្ញវត្ថុ។

ទី៣). ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ÷ គណនីទោលរតនាគារជាតិ (Treasury Single Account-TSA) ត្រូវបានដាក់ឱ្យអនុវត្តនិងធ្វើឱ្យរាជរដ្ឋាភិបាលអាចតាមដានសមតុល្យសាច់ប្រាក់បានជាប្រចាំថ្ងៃ។ ចំណាត់ថ្នាក់ថវិកា និងប្លង់គណនី ត្រូវបានធ្វើបច្ចុប្បន្នភាពនិងជំរុញដាក់ឱ្យអនុវត្តពេញលេញ។ បំណុលកកស្ទះគិតត្រឹម ៦០ថ្ងៃ ត្រូវបានដោះស្រាយទាំងស្រុង រីឯរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំនិងមានអនុលោមភាពទៅតាមស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ ផ្អែកលើមូលដ្ឋានសាច់ប្រាក់ (IPSAS Cash Basis)។ បន្ថែមពីនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្តដល់គ្រប់ក្រសួង ស្ថាប័ន លើមុខងារស្នូលចំនួន ៦ រួមមាន (១)ម្យ៉ាងវិភាជន៍ថវិកា (២)ម្យ៉ាងគណនីត្រូវសង (៣)ម្យ៉ាងគណនីត្រូវទារ (៤)ម្យ៉ាងគ្រប់គ្រងសាច់ប្រាក់ (៥)ម្យ៉ាងការទិញ និង (៦)ម្យ៉ាងសៀវភៅធំ។ មុខងារពីរបន្ថែម គឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្ម កំពុងរៀបចំនិងដាក់ឱ្យសាកល្បងជាបន្តបន្ទាប់។

ទី៤). ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ÷ ក្របខ័ណ្ឌគតិយុត្តដ៏សំខាន់ចំនួន ២ ត្រូវបានរៀបចំឡើងជាលើកដំបូង គឺ១) ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលត្រូវបាន

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ដាក់ឱ្យអនុវត្តតាមរយៈព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ និង ២) ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានដាក់ឱ្យអនុវត្ត តាមរយៈព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០។ បន្ថែមពីនេះ ក្នុងគោលដៅទំនើបកម្មការងារខាងលើ, ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នប្រមូលចំណូល និងរដ្ឋបាលរាជធានី ខេត្ត រីឯប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋកម្រិត offline (SARMIS) ក៏ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ) ផងដែរ។

ទី៥). ការកែលម្អប្រព័ន្ធថវិកា÷ ថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តនៅតាមគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ គិតត្រឹមឆ្នាំ២០២១ អង្គភាពថវិកាមានចំនួនសរុប ៩២៦ ដែលក្នុងនោះរដ្ឋបាលកណ្តាលមានចំនួន ៣២៣ និងថ្នាក់មូលដ្ឋាន(មន្ទីរជំនាញរាជធានី ខេត្ត) ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្តាលអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៨៣ និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាសុទ្ធតែជាអាណាប័កផ្ទេរសិទ្ធិ។ ក្នុងការឈានទៅកាន់ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF), ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) និងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន (BSP) ត្រូវបានរៀបចំនិងផ្សារភ្ជាប់ជាបណ្តើរៗជាមួយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ បច្ចុប្បន្ន ក្របខ័ណ្ឌថវិការយៈពេលមធ្យមដែលកំណត់ពិដានថវិកាតាមវិស័យ និងក្រសួង ស្ថាប័ន ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី និងបានក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំថវិការបស់ក្រសួង ស្ថាប័ន។ លើសពីនេះ គោលការណ៍ណែនាំស្តីពីការតាមដាននិងវាយតម្លៃថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ១១៣ សហវ.ប្រក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២។ ក្នុងឆ្នាំ២០២៣ ខាងមុខ ក្រសួង ស្ថាប័នចំនួន ៧ នឹងសាកល្បងអនុវត្ត "ថវិកាសមិទ្ធកម្ម" រួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងអប់រំ យុវជន និងកីឬា, ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌។ កិច្ចព្រមព្រៀងសមិទ្ធកម្មនឹងត្រូវអនុវត្ត ៣ កម្រិត÷ ទី១) រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងក្រសួង ស្ថាប័នសាមី, ទី២) រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ននឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង ស្ថាប័នសាមី និងទី៣) រវាងអ្នកគ្រប់គ្រងកម្មវិធីនឹងប្រធានអង្គភាពថវិកា។

ទី៦). ការពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈ÷ យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានដាក់ឱ្យអនុវត្ត ក្នុងគោលបំណងបង្កើតឱ្យបានន្ធរ្ប ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ:រួមមួយរបស់ជាតិ សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងពង្រឹង

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

សមត្ថភាពប្រកួតប្រជែង។ យុទ្ធសាស្ត្រនេះមានវិសាលភាពគ្របដណ្ដប់លើគ្រប់គម្រោងវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន រួមមាន÷ ថវិកាជាតិ, ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគ ឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជននិងនៅគ្រប់កម្រិតរដ្ឋបាល ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់-ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល។ ជាលទ្ធផល ក្របខ័ណ្ឌគតិយុត្តគន្លឹះចំនួន ២ ត្រូវបានរៀបចំ រួមមាន÷ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលត្រូវឱ្យដាក់ឱ្យប្រើប្រាស់តាមរយៈព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១។

ទី៧). ការគ្រប់គ្រងបំណុលសាធារណៈ÷ ស្ថានភាពនៃបំណុលសាធារណៈកម្ពុជាត្រូវបានវាយតម្លៃថាមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**" ដែលក្នុងរយៈពេលបួនឆ្នាំចុងក្រោយ ពិជានៃការខ្ចីប្រចាំឆ្នាំត្រូវបានរក្សានិងអនុវត្តទៅតាមគោលការណ៍គន្លឹះទាំង ៥ ដូចមានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣។ មូលបត្ររដ្ឋត្រូវបានបោះផ្សាយជាលើកដំបូងក្នុងឆ្នាំ២០២២ ក្នុងទំហំ ៣០០ លានដុល្លារអាម៉េរិក ក្នុងគោលបំណងកៀរគរហិរញ្ញប្បទានបន្ថែមដើម្បីគាំទ្រគម្រោងវិនិយោគសាធារណៈ។

ទី៨). ការបង្កើនប្រភពធនធានថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ÷ ការបង្កើននេះ ត្រូវបានអនុវត្តតាមរយៈយន្តការសំខាន់ៗដូចជា ការបង្កើនអត្រាវិភាជន៍ប្រចាំឆ្នាំដល់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់, យន្តការបែងចែកចំណូលសារពើពន្ធរបស់រាជធានី ខេត្ត ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់, ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទី៩). មុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច÷ បទដ្ឋានគតិយុត្តគន្លឹះមួយត្រូវបានរៀបចំឡើងដើម្បីបញ្ជៀសការអនុវត្តស្ទួនគ្នានៃមុខងារទាំងពីរ ពោលគឺអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច។ លើសពីនេះ អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដា ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ កំពុងត្រូវបានរៀបចំកែសម្រួល ស្របតាមទិសដៅនៃការកែទម្រង់ប្រព័ន្ធ ថវិកា។ នៅថ្នាក់ក្រោមជាតិ អង្គភាពសវនកម្មផ្ទៃក្នុងនឹងត្រូវបង្កើតឡើងនៅក្នុងរដ្ឋបាលរាជធានី ខេត្ត អនុលោមតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥។

សមិទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកែប្រែជាបណ្ដើរៗនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាទាំងមូលស្របតាមស្តង់ដារអន្តរជាតិ។ ស្ថានភាពកង្វះសាច់ប្រាក់ ត្រូវបានដោះស្រាយទាំងស្រុង

ដែលធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពសន្សំប្រាក់បម្រុង ដើម្បីអនុវត្តវិធានការគោលនយោបាយបន្ទាន់និងតាមការចាំបាច់នានា។ ជាក់ស្តែង ការតម្លើងបៀវត្សដល់មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ត្រូវបានផ្តល់ជូនជារៀងរាល់ឆ្នាំក្នុងអត្រា ៧ ភាគរយ រហូតដល់ឆ្នាំ២០១៩ មុននឹងការមកដល់នៃវិបត្តិកូវីដ-១៩។ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់កូវីដ-១៩ វិធានការពង្រឹងភាពស៊ាំក្នុងសហគមន៍ត្រូវបានអនុវត្តដោយការបញ្ជាទិញនិងប្រើប្រាស់វ៉ាក់សាំងដើម្បីការពារអាយុជីវិតប្រជាជនកម្ពុជា រាជរដ្ឋាភិបាលក៏មានលទ្ធភាពក្នុងអនុវត្តវិធានការអន្តរាគមន៍រក្សាលំនឹងជីវភាពប្រជាជននិងវិធានការរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជនផងដែរ តាមរយៈការដាក់ឱ្យអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ និងការអនុគ្រោះផ្នែកពន្ធដល់ប្រតិបត្តិករក្នុងវិស័យទេសចរណ៍និងអាកាសចរណ៍ដល់ចុងឆ្នាំ២០២២។

គ. បញ្ហាប្រឈម

ទោះបីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានវឌ្ឍនភាពនិងសមិទ្ធផលដូចបានគូសបញ្ជាក់ខាងលើក្តី ចំណុចប្រឈមមួយចំនួនទាមទារការបន្តយកចិត្តទុកដាក់ដោះស្រាយ ដើម្បីសម្រេចជាសារវន្តនូវមូលដ្ឋានគន្លឹះឈានឆ្ពោះទៅការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មប្រកបដោយជោគជ័យ ដែលមានដូចតទៅ÷

ទី១). ការកៀរគរចំណូលទទួលរងផលប៉ះពាល់ដោយការរីករាលដាលជំងឺកូវីដ-១៩

ទី២). ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ទោះបីជាសម្រេចបានជាសារ-វន្ត ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ប៉ុន្តែនៅមិនទាន់អាចផលិតបាននូវរបាយការណ៍ឱ្យបានគ្រប់ជ្រុងជ្រោយ និង មិនទាន់បានធ្វើស្វ័យប្រវត្តិកម្មលើការអនុវត្តថវិកាពេញលេញនៅឡើយ មានន័យថា ការអនុវត្តថវិកានៅត្រូវប្រើក្រដាសស្មាមផងនិងប្រើប្រព័ន្ធ FMIS ផង ហើយនីតិវិធីមួយចំនួនមានលក្ខណៈជាន់គ្នា

ទី៣). ការអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកាពិតមែនតែត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ ប៉ុន្តែគុណភាពនៃកម្មវិធីចាំបាច់ត្រូវកែសម្រួល ទាំងខ្លឹមសារ ទាំងរចនាសម្ព័ន្ធ និងទាំងសមិទ្ធកម្ម។ លើសពីនេះ ការរៀបចំកម្មវិធីរបស់ក្រសួង ស្ថាប័នមួយចំនួននៅចំណុះទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ដែលធ្វើឱ្យមានការលំបាកខ្លះក្នុងការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយ ក៏ដូចជាការផ្សារភ្ជាប់កម្មវិធីទៅនឹងការអនុវត្តជាក់ស្តែង។ ម្យ៉ាងទៀត ក្រសួង ស្ថាប័នមួយចំនួនក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ក៏មានតិចតួចដែរ

ទី៤). នីតិវិធីនៃការអនុវត្តថវិកាត្រូវបានពន្លឿនច្រើន ប៉ុន្តែនៅមិនទាន់អាចធានាបាននូវភាពឆាប់រហ័ស ភាពត្រឹមត្រូវ និងភាពអាចប៉ាន់ប្រមាណបាន តាមការរំពឹងទុកនៅឡើយ។ ការងារនេះមិនមែនជាការងារដាច់ដោយឡែករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះទេ ប៉ុន្តែក៏ជាការងារផ្ទាល់របស់ក្រសួង ស្ថាប័នផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលមួយចំនួនហើយលើបញ្ហានេះ ក៏ប៉ុន្តែក្រសួង ស្ថាប័នសាមី

ក៏ត្រូវខិតខំកាត់បន្ថយនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាព និងតម្លាភាពផ្ទៃក្នុងរបស់ខ្លួនផងដែរ

ទី៥). ប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតែជាបញ្ហាប្រឈមដ៏សំខាន់ ដែលជាចំណែកមួយនៃការគ្រប់គ្រងធនធានសាធារណៈ។ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ទាំងជាទ្រព្យហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុ ត្រូវការនូវការយកចិត្តទុកដាក់ច្រើនថែមទៀត ខណៈដែលផ្នែកផ្សេងៗនៃការកែទម្រង់កំពុងមានវឌ្ឍនភាពល្អទៅមុខ

ទី៦). ខណៈដែលការរៀបចំថវិកាត្រូវបានធ្វើឡើងតាមកម្មវិធី ការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀត តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្ត ដែលក្នុងនោះថ្នាក់ដឹកនាំ ឬអ្នកគ្រប់គ្រង គឺទទួលខុសត្រូវជាសំខាន់លើសមិទ្ធកម្ម ឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត ចំណែកការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃក្រសួង ស្ថាប័ន

ទី៧). ភាពចាំបាច់ក្នុងការបន្តការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រនិងឆ្លើយតបទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេសឆ្ពោះទៅ "**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**"។

១.២.១.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក. សមិទ្ធផល

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗ ដូចខាងក្រោម÷

➢ **ការដឹកនាំការងារកំណែទម្រង់**

កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ឬហៅម្យ៉ាងទៀតថា កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជា-ធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដែលមានលក្ខណៈអន្តរស្ថាប័នប្រកបដោយភាពសាំញ៉ាំនិងស្មុគស្មាញ។ ក្នុងន័យនេះ ដើម្បីធានាដល់ការដឹកនាំសម្របសម្រួលកំណែទម្រង់ឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដើម្បីធ្វើជាស្ថាប័នថ្នាក់ជាតិក្នុងការដឹកនាំនិងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះស្របតាមច្បាប់រៀបចំអង្គការ។ ការវិវត្តនៃកំណែទម្រង់នេះពីមួយដំណាក់កាលទៅមួយដំណាក់កាលបានតម្រូវជាចាំបាច់ឱ្យមានការពិនិត្យនិងកែសម្រួលស្ថាប័នដឹកនាំការងារកំណែទម្រង់នេះឱ្យកាន់តែមានភាពរឹងមាំនិងការលើកកម្ពស់ភាពជាម្ចាស់ក្នុងការដឹកនាំ ការសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកំណែទម្រង់នេះឱ្យកាន់តែមានប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាល រួមមាន÷

- ការកែសម្រួលសមាសភាពអនុប្រធាន និងការបំពេញបន្ថែមនូវសមាសភាពសមាជិកមួយចំនួននៃ

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា "**គ.ជ.អ.ប**." តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥០៥ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ ស្តីពីការកែសម្រួលសមាសភាពនៃ **គ.ជ.អ.ប**.

- ការកែសម្រួលសមាសភាពថ្នាក់ដឹកនាំនៃអនុគណៈកម្មាធិការទាំង៤របស់ **គ.ជ.អ.ប**. និងការបង្កើតអនុគណៈកម្មាធិការរបស់ **គ.ជ.អ.ប**. ថ្មីមួយបន្ថែមទៀត តាមរយៈអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការនានារបស់ **គ.ជ.អ.ប**.
- ការរៀបចំបង្កើតនិងការប្រព្រឹត្តទៅនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហ-មជ្ឈការនៅតាមក្រសួងពាក់ព័ន្ធនិងនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ស្របតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០០២/ស.ន.ណ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ
- ការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ សម្រាប់អនុវត្តរយៈពេល១០ឆ្នាំ (២០២១-២០៣០) ដែលបានឯកភាពដោយរាជរដ្ឋាភិបាល នាថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ និងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជ-ណាចក្រកម្ពុជា ដោយមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា ដែលមានអ្នកចូលរួមដោយផ្ទាល់ប្រមាណជាង ៤០០នាក់ និងតាមរយៈប្រព័ន្ធបញ្ជូនសម្លេង និងរូបភាព Zoom ប្រមាណជាង៧០០០នាក់
- ការរៀបចំនិងការដាក់ឱ្យអនុវត្តផែនការអនុវត្តរយៈពេល ៥ឆ្នាំ ដំណាក់កាលទី១ (២០២១-២០២៥) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២
- ការដឹកនាំ ការសម្របសម្រួល និងការគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.អ.ប**. ស្របតាមសកម្មភាពជាអាទិភាពដែលបានកំណត់ក្នុងកម្មវិធីជាតិដំណាក់-កាលទី១ និងកម្មវិធីជាតិដំណាក់កាលទី២ ដោយមានការចូលរួមអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិចំនួន២១ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស
- ការសម្របសម្រួលនិងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលក្នុងការចូលរួមរៀបចំនិងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំគម្រោងដាច់ដោយឡែកៗនានាចំនួនប្រមាណជាង ១០គម្រោង និងថវិកាសរុបប្រមាណពី **៤០លាន** ទៅ **៥០លានដុល្លារ** ក្នុងមួយឆ្នាំ។

➢ ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ

ផ្អែកតាមច្បាប់រៀបចំអង្គការ ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់រិមជ្ឈការនិងវិសហមជ្ឈការបានតម្រូវឱ្យមានការពិនិត្យនិងកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងគោលការណ៍នៃរដ្ឋបាលឯកភាពនៅគ្រប់កម្រិត និងប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ពាក់ព័ន្ធនឹងកិច្ចការនេះ នាពេលកន្លងមក រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតត្រូវពិនិត្យនិងកែសម្រួលឱ្យស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជា-ធិបតេយ្យ ក្នុងនោះរួមមានការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោត, ការរៀបចំនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធគ្រប់គ្រង, ប្រព័ន្ធកសាងផែនការ, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ, នីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលធានាដល់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ឥម្ពាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាលនេះរួមមាន÷

- ការកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ដោយបានធ្វើសមាហរណ-កម្មមន្ទីរសុខាភិបាល មន្ទីរពេទ្យ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងមណ្ឌលថែទាំកុមារដែលជាអង្គភាពខ្សែបណ្តោយរបស់ក្រសួងសុខាភិបាលចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តនៅទូទាំងប្រទេស តាមរយៈអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រងនិងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃនិងក្រសួងសុខាភិបាល លេខ១៥២ សនក. ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត
- ការកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌដោយបានធ្វើសមាហរណកម្ម ការិយាល័យជំនាញនានារបស់ក្រសួង ស្ថាប័ននៅថ្នាក់ស្រុកចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ ១៨២ អនក្រ.បក ស្តីពីមុខងារនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង, អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពីមុខងារនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ, អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្តីពីមុខងារនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩។ ការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ គឺដើម្បីធានាឱ្យរដ្ឋបាលទាំងនេះមានប្រព័ន្ធគ្រប់គ្រងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលធានាដល់ការដឹកនាំ សម្របសម្រួលលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹង

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

តម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព

- នៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលឃុំ សង្កាត់ ក៏បានបង្កើតឡើងនូវគណៈកម្មាធិការនានា ដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចសហការជាមួយស្ថាប័នជំនាញនិងអង្គការសង្គមស៊ីវិលលើការជំរុញ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសង្គមជូនប្រជាពលរដ្ឋ រួមមានដូចជា គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការទ្រទ្រង់សាលារៀន គណៈកម្មាធិការការងារគណនេយ្យភាពសង្គមជាដើម។

➢ **ការរៀបចំប្រព័ន្ធគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ បានរៀបចំនិងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនតាំងពីដំណាក់កាលនៃការប្រឡងជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្តូរ ការដាក់ពិន័យ ការបណ្តេញចេញ និងការដាក់ឱ្យចូលនិវត្តន៍។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាលនេះ រួមមាន÷

- ផ្អែកតាមការវិវត្តនៃការផ្ទេរមុខងារពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានសម្រេចផ្ទេរបុគ្គលិកចំនួនប្រមាណជាង ៤០ ០០០នាក់ ទៅស្ថិតក្រោមការគ្រប់គ្រងនិងចាត់ចែងដោយផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះបុគ្គលិកក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួនជាង ៧ ០០០នាក់ បុគ្គលិកក្របខ័ណ្ឌសុខាភិបាលចំនួនជាង ២០ ០០០នាក់ បុគ្គលិកក្របខ័ណ្ឌអប់រំចំនួនប្រមាណជាង ៦ ០០០នាក់ និងបុគ្គលិកក្របខ័ណ្ឌជំនាញបច្ចេកទេសពីក្រសួង ស្ថាប័នតាមវិស័យនានាចំនួនប្រមាណជិត ១០ ០០០នាក់
- សេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានពិនិត្យកែសម្រួល និងដាក់ឱ្យអនុវត្តផងដែរ
- ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានរៀបចំជាប្រចាំអំពីក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអំពីក្របខ័ណ្ឌនៃការអនុវត្តការងារតាមរយៈវគ្គបណ្តុះបណ្តាលរយៈពេលខ្លីៗជាបន្តបន្ទាប់ដល់សមាជិកក្រុមប្រឹក្សានិងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំបង្កើតនិងដាក់ឱ្យដំណើរការនូវសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីផ្តល់សេវាអភិវឌ្ឍសមត្ថ-ភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំពោះរដ្ឋបាលឃុំ សង្កាត់ រាជរដ្ឋាភិបាល តាមរយៈប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និង **កសហវ.** បានអនុញ្ញាតឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗជ្រើសរើសនូវបុគ្គលិកជំនួយការហិរញ្ញវត្ថុ១រូប

ដើម្បីជួយរដ្ឋបាលឃុំ សង្កាត់លើការងារហិរញ្ញវត្ថុ ក្នុងខណៈដែលថវិការបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានបង្កើនឡើងជារៀងរាល់ឆ្នាំ។

➢ **ការផ្ទេរមុខងារនិងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់និងជាអាទិភាពនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលត្រូវរៀបចំនិងអនុវត្តជាជំហានៗតាមដំណាក់កាលនីមួយៗជាបន្តបន្ទាប់ក្នុងបំណងបង្ហិតការធ្វើសេចក្ដីសម្រេចលើការផ្ដល់សេវាសាធារណៈឱ្យទៅកៀកជិតប្រជាពលរដ្ឋ ដើម្បីធានាដល់ការឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង និងមានលក្ខណៈដោយឡែកៗពីគ្នានៅតាមមូលដ្ឋាននីមួយៗ បានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ឥម្ពាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាលរួមមាន÷

- មុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេស ដែលមុខងារទាំងនេះពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាអាទិ៍មុខងារក្នុងវិស័យអប់រំ កសិកម្ម អនាម័យ បរិស្ថាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូច ដូចជាផ្លូវជនបទ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ប្រព័ន្ធធារាសាស្ត្រ សាលារៀនជាដើម
- មុខងារក្នុងវិស័យសង្គមកិច្ចនិងសុខាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ និងការផ្ដល់សេវាព្យាបាលនិងថែទាំសុខភាពសាធារណៈ ក៏ត្រូវបានផ្ទេរទៅស្ថិតក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស
- មុខងារដែលបានផ្ទេរទាំងនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលទ្ធភាពនិងសមត្ថភាពក្នុងការផ្ដល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ ព្រមទាំងអាចដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានបានឆាប់រហ័សនិងទាន់ពេលវេលា ជាពិសេសការគ្រប់គ្រងនិងការចាត់វិធានការទប់ស្កាត់ ថែទាំ និងព្យាបាលអ្នកជំងឺក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងរយៈពេលជាង ២ឆ្នាំកន្លងមកនេះ និងការជួយសង្គ្រោះប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម
- យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបន្តពង្រឹងនិងពង្រីកឱ្យដំណើរការយ៉ាងសកម្មនៅទូទាំងប្រទេស ដោយបានបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់នានា ដែលរួមមានសេវារដ្ឋបាលប្រមាណជាង ៨០០ប្រភេទ
- ការិយាល័យប្រជាពលរដ្ឋក៏ត្រូវបានពង្រឹងនិងពង្រីកឱ្យមានដំណើរការនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ការិយាល័យប្រជាពលរដ្ឋនេះដើរតួនាទីជាយន្តការអព្យាក្រឹតមួយក្នុងការប្រមូល ទទួល និងសម្រុះសម្រួលបណ្ដឹងតវ៉ានានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការ

ឯកសារមន្ទ្រីសាធារណៈ | https://t.me/oa_channel

បំពេញការងារ និងការផ្តល់សេវានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាព

- ការងារគណនេយ្យភាពសង្គមក៏ត្រូវបានបន្តរៀបចំនិងអនុវត្តនៅតាមរដ្ឋបាលឃុំ សង្កាត់ចំនួន ១៤០០ នៅក្នុង ១៧០ ក្រុង ស្រុក។ ការអនុវត្តការងារគណនេយ្យភាពសង្គមនេះ គឺក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋឱ្យទទួលបានន្ធវ៉ាត់តិមានសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថវិការបស់រដ្ឋបាលឃុំ សង្កាត់, បែបបទនិងនីតិវិធីនៃការផ្តល់សេវានៅតាមសាលារៀននិងមណ្ឌលសុខភាព ព្រមទាំងជំរុញឱ្យប្រជាពលរដ្ឋចូលរួមតាមដានត្រួតពិនិត្យនិងផ្តល់យោបល់កែលម្អលើការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងលើការផ្តល់សេវានៅតាមសាលារៀននិងមណ្ឌលសុខ-ភាពទាំងនោះផងដែរ
- ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅនិងមុខងារជាជម្រើសរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោម-ជាតិ (រាជធានី ខេត្ត ក្រុង និងឃុំ សង្កាត់) បានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនិងអនុវត្តគម្រោងសេវាសង្គមប្រមាណ**ជាង ២000**គម្រោងក្នុងមួយឆ្នាំ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់-ស្តែងនៅតាមមូលដ្ឋាន ដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

➢ **វិមជ្ឈការហិរញ្ញវត្ថុនិងប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- វិមជ្ឈការហិរញ្ញវត្ថុ

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនាពេលកន្លងមក ត្រូវបានបង្កើតនិងដាក់ឱ្យប្រតិបត្តិការន្ធ្ធ្ធ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

នៅឆ្នាំ២០២៣

- ការបង្កើតចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាល ក្រុង ស្រុក ក្នុងអត្រា ៤% ក្នុងឆ្នាំ២០១៨ទៅដល់ឆ្នាំ២០២២ និងទៅឱ្យរដ្ឋបាលឃុំ សង្កាត់ដែលមានការកើនឡើងពីអត្រា១% ក្នុងឆ្នាំ២០១៨ ទៅដល់អត្រា ៥% ក្នុងឆ្នាំ២០២២
- ការបង្កើតប្រភពចំណូលនៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលកម្រៃសេវារដ្ឋបាលដែលផ្តល់តាមយន្តការច្រកចេញចូលតែមួយនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ
- ការបង្កើតនិងដាក់ឱ្យដំណើរការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក សម្រាប់ការអនុវត្តគម្រោងអភិវឌ្ឍចាំបាច់មួយចំនួនដែលរដ្ឋបាលក្រុង ស្រុក ពុំអាចមានលទ្ធភាពក្នុងការប្រើប្រាស់ថវិកាដែលបានពីការវិភាជនៃមូលនិធិក្រុង ស្រុក
- ជារួម ក្នុងក្របខ័ណ្ឌនៃវិមជ្ឈការហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានបង្កើនការផ្ទេរថវិការដ្ឋជារៀងរាល់ឆ្នាំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរហូតមកទល់ឆ្នាំ២០២២នេះ ថវិកាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសរុបមានចំនួនជាង ៥០០០លានដុល្លារអាមេរិក សម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ក្នុងនោះធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះរួមមានដូចខាងក្រោម÷

រដ្ឋបាលថ្នាក់ក្រោមជាតិ	ធនធានហិរញ្ញវត្ថុ (គិតជាលានដុល្លារ)					
	២០១៨	២០១៩	២០២០	២០២១	២០២២	**សរុប**
រាជធានី ខេត្ត	២៦៩	៣៦៥	៥៦៣	៥៤៤	៧០៦	**២៤៤៧**
ក្រុង ស្រុក	៤០	៤៩	៦១	១២១	១៤០	**៤១១**
ឃុំ សង្កាត់	១០៧	១២៩	១៩៨	១៧៥	២០៩	**៨១៨**
សរុប	**៤១៦**	**៥៤៣**	**៨២២**	**៨៤០**	**១០៥៥**	**៣៦៧៦**

- ប្រព័ន្ធកសាងផែនការ

ប្រព័ន្ធកសាងផែនការគឺជាប្រព័ន្ធអភិបាលកិច្ចដ៏សំខាន់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ធ្វើសេចក្តីសម្រេចតាមបែបប្រជាធិបតេយ្យរបស់ក្រុមប្រឹក្សាក្នុងការកំណត់ចក្ខុវិស័យ គោលដៅ ក្របខ័ណ្ឌអភិវឌ្ឍន៍ ដែលក្រុមប្រឹក្សាចង់ឱ្យសម្រេចបាននៅក្នុងអាណត្តិរបស់ខ្លួន។ ច្បាប់រៀបចំអង្គការបានតម្រូវឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានកាតព្វកិច្ចក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំ

រំកិល ដើម្បីធ្វើជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនិងការជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាននីមួយៗ។

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនាពេលកន្លងមក ដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ ដាក់ឱ្យអនុវត្ត និងកែលម្អជាបណ្តើរៗ ដើម្បីធានាឱ្យមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈផ្សេងៗគ្នានៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិផង ព្រមទាំងឱ្យមានប្រសិទ្ធភាពក្នុងការបែងចែកនិងការប្រើប្រាស់ធនធានសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកែលម្អនៅក្នុងអាណត្តិទី៦របស់រាជរដ្ឋាភិបាលនេះរួមមាន÷

- ការកែសម្រួលប្រតិទិននៃការរៀបចំផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានសង្គតិភាពជាមួយប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងន័យធានាឱ្យការវិភាជនិងការប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាននីមួយៗកាន់តែចំទិសដៅ ទាន់ពេលវេលា និងមានប្រសិទ្ធភាព
- ទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យជាមូលដ្ឋានបម្រើឱ្យការវិភាគ ការកំណត់បញ្ហា និងការកំណត់តម្រូវការអភិវឌ្ឍតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីធានាដល់ការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានសុក្រឹតភាពក្នុងការឆ្លើយតបទៅនឹងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ
- ការរៀបចំនិងដាក់ឱ្យអនុវត្តនូវឧបករណ៍នានាសម្រាប់ការវិភាគ និងការបញ្ជាបតម្រូវការសមភាពយេនឌ័រ តម្រូវការរបស់ក្រុមជនងាយរងគ្រោះ តម្រូវការនៃភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ និងបញ្ហាសង្គមនានាទៅក្នុងប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយបរិយាប័ន្ន សមធម៌សង្គម និងប្រកបដោយនិរន្តរភាព។

ខ. បញ្ហាប្រឈម

ទោះបីការរៀបចំនិងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងរយៈពេលកន្លងមកនេះ បានបង្កើតនូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើនពាក់ព័ន្ធនឹងការកែលម្អគុណភាពសេវាសាធារណៈនិងការជំរុញការអភិវឌ្ឍនៅតាមមូលដ្ឋានដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនិងដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

នីមួយៗ ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តជំរុញនិងដោះស្រាយ។ បញ្ហាប្រឈមគន្លឹះទាំងនោះរួមមាន÷

- ការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានាទាំងស្ថាប័នសាធារណៈ សង្គមស៊ីវិល និងសាធារណជនអំពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនេះនៅមានកម្រិត
- ទោះបីរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវបានរៀបចំឡើងវិញ និងកែសម្រួលជាបណ្តើរៗនាពេលកន្លងមកក៏ដោយ ក៏នៅមិនទាន់មានលក្ខណៈសមស្របទាំងស្រុងទៅតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅឡើយ ដែលចាំបាច់ត្រូវមានការបន្តពិនិត្យនិងកែសម្រួលឡើងវិញបន្ថែម
- ការបែងចែកមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវរវាងថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ក្រោមជាតិនិងថ្នាក់ក្រោមជាតិនៅមិនទាន់មានភាពច្បាស់លាស់និងសមស្របនៅឡើយ ដែលតម្រូវឱ្យមានការពិនិត្យនិងការបែងចែកមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវឡើងវិញ
- ការផ្ទេរបុគ្គលិក ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានលក្ខណៈសមស្របតាមចំនួននិងទំហំមុខងារដែលបានផ្ទេរ ព្រមទាំងពុំទាន់មានដំណើរការដោយរលូននៅឡើយ ដែលប្រការនេះក៏ត្រូវមានការពិនិត្យនិងកែលម្អបន្ថែមទៀត
- ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់បំពេញតួនាទីពេញលេញជាអង្គធ្វើសេចក្តីសម្រេចចិត្តលើផែនការនិងថវិការបស់ខ្លួន ព្រមទាំងបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅឡើយ។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនិងការបង្កើតការិយាល័យប្រជាពលរដ្ឋក៏ដោយ ក៏ប្រជាពលរដ្ឋនៅមិនទាន់យល់ដឹងច្បាស់លាស់អំពីសិទ្ធិរបស់ខ្លួនក្នុងការជំរុញឱ្យក្រុម-ប្រឹក្សាមានគណនេយ្យភាពចំពោះខ្លួននៅឡើយ
- ទោះបីប្រព័ន្ធគ្រប់គ្រងបុគ្គលិកនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តជាបណ្តើរៗក៏ដោយ ក៏ការអនុវត្តជាក់ស្តែងនៅពុំទាន់មានប្រសិទ្ធ-ភាពនិងអនុវត្តពេញលេញតាមប្រព័ន្ធនៅឡើយ ហើយសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោម-ជាតិក៏នៅមានកម្រិត
- ការរៀបចំប្រព័ន្ធអភិបាលកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម នៅពុំទាន់បានបញ្ជ្រាបនិងអនុវត្តបានពេញលេញនៅក្នុងការបំពេញការងារជាទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ ដែលប្រការនេះចាំបាច់ត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយឱ្យកាន់តែមានប្រសិទ្ធភាព។

១.២.១.៣. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ

ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាបន្តកិច្ចប្រឹងប្រែងក្នុងការកសាងរដ្ឋបាលសាធារណៈ ដែលមានលក្ខណៈ ខ្លាំង ស្អាតស្អំ ឆ្លាត និងផ្តោតលើប្រជាជន ជាស្នូល។ ក្នុងន័យនេះ ការបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ចគឺជាលក្ខខណ្ឌចាំបាច់ដែលត្រូវអនុវត្តតាមរយៈការដ្ឋានកែទម្រង់និងកម្មវិធីទាំងឡាយរបស់រាជរដ្ឋាភិបាល ពិសេសការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ជាដើម។ នៅក្នុងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥ ត្រូវបានរៀបចំឡើងជាដំណាក់កាលៗ ដែលផ្តោតជាអាទិភាពលើការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ ដែលសកម្មភាពកែទម្រង់ទាំងអស់នេះមានសង្គតិភាព ភាពប្រទាក់ក្រឡា និងការគាំទ្រគ្នាទៅវិញទៅមកជាមួយនឹងការដ្ឋានកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល។

ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ សម្រេចបាននូវសមិទ្ធផលធំៗគួរឱ្យកត់សម្គាល់ ដូចខាងក្រោម÷

ក. ការកែលម្អរចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

បានកែសម្រួលឡើងវិញនូវការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់ **គ.ក.ร.**, អនុគណៈកម្មាធិការនានារបស់ **គ.ក.ร.** និងលេខាធិការដ្ឋាន **គ.ក.ร.** ព្រមទាំងការកែសម្រួលសមាសភាព **គ.ក.ร.** និងលេខាធិការដ្ឋាន **គ.ក.ร.**។

ខ. ការរៀបចំកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥

- បានរៀបចំនិងដាក់ចេញនូវឯកសារទស្សនាទានស្តីពីការរៀបចំកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ ដោយទទួលបានការយល់ព្រមពីរាជរដ្ឋាភិបាល។ ផ្អែកលើឯកសារទស្សនាទាននេះ សេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥ ក៏ត្រូវបានរៀបចំនិងដាក់ឆ្លងការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ ជាមួយនឹងការកំណត់នូវចក្ខុវិស័យ ដើម្បីធានាឱ្យបាននូវការកសាងរដ្ឋបាលសាធារណៈមួយដែលខ្លាំង ស្អាតស្អំ ឆ្លាត និងផ្តោតលើប្រជាជនជាស្នូល និងដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ រួមមានការកែទម្រង់និងការពង្រឹងប្រសិទ្ធភាពស្ថាប័ន ការលើកកម្ពស់ប្រសិទ្ធភាពនៃសមិទ្ធកម្មស្ថាប័នសាធារណៈ និងគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ។
- បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារគោលការណ៍ណែនាំស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ។

គ. ការកែទម្រង់បៀវត្ស ការបើកបៀវត្សតាមប្រព័ន្ធធនាគារ និងការបង្កើនរបបសន្តិសុខសង្គម សម្រាប់អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន

- បានដំឡើងប្រាក់បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិកម្ពុជា យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីសង្ឆ ប្រាក់បំណាច់ចៅក្រមព្រះរាជអាជ្ញា ជំនួយការនិងទីប្រឹក្សាដែលមានឋានៈស្មើ និងមន្ត្រីទូតដែលទៅបំពេញបេសកកម្មនៅបរទេស និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនដល់ប្រធាននិងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជំទប់ទី១និងទី២ ចៅសង្កាត់រងទី១និងទី២ សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ និងមេភូមិ អនុប្រធានភូមិ ជំនួយការភូមិ និងមន្ត្រីជាប់កិច្ចសន្យា ក្នុងក្របខ័ណ្ឌលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ ការលើកកម្ពស់ជីវភាពរបស់មន្ត្រី និងការបង្កើនប្រសិទ្ធភាពការងារ
- បានរៀបចំបើកប្រាក់បៀវត្សជូនមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគាររយៈពេលពីរសប្តាហ៍ម្តង
- បានដំឡើងប្រាក់សោធនប្រចាំខែរបស់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយផ្តោតការយកចិត្តទុកដាក់លើប្រាក់សោធនកម្រិតអប្បបរមា ការកាត់បន្ថយគម្លាតរវាងប្រាក់សោធនអប្បបរមានិងអតិបរមា ការធានាសង្គតិភាពរវាងប្រាក់សោធនរបស់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន។

ឃ. ការលើកកម្ពស់គុណភាពសេវាសាធារណៈ

- បានរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីលេខ១ អង្គភាពផ្តល់សេវាសាធារណៈគំរូ ឆ្នាំ២០១៩ សម្រាប់វិស័យអប់រំ និងសុខាភិបាល
- បានរៀបចំសេចក្តីណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់អនុវិទ្យាល័យនិងសាលាបឋមសិក្សាគំរូ និងសេចក្តីណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់មណ្ឌលសុខ-ភាពគំរូ
- បានបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងទទួលស្គាល់អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ដល់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូ នាយក នាយិកា អនុវិទ្យាល័យ សាលាបឋមសិក្សា និងប្រធានមណ្ឌលសុខភាពទូទាំងប្រទេស
- បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ
- បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារណែនាំស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ
- បាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការវាយតម្លៃនិងទទួលស្គាល់គម្រោងនវានុវត្តន៍ក្នុង

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

រដ្ឋបាលសាធារណៈ។

ង. ការលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន

- បានរៀបចំនិងដាក់ឱ្យអនុវត្តសេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក
- បាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យនិងឯកសារសេចក្តីណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារណែនាំនិងអនុក្រឹត្យស្តីពីការរៀបចំការពិពណ៌នាមុខតំណែង
- បាននិងកំពុងរៀបចំបោះពុម្ពឡើងវិញនូវអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ដែលមានលក្ខណៈជាស្មាតកាត (Smart Card)
- បាននិងកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យានិងតារាងទូទាត់បៀវត្សថ្មី
- បាននិងកំពុងរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពលើប្រធានបទ ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យមុខងារសាធារណៈសម្រាប់មន្ត្រីរាជការកម្រិតគ្រប់គ្រងនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំអធិការកិច្ចលើវិស័យមុខងារសាធារណៈ និងកំណត់ទម្រង់របាយការណ៍អធិការកិច្ចវិស័យមុខងារសាធារណៈ។

ច. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលធំៗខាងលើ ការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម÷

- សមត្ថភាពស្ថាប័ននិងធនធានមនុស្សរបស់ក្រសួង ស្ថាប័ន នៅមិនទាន់ឆ្លើយតបបានពេញលេញទៅនឹងតម្រូវការនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ការកសាងសមត្ថភាពមន្ត្រីក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល មិនទាន់មានលក្ខណៈជាប្រព័ន្ធនិងប្រសិទ្ធ-ភាពខ្ពស់ ឆ្លើយតបទៅនឹងការវិវឌ្ឍរបស់រដ្ឋបាលសាធារណៈ
- ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនិងការលើកកម្ពស់គុណភាពសេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅមានកម្រិតនៅឡើយ
- ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមន្ត្រីរាជការស៊ីវិលបច្ចុប្បន្នមិនទាន់មានសមត្ថភាពពេញលេញនិងសមស្រប ឆ្លើយតបទៅនឹងតម្រូវការនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- ការវិភាគមុខងារស្ថាប័ន អង្គភាព និងរំហ្ហូរការងារក្នុងក្រសួង ស្ថាប័ន សម្រាប់ប្រភេទសេវានីមួយៗ

មិនទាន់កំណត់បានច្បាស់លាស់និងកែលម្អឱ្យមានប្រសិទ្ធភាព

- ការផ្សារភ្ជាប់ផ្នែកស្ថាប័ននិងសកម្មភាពកែទម្រង់តាមការដ្ឋាន ជាមួយនឹងវិស័យជាអាទិភាពរបស់រាជរដ្ឋាភិបាល នៅមិនទាន់អាចអនុវត្តបានពេញលេញនិងមានប្រសិទ្ធភាព។

១.២.១.៤. កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

ក. ការងារនីតិកម្ម

ទំនើបកម្មច្បាប់សំដៅដល់ការតាក់តែងច្បាប់ឱ្យបានគ្រប់គ្រាន់ ដើម្បីតុលាការមានដំណើរការដោយរលូន គោរពលទ្ធិប្រជាធិបតេយ្យ គោលការណ៍នីតិរដ្ឋ លើកស្ទួយសិទ្ធិទទួលបានយុត្តិធម៌ និងសណ្តាប់ធ្នាប់សាធារណៈ។

- បានរៀបចំតាក់តែងក្រមគោលទាំង៤ រួមមាន ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្ម-ទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ
- បានរៀបចំតាក់តែងច្បាប់ទាំង៣ រួមមាន ច្បាប់រៀបចំអង្គការតុលាការ លក្ខន្តិកៈចៅក្រម លក្ខន្តិកៈព្រះរាជអាជ្ញា
- កសាងសេចក្តីព្រាងច្បាប់និងគោលនយោបាយក្នុងវិស័យយុត្តិធម៌ រួមមាន÷ សេចក្តីព្រាងច្បាប់ស្តីពីសារការី, សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, សេចក្តីព្រាងច្បាប់ក្រឡាបញ្ជី, សេចក្តីព្រាងច្បាប់ស្តីពីការតម្កល់និងការផ្ញើ, សេចក្តីព្រាងច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ, គោល-នយោបាយជាតិស្តីពីសន្ធានកម្ម និងគោលនយោបាយជាតិស្តីពីជំនួយផ្នែកច្បាប់
- ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់របស់ក្រសួង ស្ថាប័ននានា រួមមាន÷ សេចក្តីព្រាងបទបញ្ញត្តិស្តីពីការចុះបញ្ជីអចលនវត្ថុ, សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, សេចក្តីព្រាងច្បាប់ស្តីពីសំណង់, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង, សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសេវាសុខាភិបាល, សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម, សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន, សេចក្តីព្រាងច្បាប់ស្តីពីអន្តោប្រវេសន៍ថ្មី, សេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភ្ជួតគាមអនាម័យ, សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត, សេចក្តីព្រាងក្រមស្តីពីបទល្មើសយោធានិងនីតិវិធីបទល្មើសយោធា, សេចក្តីព្រាងច្បាប់ស្តីពីរៀបចំតុលាការយោធា, សេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងបណ្តោះអាសន្នវត្ថុចាប់យក, សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីច្បាប់ការងារ, សេចក្តីព្រាងច្បាប់ស្តីពីទឹកកខ្វក់និងប្រព័ន្ធលូ, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា,

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

សេចក្តីព្រាងច្បាប់ស្តីពីជលផល, សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ, សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, សេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធ, សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី), សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រមូលម្ហូបអាហារត្រឡប់មកវិញ, សេចក្តីព្រាងអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម, សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធ។

- ➢ កិច្ចការច្បាប់អន្តរជាតិ
  - សន្ធិសញ្ញាឬកិច្ចព្រមពៀងស្តីពីការផ្ទេរទណ្ឌិតដែលបានអនុម័តយល់ព្រម ចំនួន ១ (សាធារណរដ្ឋសង្គមនិយមវៀតណាម) និងកំពុងរៀបចំចំនួន ៤(សាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋតួកគី ប៊ែលហ្ស៊ិក និងប៉េរូ)
  - សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌដែលបានអនុម័តយល់ព្រមចំនួន ៣ (សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋសង្គមនិយមវៀតណាម និងសហព័ន្ធរុស្សី) និងកំពុងរៀបចំចំនួន ១ (បេឡារុស)
  - សេចក្តីព្រាងសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យរដ្ឋប្បវេណីរវាងកម្ពុជានិងឥណ្ឌា។
- ➢ ការចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ រួមមាន÷
  - ព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត
  - អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះ-ថ្នាក់ផ្សេងទៀត
  - អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត
  - អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ ស្តីពីកាតព្វកិច្ចក្នុងការទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
  - អនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩

- សេចក្តីប្រកាសលេខ ០៦ សប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ
- ប្រកាសលេខ ៨១ ស.នក.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងសុខាភិបាលស្តីពីកាតព្វកិច្ចពាក់ម៉ាសនិងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍។

ខ. ការងារកិច្ចការរដ្ឋបាលតុលាការ

រដ្ឋបាលតុលាការជាសេនាធិការរបស់តុលាការ ក្នុងការគ្រប់គ្រងនិងសម្របសម្រួលដំណើរការរដ្ឋបាល ហិរញ្ញវត្ថុ កិច្ចការបុគ្គលិក ទំនាក់ទំនងសាធារណៈ ការចុះបញ្ជីនិងគ្រប់គ្រងសំណុំរឿង និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យា ក្នុងគោលបំណងលើកកម្ពស់និងធានានូវដំណើរការល្អនៃអង្គការតុលាការ។

- ➢ ដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធអេឡិចត្រូនិកនៅតាមសាលាដំបូងរាជធានី ខេត្ត
- ➢ បណ្តុះបណ្តាលជំនាញបច្ចេកទេសលើការចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធអេឡិចត្រូនិកដល់មន្ត្រីទទួលបន្ទុក
- ➢ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី ខេត្ត ឱ្យកាន់តែល្អប្រសើរឡើង
- ➢ សិក្សានិងរៀបចំការអនុវត្តសាកល្បងតុលាការឌីជីថល (E-Court)
- ➢ កែសម្រួលសៀវភៅចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌឱ្យមានលក្ខណៈស្តង់ដារ
- ➢ ធ្វើបច្ចុប្បន្នភាពទម្រង់របាយការណ៍សកម្មភាពការងាររបស់សាលាជម្រះក្តីឱ្យមានស្តង់ដារតែមួយ និងងាយស្រួលគ្រប់គ្រងនិងបូកសរុប
- ➢ បន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធអេឡិចត្រូនិក
- ➢ រៀបចំខ្សែសេវាអ៊ីនធីណិតសម្រាប់កុំព្យូទ័រមេ (Server) សម្រាប់ប្រព័ន្ធចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធអេឡិចត្រូនិក
- ➢ រៀបចំរំហ្ជូរនីតិវិធីរដ្ឋបាលនៃលេខាធិការដ្ឋានរដ្ឋបាលសាលាជម្រះក្តី និងការកំណត់រំហ្ជូររដ្ឋបាលច្រករដ្ឋបាលតែមួយ លិខិតបទដ្ឋានគតិយុត្ត ទម្រង់ និងរបៀបនៃការប្រើប្រាស់សៀវភៅចុះបញ្ជីសំណុំរឿង លេខសេចក្តីសម្រេច និងលិខិតរដ្ឋបាល។

គ. ការបណ្តុះបណ្តាលធនធានមនុស្ស

ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រីអនុវត្តច្បាប់ក្នុងក្របខ័ណ្ឌនៃការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្រសួងយុត្តិធម៌មានរាជបណ្ឌិត្យសភា

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

វិជ្ជាជីវៈតុលាការជាសេនាធិការលើការបណ្តុះបណ្តាលដំបូងនិងបន្តដោយបានធ្វើការកែលម្អ និងអភិវឌ្ឍកម្មវិធីសិក្សា និងគ្រូឧទ្ទេស ជាបន្តបន្ទាប់។

➢ ការបណ្តុះបណ្តាលនៅរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ

ល.រ	សាលា	សិក្ខាកាម	ចំនួនសិស្សសរុប	
			ចំនួនសរុប	ស្ត្រី
១	សាលាភូមិន្ទចៅក្រម	សិក្សាចៅក្រម-ព្រះរាជអាជ្ញា	៥៩៧	១០១
២	សាលាភូមិន្ទក្រឡាបញ្ជី	ក្រឡាបញ្ជី	៦៨៨	២១១
៣	សាលាភូមិន្ទអាជ្ញាសាលា	អាជ្ញាសាលា	២៧	២
៤	សាលាភូមិន្ទសារការី	សារការី	៥០	១៩

➢ ការងារស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ផ្នែក	បរិយាយ	ចំនួន	រាជធានី-ខេត្ត និងសិក្ខាកាម
ការងារស្រាវជ្រាវ	ចុះស្រាវជ្រាវ និងវាយតម្លៃ តាមសាលាដំបូងរាជធានី ខេត្ត ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងការអនុវត្ត ច្បាប់គោលទាំងបីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ នៅតាមបណ្តារាជធានី ខេត្ត	៥២ ដង	ទូទាំងប្រទេស
ការផ្សព្វផ្សាយ	សិក្ខាសាលាអំពីកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌	៤៥ វគ្គ	៥,២០៥ នាក់
	ផលិតស្តុតអំពីកម្មវិធីកំណែទម្រង់និងសមិទ្ធផលដើម្បីចាក់ផ្សាយតាមវិទ្យុនិងទូរទស្សន៍	៥ ដង	ទូទាំងប្រទេស
ការបណ្តុះបណ្តាល	បណ្តុះបណ្តាលអំពីវិធីសាស្ត្រ បច្ចេកទេសស្រាវជ្រាវ សរសេរ អត្ថបទវិភាគផ្នែកច្បាប់ និងវាយតម្លៃលើផល-ប៉ះពាល់នៃ លិខិតបទដ្ឋានគតិយុត្ត	៩ វគ្គ	៥០០ នាក់
	បណ្តុះបណ្តាលនិងផ្សព្វផ្សាយស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមរយៈសន្ធានកម្មនិងច្បាប់ពាក់-ព័ន្ធ	៥០	៥២០៤ នាក់

ឃ. ការអភិវឌ្ឍស្ថាប័ន

ជាការឆ្លើយតបនឹងតម្រូវការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង ស្របតាមកំណើនប្រជាសាស្ត្រនិងការវិវត្តរបស់សង្គម ក្រសួងយុត្តិធម៌បានបង្កើនសមត្ថភាពការងារនិងពង្រឹងការអនុ-វត្តការងារគ្រប់គ្រង ព្រមទាំងការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្រសួងនិងតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ រួមមាន÷

- ដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍តំបន់ចំនួនបី រួមមានសាលាឧទ្ធរណ៍បាត់ដំបង សាលាឧទ្ធរណ៍ព្រះសីហនុ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ
- ជួលកន្លែងធ្វើការបន្ថែម ដើម្បីឆ្លើយតបនឹងតម្រូវការសេវាមូលដ្ឋានរបស់មន្ត្រី
- ដាក់ឱ្យដំណើរការសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកែប
- សាងសង់នូវអគារថ្មីនៃសាលាឧទ្ធរណ៍ភ្នំពេញ, សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ
- ជួសជុលនិងកែលម្អអគារទីស្តីការក្រសួងយុត្តិធម៌
- សាងសង់និងជួសជុលអគាររដ្ឋបាលរបស់សាលាដំបូងរាជធានី ខេត្ត និងអាគារស្នាក់នៅរបស់ចៅក្រម ព្រះរាជអាជ្ញា
- រៀបចំប្តង់ស្ថាបត្យកម្មគំរូមួយតាមលក្ខណៈបច្ចេកទេសច្បាស់លាស់កំណត់អំពីរចនាបថនិងអត្ត-សញ្ញាណជាសាលាជម្រះក្តី។

ង. ការកែទម្រង់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ

ក្នុងគោលបំណងធានានិងលើកកម្ពស់សមត្ថភាព គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ វិជ្ជាជីវៈច្បាប់ និងជំនាញផ្សេងទៀតក្នុងវិស័យច្បាប់និងយុត្តិធម៌ ព្រមទាំងពង្រឹងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ នៅព្រះរាជាណាចក្រកម្ពុជា ការកែទម្រង់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការរួមមាន÷

- គិតគូរពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលទៅកាន់វិជ្ជាជីវៈច្បាប់ផ្សេងទៀត ជាអាទិ៍សន្ធានការីមន្ត្រីរាជការដែលកំពុងបម្រើការងារនៅក្រសួងយុត្តិធម៌និងនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងមន្ត្រីអនុវត្តច្បាប់នៅតាមក្រសួង ស្ថាប័ននានា
- បង្កើតមុខងារស្រាវជ្រាវបែបវិទ្យាសាស្ត្រក្នុងវិស័យយុត្តិធម៌ (វិទ្យាស្ថានច្បាប់និងយុត្តិធម៌) ដើម្បីគាំទ្រដល់ការងារពាក់ព័ន្ធនឹងការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- ទំនើបកម្មនិងធ្វើឱ្យកាន់តែប្រសើរឡើងនូវកម្មវិធីសិក្សា
- ពង្រឹងគុណភាពនិងលើកតម្កើងកិត្តិយសដល់សាស្ត្រាចារ្យ ឬគ្រូបណ្តុះបណ្តាល។

ច. បញ្ហាប្រឈម

ក្នុងការអនុវត្តភារកិច្ចនិងការងាររហ្វូតសម្រេចបាននូវលទ្ធផលដូចបានរៀបរាប់ខាងលើនេះ ក្រសួងបាន

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជាធនធានមនុស្ស ធនធានហិរញ្ញវត្ថុ សម្ភារបរិក្ខារ និងសំណង់អាគារ សម្រាប់ធ្វើការជាដើម ដែលមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការនិងទំហំការងាររបស់ក្រសួងនាពេលបច្ចុប្បន្ន ជាពិសេសទំហំការងារ តួនាទីនិងភារកិច្ច ការទទួលខុសត្រូវរបស់ក្រសួងស្របតាមច្បាប់មូលដ្ឋានទាំងបី ដែលតម្រូវឱ្យក្រសួងត្រូវមានថវិកាច្រើនជាងមុន ចំនួនបុគ្គលិកដែលពោរពេញដោយជំនាញនិងសមត្ថភាពច្រើនជាងមុន ព្រមទាំង សម្ភារបរិក្ខារ សំណង់ និងអាគារសម្រាប់មន្ត្រីធ្វើការច្រើននិងមានទំហំធំជាងមុន។ ជាមួយគ្នានេះ បញ្ហាជំងឺរាតត្បាតកូវីដ-១៩ បានក្លាយជាឧបសគ្គដល់ការរៀបចំសកម្មភាពជួបប្រជុំ ក្នុងការដំណើរការរៀបចំច្បាប់និងគោលនយោបាយអាទិភាពរបស់ក្រសួង ដែលធ្វើឱ្យមានការអូសបន្លាយរយៈពេលយូរផងដែរ។

១.២.២. សមិទ្ធផលនិងបញ្ហាប្រឈមនៃយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឃ ១

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា។

ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្មរវាងការកែទម្រង់ទាំងបី យន្តការសម្របសម្រួលមួយ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ដោយផ្សារភ្ជាប់ទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង៣។ យន្តការនេះមានរបបប្រជុំប្រចាំត្រីមាស តាមការដឹកនាំជាលក្ខណៈប្តូរវេន ដើម្បីពិនិត្យ សម្របសម្រួល និងលើកសំណើដំណោះស្រាយបញ្ហាប្រទាក់ក្រឡារវាងកម្មវិធីកែទម្រង់ទាំងបី។

នៅឆ្នាំ២០១៨ យន្តការខាងលើបានបញ្ចូលកម្មវិធីកែទម្រង់ ១ បន្ថែមទៀត គឺកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលយន្តការនេះត្រូវបានហៅថា យន្តការសម្របសម្រួលការកែទម្រង់ ៣ ឃ ១ នៃរាជរដ្ឋាភិបាល ដែលហៅកាត់ថា “**យ.ស.ក.**” ផ្អែកតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

យ.ស.ក. សម្រេចបាននូវការប្រជុំផ្លាស់វេនជាប្រចាំប៉ុន្តែដោយហេតុសត្យានុម័តនៃការរីករាលដាលជម្ងឺកូវីដ-១៩ យន្តការកិច្ចប្រជុំនេះមិនត្រូវបានរៀបចំជាប្រក្រតីឡើយ។ កត្តាជាបញ្ហាប្រឈមសម្រាប់ **យ.ស.ក.** ដែលរួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ នៅតែបន្តមាន ដែលទាមទារឱ្យមានការបង្កើតយន្តការសម្របសម្រួលជាក់លាក់ មានក្របខ័ណ្ឌផែនការសកម្មភាព និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពជាទៀងទាត់។

១.៣. ស្ថានភាពបច្ចុប្បន្ន

១.៣.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានចក្ខុវិស័យច្បាស់លាស់គឺប្រែក្លាយ "***ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ***"។

ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់យកតាំងពីចុងឆ្នាំ២០០៤ រហូតមក នូវយុទ្ធសាស្ត្រកែទម្រង់ "**បោះជំហានជាដំណាក់កាល**" (Platform Approach) គឺបោះជំហានថ្មីទៅក្នុងដំណាក់កាលថ្មី ដោយថែរក្សាជំហានដែលសម្រេចបានជោគជ័យកន្លងទៅផង ថែមទាំងរៀបចំត្រៀមខ្លួនតម្រង់ឆ្ពោះទៅកាន់ជំហានខាងមុខបន្ទាប់ទៀតផង។ ក្នុងន័យនេះ កិច្ចការ ៣យ៉ាង ត្រូវបំពេញក្នុងពេលដំណាលគ្នាគឺ÷ ១) ថែរក្សានិងពង្រឹងបន្ថែមនូវសមិទ្ធផលដែលសម្រេចបានក្នុងដំណាក់កាលមុន ២) ស្ថាបនាសមិទ្ធផលដែលត្រូវសម្រេចឱ្យបានក្នុងដំណាក់កាលបច្ចុប្បន្ន និង ៣) រៀបចំត្រៀមខ្លួនកសាងសមិទ្ធផលថ្មីៗ នៅដំណាក់កាលខាងមុខ។

ផ្អែកលើយុទ្ធសាស្ត្រកែទម្រង់ខាងលើ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានគ្រោងទុកថានឹងបញ្ចប់នៅឆ្នាំ២០១៥។ ប៉ុន្តែ បទពិសោធន៍ បានបង្ហាញថាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពិតជាត្រូវការរយៈពេលបន្ថែមទៀត គឺសរុបប្រមាណ ២៣ ឆ្នាំ ដោយគ្រោងជាថ្មីថានឹងសម្រេចបញ្ចប់នៅឆ្នាំ២០២៧ ហើយដែលនៅពេលនោះ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជានឹងត្រូវបានផ្លាស់ប្តូរទាំងស្រុងទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុ-វត្តន៍អន្តរជាតិ។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

យុទ្ធសាស្ត្រកែទម្រង់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ចាប់តាំងពីការសម្រេចជាវឌ្ឍនភាពក្នុងខ្សែន ឬដំណាក់កាលទី១ ដល់ទី៣ ការងារសេសសល់មួយចំនួននៅតែបន្តមាននិងទាមទារឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបន្តអនុវត្តក្នុងការកសាងមូលដ្ឋានគ្រឹះឱ្យបានរឹងមាំនិងដើម្បីរក្សាបានចីរភាពនៃប្រព័ន្ធទាំងមូល។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅក្នុងដំណាក់កាល ៣ បូក ២ ដែលមានសុពលភាពអនុវត្តសម្រាប់រយៈពេល ២ ឆ្នាំ គឺឆ្នាំ២០២១-២០២២។ ៣ បូក ២ គឺបានន័យថាការបន្ថែមរយៈពេលចំនួន ២ ឆ្នាំទៀត សម្រាប់ការអនុវត្តដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដែលត្រូវបានគ្រោងពីដំបូងថានឹងបញ្ចប់នៅឆ្នាំ២០២០ និងចាប់ផ្តើមអនុវត្តដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" នៅក្នុងឆ្នាំ២០២១។

ការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាល ៣ បូក ២ (២០២១-២០២២) ក្នុងរយៈពេល ២ឆ្នាំនេះ បានសម្រេចសមិទ្ធផលជាមូលដ្ឋានគ្រឹះដែលចាំបាច់និងគ្រប់គ្រាន់សម្រាប់ការបោះជំហានទៅមុខនិងចាប់ផ្តើមអនុវត្តដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ចាប់ពីឆ្នាំ២០២៣ តាមការរំពឹងទុក។

ក្នុងដំណាក់កាលទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្របខ័ណ្ឌផែនការសកម្មភាពរួម (CAP4) ឆ្នាំ២០២៣-២០២៧ ដែលត្រូវអនុម័តដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងក្លាយជាផែនទីចង្អុលផ្លូវ ដើម្បីសម្រេចបាននូវចក្ខុវិស័យ នោះគឺការប្រែក្លាយ "**ប្រព័ន្ធ**

ហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងខ្នាតអាទិភ្ជ្ជ អន្តរជាតិ"។

១.៣.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការបាននិងកំពុងអនុវត្តតាមរយៈកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមដំណាក់កាលនីមួយៗ ដែលដំណាក់កាលទី១ រយៈពេល ១០ឆ្នាំ ត្រូវបានអនុវត្តបញ្ចប់នៅចុងឆ្នាំ២០២០។

ក្នុងការបន្តកិច្ចដំណើរការកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានសម្រេចរៀបចំនិងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល ១០ឆ្នាំ ដំណាក់កាលទី២ (២០២១-២០៣០) ដើម្បីធានាដល់ការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅរបស់រាជរដ្ឋាភិបាលដូចមានរៀបរាប់ខាងក្រោម÷

១.៣.២.១. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺ "***ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈនិងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ធនិងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបានឆ្ងាយគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០***"។

ដើម្បីធានាដល់ការចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យនេះ ចាំបាច់ត្រូវកែសម្រួលរចនាសម្ព័ន្ធ សិទ្ធិអំណាច មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពសមស្របក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃការវិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម។ រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវមានសមត្ថភាពពេញលេញក្នុងការផ្តល់សេវាសាធារណៈ ដើម្បីចូលរួមគាំទ្រដល់ការវិនិយោគនិងការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋាន ព្រមទាំងបង្កើនការអប់រំនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថ-កិច្ចរបស់ខ្លួន។ ទន្ទឹមគ្នានេះ ការទទួលខុសត្រូវដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវធានាថាប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍប្រកបដោយបរិយាប័ន្ធនិងសមធម៌សង្គម រួមទាំងការធានាឱ្យស្ត្រី ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះទទួលបានឱកាសស្មើភាពគ្នាផ្នែកសេដ្ឋកិច្ចនិងសេវាសង្គមនានា។

១.៣.២.២. គោលបំណង

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានគោលបំណង ***"លើកកម្ពស់ការផ្តល់សេវានិងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ធ សមធម៌ និងយុត្តិធម៌តាមរយៈការ***

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

ធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលម្អនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង"។

ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវជំរុញដល់ការរៀបចំប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបទំនើបនិងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ព្រមទាំងត្រូវមានបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈសម្រាប់ដំណើរការប្រព័ន្ធទាំងនេះប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានផែនការដែលឆ្លុះបញ្ចាំងពីតម្រូវការជាអាទិភាពនានានៅតាមមូលដ្ឋាននីមួយៗ តាមរយៈការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវទទួលបាននូវធនធានហិរញ្ញវត្ថុនិងសិទ្ធិអំណាចកាន់តែច្រើនបន្ថែមទៀតក្នុងការធ្វើការសម្រេចនានាពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួន។ គួនាទីនីតិវិធីអនុវត្តការងារ និងសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវពង្រឹង ដើម្បីក្លាយជាអង្គដ៏សំខាន់ក្នុងការធានានូវគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

១.៣.២.៣. គោលដៅ

គោលដៅនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅឆ្នាំ២០៣០គឺ ***"រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ធ និងសមធម៌សង្គមក្នុងផែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោម-ជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្របនិងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ"***។

ដើម្បីធានាដល់ការសម្រេចបានគោលដៅនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវផ្តោតទៅលើការរៀបចំអនុវត្តតាមសមាសភាគនិងសមិទ្ធផលរំពឹងទុកនានាដូចខាងក្រោម÷

- **សមាសភាគទី១÷ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការគ្រប់គ្រងការងារកំណែទម្រង់ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ក្នុងការរៀបចំនិងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិ-សិទ្ធិភាព។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន÷

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

១). ការបន្តពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់ **គ.ជ.អ.ម.** អនុគណៈកម្មាធិការនានានៃ **គ.ជ.អ.ម.** គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការដឹកនាំសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ស្របតាមផែនការអនុវត្តនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់នេះជាមួយកម្មវិធីកំណែទម្រង់ផ្សេងទៀត ដូចជាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងយុត្តិធម៌ ជាដើម។

២). ការពង្រឹងយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាននិងការប្រាស្រ័យទាក់ទង ដើម្បីធានាថាស្ថាប័នពាក់ព័ន្ធទាំងអស់ និងសាធារណជនមានការយល់ដឹងកាន់តែទូលំទូលាយអំពីចក្ខុវិស័យ គោលបំណង គោលដៅ និងលទ្ធផលរំពឹងទុកនានានៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

៣). ការលើកកម្ពស់ការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការតាមដំណាក់កាលនីមួយៗ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

៤). ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំបង្កើតស្ថាប័នថ្នាក់ជាតិដែលមានតួនាទីនិងការទទួលខុសត្រូវជាក់លាក់និងច្បាស់លាស់ក្នុងការផ្តល់ការគាំទ្រនិងការត្រួតពិនិត្យលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់-ក្រោមជាតិ។

៥). ការពង្រឹងតួនាទីសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបំពេញតួនាទីផ្តល់មតិយោបល់និងអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។

➢ **សមាសភាគទី២÷ រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការកំណត់ឱ្យច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរវាងថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមប្រភេទ និងចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដូចជារដ្ឋបាលតំបន់ទីក្រុងធំ រដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ ព្រមទាំងការជំរុញឱ្យមានការរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រព័ន្ធគ្រប់គ្រងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្តល់សេវាសាធារណៈនិងការប្រាស្រ័យទាក់ទងសាធារណៈ។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំនិងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន÷

១). ការសិក្សានិងការបែងចែកឱ្យបានច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះ

- **ក្រសួង ស្ថាប័នថ្នាក់ជាតិ** ត្រូវមានមុខងារស្នូលសំខាន់ៗពាក់ព័ន្ធនឹង ១). ការសិក្សាស្រាវជ្រាវដើម្បីជំរុញការអភិវឌ្ឍនិងនវានុវត្តន៍តាមវិស័យជំនាញរបស់ខ្លួន, ២). ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេសសម្រាប់កំណត់ស្តង់ដារសេវា, ៣).ការគាំទ្រ តាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៤). ការអនុវត្តមុខងារជាយុទ្ធសាស្ត្រធំៗមួយចំនួន។
- **រដ្ឋបាលខេត្ត** ត្រូវរៀបចំប្រែក្លាយជារដ្ឋបាលដែលមានរចនាសម្ព័ន្ធគ្រប់គ្រងតាមចរិតលក្ខណៈជា**រដ្ឋបាលតំបន់**ផ្នែកតាមគោលការណ៍នៃរដ្ឋបាលឯកភាពនិងមានមុខងារសំខាន់ៗពាក់ព័ន្ធនឹង ១). ការបំពេញមុខងារជាតំណាងឱ្យរាជរដ្ឋាភិបាលនិងក្រសួង ស្ថាប័នក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអនុវត្តមុខងារនានាដែលរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នបានធ្វើប្រតិភូកម្មឱ្យ, ២).ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋានក្នុងការអនុវត្តមុខងារផ្តល់សេវាសាធារណៈ ការត្រួតពិនិត្យនីតិវិធីនុកូលភាព ការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន ស្របតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដារសេវាដែលបានកំណត់ ការសម្របសម្រួលជាមួយរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍតំបន់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង ៣). ការអនុវត្តមុខងារ ឬគម្រោងក្នុងវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេសខ្ពស់ និងឬមានវិសាលភាពគ្របដណ្តប់លើភូមិសាស្ត្រទូទាំងខេត្តដែលរដ្ឋបាលក្រុង ស្រុកពុំអាចអនុវត្តបាន។
- **រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់**នឹងត្រូវរៀបចំប្រែក្លាយជា**រដ្ឋបាលមូលដ្ឋាន**ដែលមានស្វ័យភាពសមត្ថភាព និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈនានាដោយផ្ទាល់ជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលមូលដ្ឋានទាំងនេះនឹងត្រូវរៀបចំឱ្យមានមុខងារ រចនា-សម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈពិសេសផ្សេងៗគ្នាស្របតាមសក្តានុពលនិងស្ថានភាពផ្សេងៗគ្នារវាងទីប្រជុំជន និងតំបន់ជនបទ។ រដ្ឋបាលមូលដ្ឋានទាំងនេះមានមុខងារសំខាន់ៗពាក់ព័ន្ធនឹង ១). ការកំណត់តម្រូវការនិងបញ្ហាប្រឈមនានានៅតាមមូលដ្ឋានតាមរយៈដំណើរការកសាងផែនការដោយមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋនិងសហគមន៍មូលដ្ឋាន និងការពង្រឹងអនុវត្តការងារគណនេយ្យភាពសង្គម, ២). ការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន និងផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដារសេវាដែលបានកំណត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ និង ៣). ការរៀបចំនិងអនុវត្តការងារគណនេយ្យភាពជាមួយប្រជាពលរដ្ឋ តាមរយៈយន្តការទទួលសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ។

- **រដ្ឋបាលរាជធានី** ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងជា**រដ្ឋបាលក្រុងមេត្រូប៉ូលីតែន** ដែលមានលក្ខណៈពិសេសដោយឡែកពីរដ្ឋបាលខេត្តនិងរដ្ឋបាលក្រុងដទៃទៀត។ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ ត្រូវរៀបចំស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលបង្កលទ្ធភាពឱ្យរដ្ឋបាលនេះអាចបំពេញមុខងារជារដ្ឋបាលតំបន់និងរដ្ឋបាលមូលដ្ឋានផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាលនេះក៏មានលទ្ធភាពក្នុងការពង្រីកការអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួន ដែលបច្ចុប្បន្ននេះ រាជធានីភ្នំពេញរួមមានតំបន់រណបជាច្រើនដែលត្រូវបានកាត់ចេញពីខេត្តជាប់ព្រំប្រទល់នានា ដាក់បញ្ចូលឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី (ដែលតំបន់រណបទាំងនេះពុំទាន់មានការអភិវឌ្ឍដូចគ្នានឹងខណ្ឌនានាដែលស្ថិតនៅតំបន់កណ្តាលនៃរាជធានី) ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការទទួលខុសត្រូវជាចម្បងរបស់រដ្ឋបាលរាជធានីរួមមានដូចជា ការរៀបចំផែនការទីក្រុង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការរៀបចំនិងការផ្តល់សេវាដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងចរាចរណ៍ ការគ្រប់គ្រងសំណល់រឹងនិងរាវ ការងារបរិស្ថាននិងអនាម័យ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់និងសុវត្ថិភាពសាធារណៈ និងមុខងារមួយចំនួនទៀត។

២). ការពិនិត្យនិងការកែលម្អនូវទំនាក់ទំនងការងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងក្រសួង ស្ថាប័នថ្នាក់ជាតិ ស្របតាមមុខងារនិងការទទួលខុសត្រូវរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ។

៣). ការពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ការដឹកនាំ ការធ្វើសេចក្តីសម្រេចក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

៤). ការបន្តលើកកម្ពស់ខ្សែគណនេយ្យភាពទាំងបី ពោលគឺ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខ្ពស់ជាងនិងចំពោះថ្នាក់ជាតិ, គណនេយ្យភាពផ្ទៃក្នុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ, និងជាពិសេសគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

៥). ការកែលម្អយន្តការអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការបំពេញការងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមស្វ័យភាព សិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានជាធរមាន។

➢ **សមាសភាគទី៣÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

សមាសភាគនេះផ្តោតលើការសម្រេចបាននូវសមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអំណាចនិងការ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ទទួលខុសត្រូវឱ្យបានសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារនិងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការ ជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបានន្ទវសមិទ្ធផលរំពឹងទុកនេះ រួមមាន÷

១). ការរៀបចំអង្គមន្ត្រីរាជការដើម្បីប្រមូលផ្តុំនិងគ្រប់គ្រងមន្ត្រីដែលទទួលបានការបណ្តុះបណ្តាល មានបទពិសោធន៍ការងារ មានចំណេះដឹង និងបំពេញការងារក្នុងវិស័យជំនាញវិជ្ជាជីវៈតែមួយនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងដើម្បីធានាដល់ការដាក់បញ្ចូលមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងអង្គមន្ត្រីរាជការនីមួយៗដែលធានាដល់ការលើកទឹកចិត្តមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

២). ការជំរុញនិងការពង្រឹងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវឱ្យបានពេញលេញក្នុងការជ្រើសរើស ការគ្រប់គ្រង និងការរៀបចំបុគ្គលិករបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានបុគ្គលិកក្នុងចំនួនសមស្របដែលមានសមត្ថភាពជំនាញវិជ្ជាជីវៈនិងមានបទពិសោធន៍ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ បុគ្គលិកម្នាក់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានលក្ខខណ្ឌការងារច្បាស់លាស់ដែលជាមូលដ្ឋានសម្រាប់ការវាយតម្លៃប្រចាំឆ្នាំដែលនឹងត្រូវអនុវត្តជាប្រចាំ។

៣). ការរៀបចំឱ្យមានប្រព័ន្ធលើកទឹកចិត្តសមស្របដល់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាការលើកទឹកចិត្តផ្នែកប្រាក់ខែ ប្រាក់ឧបត្ថម្ភ ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង និងការលើកទឹកចិត្តផ្សេងទៀត ដើម្បីលើកកម្ពស់ឆន្ទៈម្ចាស់ការនិងមនសិការវិជ្ជាជីវៈក្នុងការបំពេញការងារ ព្រមទាំងលើកទឹកចិត្តបុគ្គលិកស្ម័គ្រចិត្តទៅបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក។

៤). ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាពសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលនិងការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្របជាមួយនឹងការពិព័ណ៌នាមុខតំណែងនិងលក្ខខណ្ឌការងាររបស់បុគ្គលិកម្នាក់ៗ។

៥). ការពង្រឹងកិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋានលើការរៀបចំស្តង់ដារកម្មវិធីសិក្សា កម្មវិធីបណ្តុះបណ្តាល សម្ភារៈបណ្តុះបណ្តាល និងការរៀបចំគ្រូឧទ្ទេស ក៏ដូចជាការអនុវត្តវគ្គបណ្តុះបណ្តាលនានាដោយផ្ទាល់ដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជិតស្និទ្ធជាមួយស្ថាប័នជំនាញផ្នែកបណ្តុះ-បណ្តាលនានា ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ ជាមួយគ្នានេះ ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឡើងដោយផ្អែកជាមូលដ្ឋានលើវិធីសាស្ត្រផ្សេងៗ រួមបញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពលើប្រធានបទជាក់លាក់ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការសិក្សាដោយខ្លួនឯង។

➢ សមាសភាគទី៤÷ វិមជ្ឈការហិរញ្ញវត្ថុនិងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកដែលពាក់ព័ន្ធនឹងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាអាចព្យាករបាននិងមានទំហំសមស្របទៅនឹងមុខងារនិងអាទិភាពគោល-នយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា ដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាសភាគនេះត្រូវអនុវត្តដោយមានកិច្ចសហការនិងការសម្របសម្រួលយ៉ាងជិត-ស្និទ្ធជាមួយនឹងកម្មវិធីកំណែទម្រង់ និងក្រសួង ស្ថាប័នអនុវត្តនានា ជាពិសេសជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងក្រសួងផែនការ។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំនិងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន÷

១). ការពិនិត្យនិងការកែសម្រួលកិច្ចដំណើរការនៃការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមរចនាសម្ព័ន្ធ ប្រព័ន្ធ និងមុខងារថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបន្ស៊ីគ្នារវាងកិច្ចដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាមួយកម្មវិធីវិនិយោគបីឆ្នាំរំកិល ផ្អែកលើទិន្នន័យនិងព័ត៌មានច្បាស់លាស់អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងអំពីធនធានហិរញ្ញវត្ថុដែលអាចព្យាករបាន។

២). ការពិនិត្យមើលឡើងវិញនិងការបង្កើនធនធានហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនប្រភពចំណូលមូលដ្ឋានដែលបានមកពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការពិចារណាក្នុងការបង្កើនអត្រាចែករំលែកចំណូលសារពើពន្ធនិងលទ្ធភាពបន្ថែមប្រភេទពន្ធថ្មីៗបន្ថែមទៀត, ការផ្ទេរធនធានគ្មានភ្ជាប់លក្ខខណ្ឌនិងធនធានមានភ្ជាប់លក្ខខណ្ឌ និងតាមរយៈការបង្កើតនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុបន្ថែមទៀតដូចជា ការបង្កើតមូលនិធិភាពរភាពសំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជននិងតំបន់ជនបទ ព្រមទាំងកញ្ចប់ថវិកាពិសេសសម្រាប់ជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលតិចតួច។

៣). ការពង្រឹងការអនុវត្តសវនកម្មនិងអធិការកិច្ចលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថាធនធាននិងទ្រព្យសម្បត្តិទាំងនោះត្រូវបានចាត់ចែង និងប្រើប្រាស់ស្របតាមនីតិវិធីដែលបានកំណត់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យ-ភាព។

៤). ការរៀបចំនិងការដាក់ឱ្យអនុវត្តនូវគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តនានាពាក់ព័ន្ធការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការវិនិយោគក្នុងភាពជាដៃគូជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា។

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

➢ **សមាសភាគទី៥÷ ការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកដែលពាក់ព័ន្ធការរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំនិងអនុវត្ត ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន÷

១). ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ចនិងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ព្រមទាំងការកំណត់ឱ្យមានគោលការណ៍ បែបបទ និងនីតិវិធីច្បាស់លាស់ សាមញ្ញ និងងាយស្រួលក្នុងការប្រតិបត្តិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់

២). ការពង្រឹងនិងការកែលម្អនូវយន្តការនានាដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋដោយឆាប់រហ័ស តម្លាភាព សមធម៌ និងប្រកបដោយលក្ខណៈងាយស្រួល។

៣). ការរៀបចំនិងគាំទ្រឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុឆន្ទានុសិទ្ធិក្នុងទំហំសមស្របនិងមានធនធានមនុស្សប្រកបដោយសមត្ថភាពនិងជំនាញវិជ្ជាជីវៈជាក់លាក់ ព្រមទាំងប្រកបដោយមនសិការវិជ្ជាជីវៈក្នុងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

៤). ការផ្លាស់ប្តូរឥរិយាបថរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាអ្នកផ្តល់សេវាដ៏ល្អប្រសើរនិងប្រកបដោយប្រសិទ្ធភាពដោយត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវឆន្ទៈ ម្ចាស់ការ ភក្តីភាព មនសិការ វិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋ។

៥). ការបង្កើនកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិនិងកិច្ចសហប្រតិបត្តិ-ការក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិលនិងវិស័យឯកជន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗប្រកបដោយភាពជឿជាក់ និងឈរលើស្មារតីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋដោយស្មោះត្រង់។

បន្ថែមលើសមាសភាគទាំង៥ខាងលើនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) នឹងផ្តោតលើកិច្ចការអន្តរវិស័យចំនួន២ រួមមាន÷

➢ **ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម÷**

កិច្ចការអន្តរវិស័យនេះផ្តោតលើការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិក ការរៀបចំផែនការ និងធនធាន ព្រមទាំងការចាត់ចែងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាន

ដោយគ្មានការរើសអើង និងមិនប្រកាន់ជាតិសាសន៍ សាសនា ភេទ ជនពិការ ក្រុមជនងាយរងគ្រោះនានាក្នុងសង្គមប្រកបដោយបរិយាប័ន្ននិងសមធម៌។

➢ **ការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា÷**

កិច្ចការអន្តរវិស័យនេះផ្តោតលើការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចវាយតម្លៃ គ្រប់គ្រង និងឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ដើម្បីគាំទ្រដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋនិងអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។

១.៣.៣. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ

ផ្អែកតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងសមិទ្ធផលនិងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ជាបន្តបន្ទាប់នាពេលកន្លងមក, **គ.ក.រ.** បាននិងកំពុងរៀបចំសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥ ដែលកំណត់ចក្ខុវិស័យ គឺ "**ធានាឱ្យបានទូវរដ្ឋបាលសាធារណៈដែលមានលក្ខណៈខ្លាំង ស្អាតស្អំ ឆ្លាត និងផ្តោតលើប្រជាជនជាស្នូល សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គមប្រកបដោយសមធម៌ យុត្តិធម៌ និងបរិយាប័ន្ន**"។

កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥ កំណត់ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងដំណាក់កាលនៃការអនុវត្តសកម្មភាពកែទម្រង់យ៉ាងច្បាស់លាស់និងប្រាកដនិយម សមស្របនឹងបរិការណ៍កម្ពុជា។ កម្មវិធីកែទម្រង់នេះ ផ្តោតជាអាទិភាពលើការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ការអនុវត្តនិងការត្រួតពិនិត្យ វាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ។ ដើម្បីធានាឱ្យសម្រេចបានទូវគោលបំណងនេះ យុទ្ធសាស្ត្រចំនួនបីនឹងត្រូវដាក់ឱ្យអនុវត្ត រួមមាន÷

- ➢ ការជំរុញនវានុវត្តន៍និងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងរដ្ឋបាលសាធារណៈ
- ➢ ការជំរុញនិងការរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- ➢ ការរៀបចំយន្តការគណនេយ្យភាពរបស់អង្គភាពចំពោះប្រជាជន និងការចូលរួមវាយតម្លៃរបស់ប្រជាជនក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ។

១.៣.៤. កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦នៃរដ្ឋសភាបានដាក់ចេញនិងអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ។ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នេះ ពាក់ព័ន្ធនឹងការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ រាជរដ្ឋាភិបាលផ្តោតជាសំខាន់លើការលើកកម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធភាពការងារមន្ត្រីអនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្តពីសាធា-

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

រណជនលើវិស័យយុត្តិធម៌ និងប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌នៅក្នុងសង្គម តាមរយៈ÷

១. ការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ

២. ការពង្រឹងភាពស្អាតស្អំនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់

៣. ការពង្រឹងយន្តការវិន័យការងារនិងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌

៤. ការលើកកម្ពស់ការផ្តល់សេវាច្បាប់

៥. ការពង្រឹងនិងកែលម្អយន្តការដោះស្រាយវិវាទដែលអាចឆ្លើយតបបានទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលដាក់ចេញនូវកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ឆ្ពោះទៅសម្រេចចក្ខុវិស័យ “***ការទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា តាមរយៈការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និងសិទ្ធិទទួលបានយុត្តិធម៌របស់ពលរដ្ឋ***”។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃការកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្រសួងយុត្តិធម៌បានដាក់ចេញនូវទិសដៅអនុវត្តសកម្មភាពសំខាន់ៗ ដូចខាងក្រោម÷

- **បន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**
  - ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន
  - ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់
  - ជំរុញលទ្ធភាពឱ្យទទួលព័ត៌មានអំពីច្បាប់និងតុលាការឱ្យកាន់តែប្រសើរឡើង
  - ធ្វើឱ្យគុណភាពនៃដំណើរការរឿងក្តីនិងសេវាកម្មពាក់ព័ន្ធឱ្យកាន់តែប្រសើរឡើង
  - ពង្រឹងសេវាកម្មយុត្តិធម៌រួមមានអំណាចតុលាការនិងសេវាកម្មផ្នែកអយ្យការ
  - បង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង
  - ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់និងតុលាការ ឱ្យអាចបំពេញអាណត្តិកិច្ចរបស់ខ្លួនបានជោគជ័យ។
- **ការងារអភិវឌ្ឍច្បាប់**
  - ពង្រឹងការរៀបចំច្បាប់និងជំរុញការអនុម័តច្បាប់
  - ពង្រឹងនិងពង្រីកការផ្សព្វផ្សាយបទប្បញ្ញត្តិច្បាប់ និង
  - ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់និងយុត្តិធម៌។
- **លើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយរឿងក្តី**
  - ពង្រឹងការបណ្តុះបណ្តាលច្បាប់និងជំនាញផ្សេងៗដល់មន្ត្រីអនុវត្តច្បាប់រួមមានមន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងអ្នកប្រកបវិជ្ជាជីវៈច្បាប់

- លើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពិសេសនៅថ្នាក់មូលដ្ឋាន
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមសាលាជម្រះក្តី
- លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យយុត្តិធម៌ និង
- ពង្រឹងយន្តការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់។

➢ **លើកកម្ពស់សមត្ថភាពស្ថាប័ន**

- បង្កើនសមត្ថភាពការងារនិងពង្រឹងការអនុវត្តការងារ និង
- ពង្រីកនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្រសួងនិងតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

ជំពូកទី២. ចក្ខុវិស័យស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១

១.១. ចក្ខុវិស័យនិងបេសកកម្មសម្រាប់កម្មវិធីកែទម្រង់ ៣ បូក ១

១.១.១. ចក្ខុវិស័យ

កម្មវិធីកែទម្រង់ ៣ បូក ១ មានចក្ខុវិស័យដោយឡែកពីគ្នាទៅតាមវិសេសភាពនិងវិស័យរៀងៗខ្លួន ដែលមានដូចតទៅ÷

កម្មវិធីកែទម្រង់	ឆ្នាំគោលដៅ	ចក្ខុវិស័យ
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	២០២៥	ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ
កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ	២០៣០	ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈនិងផល-ប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋាន ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០
កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ	២០៣៥ (សេចក្ដីព្រាង)	ធានាឱ្យបាននូវរដ្ឋបាលសាធារណៈដែលមានលក្ខ-ណៈ ខ្លាំង ស្អាតស្អំ ឆ្លាតវៃ និងផ្តោតលើប្រជាជនជាស្នូល
កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌	(សេចក្ដីព្រាង)	ការទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា តាមរយៈការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និងសិទ្ធិទទួលបានយុត្តិធម៌

យន្តការសម្របសម្រួលអន្តរកែទម្រង់ ៣ បូក ១ មិនមានគោលដៅសំយោគនិងបង្រួមចក្ខុវិស័យនៃកម្មវិធីកែទម្រង់នីមួយៗ ទៅជាចក្ខុវិស័យតែមួយនោះទេ ដោយគោរពគោលការណ៍ភាពជាម្ចាស់ និងគោល-ការណ៍សុខដុមនីយកម្ម។

ផ្ទុយទៅវិញ ចក្ខុវិស័យដែលស្នើឡើងគឺជាចក្ខុវិស័យរបស់អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង ៤ ដែលជាអ្នកសម្របសម្រួលស្នូល ដើម្បីធានាឱ្យការងារកែទម្រង់ ៣ បូក ១ មានសង្គតិភាព ភាពប្រទាក់ក្រឡាគ្នា និងសុខដុមនីយកម្មនឹងគ្នា។

ដូចនេះ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង ៤ សម្រេចកំណត់ចក្ខុវិស័យរួមដូចតទៅ÷

ចក្ខុវិស័យ **សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**

១.១.២. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យរួមខាងលើ អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង ៤ នឹងអនុវត្តផែនការសកម្មភាពរួមគ្នា នៅក្នុងបេសកកម្មគន្លឹះមួយគឺ÷

បេសកកម្ម **ធានាសង្គតិភាព និងស័ក្តិសិទ្ធភាព នៃការគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ បូក ១**

១.២. ក្របខ័ណ្ឌផែនការសកម្មភាពរួមនិងប្រតិពន្ធធានាផ្ទៃ

១.២.១. ក្របខ័ណ្ឌផែនការសកម្មភាពរួម

សមិទ្ធផល បញ្ហាប្រឈម និងបទពិសោធន៍ ក្នុងរយៈពេលប្រមាណ ៨ ឆ្នាំកន្លងមកនេះ នៃយន្តការសម្ប-សម្រួលការកែទម្រង់ ៣ បូក ១ គឺជាមូលដ្ឋានដ៏មានសារៈសំខាន់និងជាសព្យានុម័ត ដើម្បីជាការពិចារណាលើកាលានុវត្តភាពនិងអាទិភាពនៃសកម្មភាព ដែលអាចរៀបចំឡើងប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

ក្នុងន័យនេះ អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ បានពិនិត្យនិងពិចារណាលើសកម្មភាព ដោយសម្លឹងផ្តោតលើសកម្មភាពទាំងឡាយដែលយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ជា

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

យន្តការការងារដែលមាន “**សមានគតិភាព**” ជាងគេ និងអាចអនុវត្តទៅបានលទ្ធផលដោយ “**ស័ក្តិសិទ្ធភាព**” ជាងគេ។

នេះជាកាលានុវត្តភាពដែលអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ ត្រូវពិចារណាបង្កើតជាសកម្មភាព ដោយប្រកាន់អភិក្រម “**ស្រាល ស្រួច និងស្រេច**”។

ស្ថិតក្នុងស្មារតីនេះ និងដើម្បីសម្រេចបាននូវចក្ខុវិស័យនិងបេសកកម្មគន្លឹះខាងលើ អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាន ៣ បូក ១ សម្រេចដាក់ចេញក្របខ័ណ្ឌផែនការសកម្មភាពរួម ដែលមានលម្អិតជាយុទ្ធសាស្ត្រចំនួន ៣ និងគាំទ្រដោយកម្មវិធីចំនួន ១២ ដែលមានដូចតទៅ÷

ចក្ខុវិស័យ	សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
បេសកកម្ម	ធានាសង្គតិភាពនិងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ បូក ១
អភិក្រម	ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីស័ក្តិសិទ្ធភាព និងសុខដុមនីយកម្មនៃការកែទម្រង់ទាំង៤
យុទ្ធសាស្ត្រ	**១. សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ ៣ បូក ១**
កម្មវិធី	១.១. កំណត់និងរៀបចំមុខងារនិងរចនាសម្ព័ន្ធ
	១.២. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
	១.៣. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស
	១.៤. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
យុទ្ធសាស្ត្រ	**២. សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម**
កម្មវិធី	២.១. រៀបចំនិងសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា
	២.២. រៀបចំនិងសម្របសម្រួលការងារសវនកម្មនិងអធិការកិច្ច
	២.៣. ពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់ ៣ បូក ១
	២.៤. រៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ន និង គុណភាពសេវាសាធារណៈ

យុទ្ធសាស្ត្រ	៣. សុខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់ ៣ បូក ១
កម្មវិធី	៣.១. រៀបចំនិងសម្របសម្រួលកិច្ចដំណើរការ និងការគាំទ្រកម្មវិធីកែទម្រង់ ៣ បូក ១
	៣.២. រៀបចំនិងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់ ៣ បូក ១
	៣.៣. រៀបចំនិងសម្របសម្រួលវិធានការនិងយន្តការលើកទឹកចិត្តនិងស្មារតីទទួលខុសត្រូវ
	៣.៤. រៀបចំនិងសម្របសម្រួលទស្សនកិច្ចសិក្សានៅតាមការដ្ឋានកែទម្រង់ក្នុងនិងក្រៅប្រទេស

១.២.១.១. យុទ្ធសាស្ត្រទី១÷ សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ ៣ បូក ១

យុទ្ធសាស្ត្រនេះមានគោលដៅធ្វើឱ្យការងារកែទម្រង់ ៣ បូក ១ ក្លាយជា "ប្រព័ន្ធតួអង្គតែមួយ" ពោលគឺការងារកែទម្រង់ទាំង៤ អាចបំពេញការងាររៀងៗខ្លួន ដោយមិនជាន់គ្នា តែត្រូវប្រទាក់ក្រឡាគ្នា តាមរយៈយន្តការសម្របសម្រួលនិងសហការគ្នា ដើម្បីសម្រេចនូវចក្ខុវិស័យ បេសកកម្ម គោលបំណង និងកម្មវិធីនៃការងារកែទម្រង់នីមួយៗប្រកបដោយប្រសិទ្ធភាព។

ថ្វីត្បិតកម្មវិធីកែទម្រង់នីមួយៗ ស្ថិតក្រោមសមត្ថកិច្ចដឹកនាំអនុវត្តដោយក្រសួងដោយឡែកពីគ្នា សកម្មភាពកែទម្រង់ជាក់ស្តែងភាគច្រើន គឺអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀត ដែលនេះគឺជាលក្ខណៈពិសេសជាប្រព័ន្ធនិងប្រទាក់ក្រឡានៃកម្មវិធីកែទម្រង់ទាំង ៣ បូក ១ ខាងលើនេះ។ ទំនាក់ទំនងជាប្រព័ន្ធនិងប្រទាក់ក្រឡានេះមានមិនត្រឹមតែរវាងក្រសួង ស្ថាប័នដឹកនាំការងារកែទម្រង់ (តួអង្គនិម្មាបនករកែទម្រង់) ជាមួយនឹងក្រសួងស្ថាប័នអនុវត្តការងារកែទម្រង់ (តួអង្គប្រតិបត្តិករកែទម្រង់) តែប៉ុណ្ណោះទេ លើសពីនេះនឹងរឹតតែសំខាន់ជាងនេះនោះគឺទំនាក់ទំនងនិងភាពប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់នីមួយៗ ឬនិម្មាបនកម្មកែទម្រង់នីមួយៗតែម្តង គឺ***ការកែទម្រង់ ៣ បូក ១***។

ក. កំណត់និងរៀបចំមុខងារនិងរចនាសម្ព័ន្ធ

មុខងារនៅទីនេះ សំដៅដល់វិចារណកម្មមុខងារនៅក្នុងចំណោមក្រសួង ស្ថាប័នថ្នាក់ជាតិនិងការផ្ទេរមុខងាររវាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ការផ្ទេរមុខងារ តែងតែទាមទារឱ្យមានការគិតគូរទន្ទឹមគ្នានូវការផ្ទេរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ទើបការអនុវត្តមុខងារដែលត្រូវបានផ្ទេរអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធ-ភាពនិងស័ក្តិសិទ្ធភាព។

ក្នុងន័យនេះ កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនឹងការបង្កើនប្រសិទ្ធភាពនៃ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ការកែទម្រង់មុខងារនិងរចនាសម្ព័ន្ធ ជាអាទិ៍ការបង្កើត ការលុបចោល និងបញ្ចូលនូវរចនាសម្ព័ន្ធស្ថាប័ន ព្រមទាំងការបង្កើត ឬផ្ទេរមុខងារ រវាងថ្នាក់ជាតិ រវាងថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ទាំងពីរ ដែលអាចមានបច្ច័យលើការងារហិរញ្ញវត្ថុ ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

ខ. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ជាសត្យានុម័ត ការអនុវត្តមុខងារនិងភារកិច្ចរបស់ក្រសួង ស្ថាប័ន ត្រូវមានថវិកាគាំទ្រ។ នៅក្នុងបរិបទដែលសមិទ្ធកម្មក្លាយជាគោលដៅនៃការគ្រប់គ្រងក្នុងរដ្ឋបាលសាធារណៈកម្ពុជា ថវិកាមិនត្រឹមតែជាការគាំទ្រដល់ការបំពេញមុខងារនិងភារកិច្ចតែប៉ុណ្ណោះទេ តែថវិកាគឺជាឧបករណ៍នៃគោលនយោបាយ ឬថវិកាត្រូវផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ឬនិយាយម្យ៉ាងទៀត ការប្រើប្រាស់ថវិកាត្រូវសម្រេចលទ្ធផលដែលបានគ្រោងទុក។ នេះគឺជាគោលនយោបាយថវិកាសមិទ្ធកម្ម នៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដោយឡែក នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ ៣ បូក ១ ហិរញ្ញវត្ថុឬថវិកា ត្រូវគាំទ្រនិងមានសង្គតិភាពទៅនឹងគោលនយោបាយវិមជ្ឈការ គោលនយោបាយធនធានមនុស្ស និងគោលនយោបាយច្បាប់និងប្រព័ន្ធយុត្តិធម៌ផងដែរ។

កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនិងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានបច្ច័យលើមុខងារ រចនាសម្ព័ន្ធ ធនធានមនុស្ស និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាអាទិ៍ការរៀបចំរចនាសម្ព័ន្ធកម្មវិធីនិងរចនាសម្ព័ន្ធស្ថាប័ន ការផ្ទេរធនធានហិរញ្ញវត្ថុទៅតាមមុខងារ រចនាសម្ព័ន្ធ ឬធនធានមនុស្សដែលត្រូវបានផ្ទេរ។

គ. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស

ការកែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតទៅលើសមាសធាតុគន្លឹះចំនួន ៣ គឺ ការកែទម្រង់និងអភិវឌ្ឍសមត្ថភាពស្ថាប័ន ការកែទម្រង់ប្រព័ន្ធបៀវត្ស និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលសំដៅដល់មន្ត្រីរាជការ។ បេសកកម្មទាំង ៣ នេះ មានទំនាក់ទំនងនិងគាំទ្រដល់កម្មវិធីកែទម្រង់ ៣ ផ្សេងទៀតដោយផ្ទាល់ គឺ មុខងារ និងហិរញ្ញវត្ថុ។

ក្នុងន័យនេះ កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនិងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានបច្ច័យលើការកែទម្រង់មុខងារ រចនាសម្ព័ន្ធ ហិរញ្ញវត្ថុ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាអាទិ៍ការបំពាក់សមត្ថភាពក្នុងការអនុវត្តការងារកែទម្រង់ទាំង៤ ការបណ្តុះភាពជាអ្នកដឹកនាំនិងឆន្ទៈក្នុងការអនុវត្តការងារកែទម្រង់, ការផ្ទេរធនធានមនុស្សទៅតាមមុខងារនិងរចនាសម្ព័ន្ធ, ការលើកទឹកចិត្តតាមលទ្ធភាពហិរញ្ញវត្ថុដែលអាចទ្រទ្រង់បាន។

ឃ. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា

២០២១-២០៣៥ ដោយកំណត់យកចក្ខុវិស័យ "***កសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើក ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មីនិងលើកកម្ពស់សុខុមាលភាពសង្គមផ្អែកលើប្រក្រតីភាពតាមគន្លងថ្មី***"។ ក្របខ័ណ្ឌគោលនយោបាយនេះ ផ្តោតលើសមាសធាតុចំនួន ៥ ដែលចែកចេញជាគ្រឹះចំនួន២ (ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និងការកសាងទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល) និងសសរស្តម្ភចំនួន ៣ (ការកសាងពលរដ្ឋឌីជីថល ការកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល)។ ក្របខ័ណ្ឌគោលនយោបាយនេះ ត្រូវដឹកនាំអនុវត្តដោយក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថលដែលមាននាយករដ្ឋមន្ត្រីជាប្រធានដោយចែកចេញជាគណៈកម្មាធិការចំនួន ៣ គឺ គណៈកម្មាធិការសេដ្ឋកិច្ចឌីជីថលនិងធុរកិច្ចឌីជីថល គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល។

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ផ្នែកអភិបាលកិច្ចសាធារណៈ (Public Governance Reform) ដែលសំដៅដល់កម្មវិធីកែទម្រង់ជាប្រព័ន្ធ ៣ បូក ១ នេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនទៀតបាននិងកំពុងដំណើរការស្រាប់ ដែលរួមមានជាសារវ៉ន្តដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) ជាដើមដែលនៅក្នុងនោះមានអនុប្រព័ន្ធជាច្រើនទៀតដែលគាំទ្រដល់ប្រព័ន្ធមេទាំងនេះ មានដូចជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)។

កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនិងការបង្កើនប្រសិទ្ធភាពនៃការងារកែទម្រង់មុខងារ រចនាសម្ព័ន្ធ ហិរញ្ញវត្ថុ និងធនធាន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលអាចជាប្រព័ន្ធតែមួយ ឬប្រព័ន្ធដោយឡែកៗពីគ្នា។ រឹតសំខាន់ជាងនេះ អ្វីដែលជាគោលបំណងអាទិភាពនៅក្នុងកម្មវិធីមួយនេះនោះគឺការដាក់ចេញនូវសកម្មភាពពាក់ព័ន្ធនឹងសុខដុមនីយកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ ដើម្បីធានាថាប្រព័ន្ធទាំងនោះគាំទ្រឱ្យគ្នា សុខដុមនឹងគ្នា ប្រទាក់ក្រឡាគ្នា ដោយមិនប្រទាំងប្រទើសគ្នា ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពសម្រាប់គាំទ្រគោលនយោបាយរដ្ឋាភិបាលឌីជីថល និងគោលនយោបាយឌីជីថលជារួមរបស់រាជរដ្ឋាភិបាលគឺគោលនយោបាយសេដ្ឋកិច្ចនិងសង្គមដូចបានរៀបរាប់ខាងលើ។

១.២.១.២. យុទ្ធសាស្ត្រទី២: សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម

សមិទ្ធកម្ម គឺជាគោលដៅគន្លឹះនៃអភិបាលកិច្ចសាធារណៈនិងជាគោលដៅគន្លឹះនៃការកែទម្រង់ផងដែរ។ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការទទួលខុសត្រូវលើលទ្ធផល ឬនិយាយម្យ៉ាងទៀតគណនេយ្យភាពលើសមិទ្ធកម្ម គឺជាគោលដៅនៃដំណាក់កាលទី៤ ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់មួយនេះ។ ដោយឡែក សម្រាប់សេចក្តីព្រាងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ សមិទ្ធកម្មគឺជាមធ្យោបាយផងនិងជាគោលដៅចុងក្រោយផងដែលត្រូវបានលើកឡើងដូចជា ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ការលើកកម្ពស់ប្រសិទ្ធភាពនៃសមិទ្ធកម្មស្ថាប័នសាធារណៈ និងគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ជាដើម។ ទន្ទឹមនេះ ផ្អែកលើឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ កម្ពុជាបានជ្រើសរើសយក "ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម" (Performance Informed Budgeting) ជាទិសដៅជាក់-លាក់ ដើម្បីកសាងប្រព័ន្ធថវិការបស់ខ្លួនស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

ក្នុងន័យនេះ យុទ្ធសាស្ត្រនេះប្រមូលផ្តុំនូវកម្មវិធីនិងសកម្មភាពពាក់ព័ន្ធការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ជាអាទិ៍ការរៀបចំនិងសម្របសម្រួលអង្គភាពថវិកាឱ្យបន្ស៊ីគ្នាជាមួយមុខងារនិងរចនាសម្ព័ន្ធ, ការសម្របសម្រួលការងារសវនកម្មនិងអធិការកិច្ច, ការពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់ ៣ បូក ១ ព្រមទាំងការរៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ននិងគុណភាពសេវាសាធារណៈ។

ក. រៀបចំនិងសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា

អង្គភាពថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត។ ការងារដែលបាននិងកំពុងបន្តពង្រឹងនិងពង្រីក គឺការពិនិត្យលទ្ធភាពនិងវាយតម្លៃលក្ខណៈសម្បត្តិរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ននីមួយៗដើម្បីតម្លើងតួនាទីឱ្យទៅជាអង្គភាពថវិកាបន្ថែមទៀត, ការវាយតម្លៃលក្ខណៈសម្បត្តិនិងតម្លើងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, ការវាយតម្លៃដើម្បីពង្រឹងការអនុវត្តសិទ្ធិអំណាចរបស់អង្គភាពថវិកាជារួម និងចុងក្រោយគឺការពិនិត្យលើការរៀបចំនិងការអនុវត្តថវិកាកម្មវិធីជារួមរបស់ក្រសួង ស្ថាប័ន ជាពិសេស គឺការផ្សារភ្ជាប់ឱ្យកាន់តែមានប្រសិទ្ធភាពរវាងរចនាសម្ព័ន្ធគ្រប់គ្រងនិងរចនាសម្ព័ន្ធគោលនយោបាយ។

នៅក្នុងឆ្នាំ២០២៣ នេះ គណនេយ្យភាពរបស់អង្គភាពថវិកាចំពោះសមិទ្ធកម្មនឹងកើនឡើងមួយកម្រិតទៀតតាមរយៈការអនុវត្ត "កិច្ចព្រមព្រៀងសមិទ្ធកម្ម" (Performance Agreement)។ ស្របតាមទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកានិងធនធ្ន:នយោបាយខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៣ គឺជាឆ្នាំដំបូងនៃការចាប់ផ្តើមអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ នៅក្នុងក្រសួងចំនួន ៧ ដែលនឹងមានជា ៣កម្រិតនៃកិច្ចព្រមព្រៀង គឺ÷ ទី១) កិច្ចព្រមព្រៀងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួង ស្ថាប័ន, ទី២) រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួងស្ថាប័នសាមី និងទី៣) កិច្ចព្រមព្រៀងរវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា។

ខ. រៀបចំនិងសម្របសម្រួលការងារសវនកម្មនិងអធិការកិច្ច

សម្រាប់បរិបទកម្ពុជា សវនកម្មនិងអធិការកិច្ចគឺជាមុខងារគន្លឹះនៃប្រព័ន្ធត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ដែលអាចលម្អិតចេញជាបួនមុខងារបន្ថែមទៀត គឺសវនកម្មផ្ទៃក្នុង សវនកម្មផ្ទៃក្រៅ អធិការកិច្ចហិរញ្ញវត្ថុ និងអធិការកិច្ចទូទៅ។

សម្រាប់សវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជានិម្មាបនករនៃប្រព័ន្ធ ជាអ្នករៀបចំគោលនយោ-បាយនិងរៀបចំស្តង់ដារសវនកម្មផ្ទៃក្នុង សម្រាប់ក្រសួង ស្ថាប័នយកទៅអនុវត្តតាមរយៈអង្គភាពឬនាយកដ្ឋាន

សវនកម្មផ្ទៃក្នុងរបស់ខ្លួន។ សម្រាប់អធិការកិច្ចហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាសេនាធិការបច្ចេក-ទេសរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យ-សម្បត្តិរដ្ឋ។ សវនកម្មផ្ទៃក្រៅគឺជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិ។ ចុងក្រោយ អធិការកិច្ចលើគ្រប់វិស័យ ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាអធិការកិច្ចរបស់រាជរដ្ឋាភិបាលផ្អែកលើអភិក្រមតាមបណ្តឹង ផ្អែកលើហានិភ័យ តាមសំណើ មានភាពមិនប្រក្រតី និងតាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

ដោយឡែក នៅក្នុងគ្រប់ក្រសួង ស្ថាប័នថ្នាក់កណ្តាល សុទ្ធតែមានន្ធរនាយកដ្ឋានឬអង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពទទួលបន្ទុកអធិការកិច្ច ក្រោមឈ្មោះជាអគ្គាធិការដ្ឋាន។ នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏គ្រោងបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅក្នុងកម្រិតរដ្ឋបាលរាជធានី ខេត្តផងដែរ។

គោលបំណងនៃសុខដុមនីយកម្មការកែទម្រង់ ៣ ឫ ១ ត្រង់កម្មវិធីនេះ គឺសុខដុមនីយកម្មនៃការបំពេញមុខងារនិងភារកិច្ចសវនកម្មផ្ទៃក្នុង សវនកម្មផ្ទៃក្រៅ អធិការកិច្ចហិរញ្ញវត្ថុ និងអធិការកិច្ចទូទៅរបស់រាជរដ្ឋាភិបាលទាំងក្នុងក្របខ័ណ្ឌសុខដុមនីយកម្មផ្ទៃក្នុងក្រសួង ស្ថាប័នសាមីនីមួយៗ និងក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងរវាងក្រសួង ស្ថាប័នធ្វើសវនកម្ម/អធិការកិច្ចជាមួយនឹងក្រសួង ស្ថាប័នទទួលរងសវនកម្ម/អធិការកិច្ចផងដែរ។

គ. ពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់ ៣ ឫ ១

ការពិនិត្យនិងតាមដានសមិទ្ធកម្ម ជាក្របខ័ណ្ឌឬយន្តការដែលប្រើប្រាស់ន្ធវិធីសាស្ត្រនៃការវាយតម្លៃនិងផ្ទៀងផ្ទាត់មួយជាក់លាក់ន្ធវយុទ្ធសាស្ត្រ ឬផែនការសកម្មភាព ធៀបនឹងលទ្ធផលដែលសម្រេចបានពីការអនុវត្តជាក់ស្តែង ដោយមានការកំណត់ន្ធវក្របខ័ណ្ឌពេលវេលា សូចនាករសមិទ្ធកម្មគន្លឹះ គោលដៅ លទ្ធផលរំពឹងទុកជាក់លាក់។

សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការពិនិត្យវាយតម្លៃសមិទ្ធកម្មជាប្រចាំ ត្រូវបានរៀបចំ ដាក់ឱ្យអនុវត្ត ដោយផ្អែកលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនិងរបាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ននីមួយៗ។

ឃ. រៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ននិងគុណភាពសេវាសាធារណៈ

ប្រសិទ្ធភាពស្ថាប័ន សំដៅដល់លក្ខខណ្ឌដែលស្ថាប័នអាចសម្រេចការងាររបស់ខ្លួន តាមស្ថានភាពនិងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងស្ថាប័នរបស់ខ្លួនផ្ទាល់ ដូចជា÷

- អ្នកដឹកនាំកំណត់ន្ធវចក្ខុវិស័យ បេសកកម្ម គោលដៅច្បាស់លាស់សម្រាប់អ្នកអនុវត្តការងារ ហើយគួសបង្ហាញផ្លូវដើរនិងមធ្យោបាយ ទៅសម្រេចឱ្យបានន្ធវចក្ខុវិស័យ បេសកកម្ម គោលដៅទាំងនោះ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ប្រកបដោយផលិតភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព

- អ្នកដឹកនាំនិងគ្រប់គ្រងកំណត់និងរៀបចំប្រព័ន្ធនិងកិច្ចដំណើរការការងារ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធនិងមុខងារ ដោយបន្ស៊ីគ្នាជាមួយការកំណត់និងការបែងចែកការងាររបស់អ្នកអនុវត្តការងារ ព្រមទាំងយន្តការនៃការសម្រេចការងារ
- អ្នកអនុវត្តការងារមានសមត្ថភាពនិងឆន្ទៈសម្រេចបាននូវលទ្ធផលការងារតាមការរំពឹងទុកទៅតាមមុខងារនិងភារកិច្ចដែលត្រូវបានប្រគល់ឱ្យដោយស្ថាប័ន។

ប្រសិទ្ធភាពស្ថាប័ន ចូលរួមចំណែកសម្រេចបាននូវស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច ព្រមទាំងគោលដៅយុទ្ធសាស្ត្រទាំង៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពិសេសការពង្រឹងសមត្ថភាពនិងអភិបាលកិច្ចស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈការកសាងប្រព័ន្ធស្ថាប័នរដ្ឋ ឱ្យមានប្រសិទ្ធភាព ផលិតភាព ភាពឆ្លើយតប គណនេយ្យភាព និងតម្លាភាព ដើម្បីធានាប្រសិទ្ធភាពនៃអភិបាលកិច្ច និងការពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

១.២.១.៣. យុទ្ធសាស្ត្រទី៣÷ សុខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់ ៣ ឫក ១

តាមរយៈឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឫក ១ នេះ, យន្តការសម្របសម្រួលជាកិច្ចប្រជុំប្រចាំត្រីមាស ត្រូវបានពង្រឹងបន្ថែមដោយការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ ៣ ឫក១។ យន្តការសម្របសម្រួលដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការកែទម្រង់ចំនួន ៣ ត្រូវបានតម្លើងកម្រិតមកជាអនុក្រឹត្យ។

កិច្ចដំណើរការនៃការងារកែទម្រង់ ៣ ឫក ១ កាន់តែមានមូលដ្ឋាននិងយន្តការច្បាស់លាស់ជាងមុន។ សកម្មភាពពាក់ព័ន្ធនឹងប្រព័ន្ធដំណើរការនេះ នឹងត្រូវលម្អិតនៅក្រោមកម្មវិធីនីមួយៗនៃយុទ្ធសាស្ត្រទី៣នេះ។

ក. រៀបចំនិងសម្របសម្រួលកិច្ចដំណើរការនិងការគាំទ្រកម្មវិធីកែទម្រង់ ៣ ឫក ១

កិច្ចដំណើរការនៃយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវបានកំណត់ដោយអនុក្រឹត្យមួយដែលនៅក្នុងនោះបានបញ្ជាក់អំពីយន្តការផ្លាស់ប្តូរវេនប្រចាំត្រីមាសរវាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ, តួនាទីនិងភារកិច្ចរបស់ប្រធានទទួលវេន, ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ, របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ និងរបបកិច្ចប្រជុំ ជាដើម។

ខ. រៀបចំនិងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់ ៣ ឫក ១

ការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់៣ ឫក ១ អាចត្រូវបានរៀបចំក្នុងគោលបំណងច្រើនយ៉ាង ដូចតទៅ÷

- ការរៀបចំកម្មវិធីបណ្តុះបណ្តាលរួមគ្នារវាងកម្មវិធីកែទម្រង់ ៣ ឫក ១ ជូនថ្នាក់ដឹកនាំនិងមន្ត្រី-

រាជការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើប្រធានបទពាក់ព័ន្ធនឹងអភិបាលកិច្ចនិងជាពិសេស លើប្រធានបទដែលពាក់ព័ន្ធនឹងការងារអន្តរកែទម្រង់។ យន្តការនេះអាចរៀបចំទៅបានប្រកបដោយ ប្រសិទ្ធភាពដោយហេតុថាក្រសួងដឹកនាំកម្មវិធីកែទម្រង់នីមួយៗសុទ្ធសឹងតែមានទ្វរ្ការ:ស្ថាប័នបណ្តុះ-បណ្តាលរៀងៗខ្លួន ក្នុងនោះរួមមាន សាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណ: វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃ **ក.ស.ហ.ហ.** រាជបណ្ឌិត្យសភាវិជ្ជាជីវ:តុលាការនៃក្រសួងយុត្តិធម៌ និងសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ

- ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ឬពិភាក្សាលើប្រធានបទជាក់លាក់ណាមួយដែលមានលក្ខណ: អន្តរកែទម្រង់
- ការរៀបចំផ្សព្វផ្សាយ តាមរយ:ឧបករណ៍ផ្សេងៗដូចជា ខិតប័ណ្ណ វីដេអូ និងការផ្សព្វផ្សាយផ្សេងៗ ទៀតនៅតាមគ្រឹះស្ថានសិក្សា ចំពោះសាធារណជនជាទូទៅ។

គ. រៀបចំនិងសម្របសម្រួលវិធានការនិងយន្តការលើកទឹកចិត្តនិងស្វារតីទទួលខុសត្រូវ

សមិទ្ធកម្មគឺជាមូលដ្ឋាននៃវិធានការលើកទឹកចិត្តនិងការរឹតត្បិត។ ការលើកទឹកចិត្តកើតមាននៅពេលដែលសមិទ្ធកម្មឬលទ្ធផលបានសម្រេចតាមគោលដៅរំពឹងទុក ឬលើសពីគោលដៅ ឬអាចមានការចំណាយធនធានឬពេលវេលាតិចជាងការកំណត់។ ការរឹតត្បិតអាចកើតមាននៅពេលដែលលទ្ធផលរំពឹងទុកមិនត្រូវបានសម្រេច ឬក៏ការសម្រេចបានលទ្ធផលនោះបានចំណាយធនធាន ឬពេលវេលាលើសពីការកំណត់ទុកជាមុន។ ការលើកទឹកចិត្ត ឬរឹតត្បិត អាចមានរូបភាពក្រោមទម្រង់ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ដែលអាចជាការផ្តល់ជូនទ្វរ្សម្ភារ: មុខតំណែង កិត្តិយស ការសរសើរ ឬដំណើរទស្សនកិច្ចជាដើម។ ការអនុវត្តវិធានការបែបនេះគឺជាកត្តាមួយដែលចូលរួមចំណែកជំរុញឱ្យស្ថាប័នសាធារណ:និងការបម្រើសេវាសាធារណ:កាន់តែមានប្រសិទ្ធភាព។

ជាឧទាហរណ៍ជាក់ស្តែង នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ: មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ:ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ:នៃក្រសួង ស្ថាប័ន ក៏ប៉ុន្តែចំនួនអ្នកត្រូវទទួលបានប្រាក់ឧបត្ថម្ភ និងចំនួនប្រាក់ឧបត្ថម្ភត្រូវទទួលបានត្រូវផ្អែកលើគុណភាពនិងប្រសិទ្ធភាពនៃផែនការសកម្មភាពកែទម្រង់និងការអនុវត្តផែនការនេះ។

ឃ. រៀបចំនិងសម្របសម្រួលទស្សនកិច្ចសិក្សានៅតាមការដ្ឋានកែទម្រង់ក្នុងនិងក្រៅប្រទេស

ទស្សនកិច្ចសិក្សានៅក្នុងប្រទេស គឺជាការចុះទៅសង្កេតផ្ទាល់នៅតាមស្ថាប័ន អង្គភាព ឬរដ្ឋបាលថ្នាក់-ក្រោមជាតិ ដើម្បីពិនិត្យសិក្សាពីបទពិសោធន៍ជាក់ស្តែង វឌ្ឍនភាព កិច្ចដំណើរការ និងជាពិសេសបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តដែលត្រូវបានសម្រេចដោយរាជរដ្ឋាភិបាល។ ការចុះទស្សនកិច្ចនេះមានអត្ថប្រយោជន៍ចំពោះអ្នករៀបចំគោលនយោបាយនិងអ្នករៀបចំទិសដៅកែទម្រង់ ដើម្បី

ឯកសារមន្ត្រីសាធារណ: | https://t.me/oa_channel

បានយល់ដឹងពីសភាពការណ៍ពិតជាក់ស្តែងនិងផ្តល់ឱកាសពិចារណាអំពីការផ្សារភ្ជាប់រវាងគោលនយោបាយនិងប្រសិទ្ធភាពនៃការអនុវត្ត។

ដោយឡែក ទស្សនកិច្ចសិក្សានៅក្រៅប្រទេស ក៏ជាវិធីសាស្ត្រមួយទៀតដែលមិនអាចខ្វះបាន ដោយហេតុថាបេសកកម្មបែបនេះផ្តល់នូវមេរៀននិងបទពិសោធន៍ល្អៗជាឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីអាចដកស្រង់យកមកពិចារណា ពិនិត្យ និងសម្រួចរៀបចំនូវគោលនយោបាយទាំងឡាយតម្រូវសម្រាប់បរិការណ៍រដ្ឋបាលនិងសង្គមកម្ពុជា។

១.២.២. ប្រភពធនធានថវិកាគាំទ្រ

ដើម្បីអនុវត្តក្របខ័ណ្ឌផែនការសកម្មភាពខាងលើប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានដែលដឹកនាំលើសកម្មភាពនីមួយៗត្រូវទទួលខុសត្រូវលើការរៀបចំនិងគ្រោងធនធានថវិកាគាំទ្រ ដែលអាចត្រូវបានប្រើប្រាស់ពីប្រភពដូចខាងក្រោម÷

១. ថវិកាប្រចាំឆ្នាំនៃអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកម្មវិធីកែទម្រង់នីមួយៗ

២. ថវិកាគាំទ្ររបស់ដៃគូអភិវឌ្ឍន៍

៣. មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៤. ថវិការដ្ឋ

៥. ផ្សេងៗ។

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

១.៣. យន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ នៃរាជរដ្ឋាភិបាល

១.៣.១. សាវតារ

យន្តការសម្របសម្រួលរវាងលេខាធិការដ្ឋានកែទម្រង់ទាំង៣ ត្រូវបានបង្កើតឡើងជាផ្លូវការលើកដំបូង ដោយ សេចក្តីសម្រេចរួមរបស់ប្រធានគណៈកម្មាធិការកែទម្រង់ទាំង ៣ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ យន្តការនេះ មានគោលបំណងធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្ម នៃទំនាក់ទំនងការងារកែទម្រង់ទាំងបីនៃរាជរដ្ឋាភិបាល តាមរយៈការផ្លាស់វេនដឹកនាំកិច្ចប្រជុំដោយអគ្គលេខាធិការឬប្រធានលេខាធិការដ្ឋាន នៃកម្មវិធីកែទម្រង់នីមួយៗប្រចាំត្រីមាស។

ក្នុងឆ្នាំ២០១៨ យន្តការសម្របសម្រួលកម្មវិធីកែទម្រង់បី បានសម្រេចបញ្ចូលនូវកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលដឹកនាំដោយក្រសួងយុត្តិធម៌ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ដើម្បីបន្ថែមទិដ្ឋភាពកែទម្រង់គ្រឹះមួយទៀតនោះគឺច្បាប់និងយុត្តិធម៌ ដែលក្រោយមក យន្តការសម្របសម្រួលអន្តរកែទម្រង់នេះត្រូវបានប្រសិទ្ធនាមទៅជា "**យន្តការកែទម្រង់ ៣ ឫក ១**"។

កន្លងមក ការដឹកនាំនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវបានកំណត់ឱ្យផ្លាស់ប្តូរវេនប្រជុំជាទៀងទាត់រៀងរាល់មួយត្រីមាសម្តងរវាងលេខាធិការដ្ឋានទាំង៣។ យន្តការប្រចាំត្រីមាសដែលត្រូវបានបង្កើតឡើងគឺជាយន្តការពិភាក្សានិងដោះស្រាយបញ្ហាចំពោះមុខដោយមិនបានកំណត់លម្អិតអំពីយន្តការសម្របសម្រួលជាប្រចាំណាមួយ ដូចជារបបត្រួតពិនិត្យតាមដានការងារលម្អិតឬរបបរបាយការណ៍ជាក់លាក់នៅឡើយ។ ក្នុងន័យនេះ អនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ នៃរាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើង ដែលនឹងជំនួសសេចក្តីសម្រេចអន្តរក្រសួងខាងលើ។ អនុក្រឹត្យនេះនឹងពង្រឹងយន្តការអនុវត្តការងារកែទម្រង់ ៣ ឫក ១ ដែលកំណត់ហៅថា "**យន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ នៃរាជរដ្ឋាភិបាល**" ហៅកាត់ "**យ.ស.ក.**" ដោយបន្ថែមគុណតម្លៃថ្មីគន្លឹះចំនួន ៤ ដូចតទៅ÷

- បញ្ចូលជាផ្លូវការនូវលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្នុង **យ.ស.ក.**
- កំណត់មុខងារនិងភារកិច្ចនៃប្រធានផ្លាស់វេន ឱ្យបានលម្អិត
- ពង្រឹងយន្តការសម្របសម្រួល ទៅជាការតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព
- ពង្រឹងរបបប្រជុំនិងរបបរបាយការណ៍ឱ្យមានគណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពជាងមុន។

១.៣.២. មុខងារនិងតួនាទី

យ.ស.ក. ជាយន្តការដឹកនាំនិងសម្របសម្រួលផ្នាស់វេនប្រចាំត្រីមាសរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ÷

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើដំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **យ.ស.ក.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗ ព្រមទាំងលើកសំណើសកម្មភាពឬសំណើដំណោះស្រាយជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយ តាមបញ្ជារបស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
- រៀបចំនិងកំណត់របៀបវារៈប្រជុំ **យ.ស.ក.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- រៀបចំនិងធានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែ-ទម្រង់ខ្ពស់
- រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដែលបានកំណត់
- រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗ គឺជា "**ប្រធាន យ.ស.ក.**" ប្រចាំត្រីមាសនោះ។ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬអនុប្រធានលេខាធិការដ្ឋានទទួលបន្ទុកដឹកនាំជំនួសបាន។

ប្រធាន **យ.ស.ក.** ត្រូវធានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ខាងលើ ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។ ប្រធាន **យ.ស.ក.** ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមាន

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

ការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។ ប្រធាន **យ.ស.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួងដឹកនាំការងារកែទម្រង់នីមួយៗ ឬដៃគូអភិវឌ្ឍន៍នានា ចូលរួមប្រជុំបានតាមការចាំបាច់។

ក្នុងករណីចាំបាច់ឬមានការស្នើសុំ ការទទួលនិងដឹកនាំសម្របសម្រួលប្រចាំត្រីមាសអាចរៀបចំក្រោមទម្រង់ជាសហប្រធាន ដែលជាតំណាងអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ខាងលើ។

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាពដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួនក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយ-ការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីធានាការចូលរួមអនុវត្ត **យ.ស.ក.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

១.៣.៣. ការរៀបចំផែនការសកម្មភាពនិងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព

យ.ស.ក. ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។ ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្តាហ៍ទី៤ នៃឆ្នាំបន្ទាប់។ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១ នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំនិងបូកសរុបផែនការសកម្មភាព ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុបត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវទទួលបន្ទុកសម្របសម្រួលនិងបូកសរុបរបាយការណ៍វឌ្ឍនភាពដែលស្ថិតក្រោមការទទួលបន្ទុករបស់ខ្លួន និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន ឬលេខា-ធិការដ្ឋានដែលជាប្រធានទទួលវេន យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែបន្ទាប់ ដើម្បីបូកសរុបសម្រាប់កិច្ចប្រជុំប្រចាំត្រីមាស។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំងបួន អាចចេញសេចក្តីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

១.៣.៤. កិច្ចប្រជុំប្រចាំត្រីមាស

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាសត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **យ.ស.ក.** នៃត្រីមាសបន្ទាប់។

របាយការណ៍កិច្ចប្រជុំត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេន ដើម្បី

ពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យ និងសហការអនុវត្ត។

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **យ.ស.ក.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

ក្នុងករណីដែលអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខានឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស តាមថិរវេលាខាងលើ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត អាចមានសិទ្ធិទទួលភារកិច្ចជំនួសបាន ដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

១.៣.៥. យន្តការសម្របសម្រួលកម្រិតមន្ត្រីបង្គោលបច្ចេកទេស

យ.ស.ក. គឺជាអង្គសម្រិតសម្រាំងបញ្ហាប្រឈមនិងលើកសំណើជាជម្រើសដំណោះស្រាយជូនប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ។ ជាធម្មតា យន្តការនេះត្រូវជួបប្រជុំជាប្រចាំត្រីមាសនិងប្រចាំឆ្នាំ ឬតាមការចាំបាច់។ ដោយឡែក ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃកិច្ចដំណើរការប្រចាំថ្ងៃនៃការងារកែទម្រង់ ៣ បូក ១នេះ យន្តការសម្របសម្រួលកម្រិតបច្ចេកទេសមួយ ត្រូវបានបង្កើត ក្នុងកម្រិតមន្ត្រីបច្ចេកទេសធ្វើការរួមគ្នា។

អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ អាចរៀបចំតែងតាំងសមាសភាពមន្ត្រីបង្គោលកម្រិតបច្ចេកទេសរបស់សាមីអង្គភាពនីមួយៗ សម្រាប់ **យ.ស.ក.**។

មន្ត្រីបង្គោលកម្រិតបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ មានមុខងារនិងភារកិច្ច ដូចតទៅ÷

- សម្របសម្រួលនិងសហការជាមួយនឹងមន្ត្រីបង្គោលនៃលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតដើម្បីពិនិត្យនិងពិភាក្សារៀបចំរបាយការណ៍ ឯកសារនានា និងជាពិសេសរបៀបវារៈ សម្រាប់កិច្ចប្រជុំប្រចាំត្រីមាស នៃ **យ.ស.ក.**
- រៀបចំនិងដឹកនាំកិច្ចប្រជុំក្នុងកម្រិតបច្ចេកទេស ជាមួយនឹងក្រុមមន្ត្រីបង្គោលនៃលេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត តាមវេនប្រចាំត្រីមាសដែលត្រូវទទួលបន្ទុកនិងតាមការចាំបាច់
- ចូលរួមកិច្ចប្រជុំក្នុងកម្រិតបច្ចេកទេសតាមការកោះប្រជុំរបស់ក្រុមមន្ត្រីបង្គោលនៃអគ្គលេខាធិការ-ដ្ឋានឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដែលជាប្រធានទទួលវេនប្រចាំត្រីមាសនីមួយៗ
- រៀបចំជំនួយស្មារតីនិងបូកសរុបរបាយការណ៍ សម្រាប់និងមុនកិច្ចប្រជុំប្រចាំត្រីមាសនីមួយៗ
- សម្របសម្រួលនិងសហការជាមួយនឹងលេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត តាមការចាំបាច់។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

គួរបញ្ជាក់ថា ក្រុមមន្ត្រីបង្គោលនៃលេខាធិការដ្ឋានកែទម្រង់ដែលត្រូវដឹកនាំវេនប្រចាំត្រីមាស គឺជាអ្នកទទួលខុសត្រូវដឹកនាំនិងកោះហៅប្រជុំក្រុមមន្ត្រីបង្គោលផ្សេងទៀត នៅក្នុងត្រីមាសនោះ។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

សន្និដ្ឋាន

ឯកសារ ចក្ខុវិស័យនិងយុទ្ធសាស្ត្រសុខដុមនីយកម្មការកែទម្រង់ ៣ ឃ្លីក ១ នេះ គឺជាឯកសារមគ្គទេសក៍ បង្ហាញផ្លូវរួមគ្នាលើកទី១ របស់កម្មវិធីកែទម្រង់ទាំង ៤ ដែលជាសក្តានុពលនៃការប្តេជ្ញាចិត្តនិងឆន្ទៈខ្ពស់របស់រាជ-រដ្ឋាភិបាលកម្ពុជាក្នុងការតម្កល់ការងារកែទម្រង់ជាការងារអាទិភាពខ្ពស់មួយ។ ក្នុងន័យម្យ៉ាងទៀត រាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែធ្វើកំណែទម្រង់ដោយបង្កើតជាការដ្ឋានឬកម្មវិធីកែទម្រង់ជាប្រព័ន្ធ នៅតាមវិស័យនីមួយៗនោះទេ តែលើសពីនេះ រាជរដ្ឋាភិបាលផ្តោតអាទិភាពលើការធានាសង្គតិភាពនិងសុខដុមភាពរវាងកម្មវិធីកែទម្រង់ទាំងនោះ ដើម្បីធានា ជំរុញល្បឿននៃកំណែទម្រង់អភិបាលកិច្ចល្អ ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

ជាសត្យានុម័ត ការអនុវត្តកម្មវិធីកែទម្រង់នីមួយៗ ដែលរួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មានចរិតលក្ខណៈប្រទាក់ក្រឡា ស៊ីជម្រៅ ស្មុគស្មាញ និងមានបញ្ហាប្រឈមច្រើនដែលទាមទារឆន្ទៈនិងជំនាញសម្របសម្រួលស្វែងរកដំណោះស្រាយខ្ពស់ រួចស្រេចទៅហើយ ចំណែកឯការរៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ យន្តការការងារ និងផែនការសកម្មភាពដែលផ្តោតលើសុខដុមនីយកម្មរវាងកម្មវិធីកែទម្រង់ទាំងអស់ខាងលើនេះ ពិតជាមានភាពស្មុគស្មាញទ្វេដងឬច្រើនដង។

ទោះបីយ៉ាងណា ក្នុងឆន្ទៈកែទម្រង់ខ្ពស់ ក្នុងស្មារតីរៀនផង ធ្វើផង និងដោយមិនយកភាពឥតខ្ចោះធ្វើជាឧបសគ្គ, ឯកសារមគ្គទេសក៍នេះអាចផ្តល់ពន្លឺបន្ថែមដល់តួអង្គអ្នកអនុវត្តពាក់ព័ន្ធទាំងឡាយ ទាំងនិម្មានករនិងប្រតិបត្តិករនៅក្នុងការដ្ឋានកែទម្រង់ ៣ ឃ្លីក ១ សម្រាប់ឆ្លុះបញ្ចាំងនិងដកស្រង់បទពិសោធន៍ពីការអនុវត្តព្រមទាំងកំណត់ឱ្យបានជាក់លាក់នូវបញ្ហាប្រឈមស្មុគស្មាញដែលអាចនឹងកើតមានឡើង ជួយសម្រួលដល់ការសិក្សានិងស្វែងរកគន្លឹះដំណោះស្រាយ នាដំណាក់កាលបន្ទាប់ទៀត។

លេខ:.....

ថ្ងៃ ខែបុណ្យភាគដាច ឆ្នាំរកា ០០ ២០១៨

រាជធានីភ្នំពេញ ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៨

ឃោសការណ៍

ស្តីពី

លទ្ធផលនៃ សិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល

ការណីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ... ...

សំដៅឆ្ពោះទៅកាន់ការកសាងវឿនសេដ្ឋកិច្ចទំនើបមួយរបស់កម្ពុជា ឈរលើគោលការណ៍ និងយន្តការសេដ្ឋកិច្ចទីផ្សារបើកចំហ ហើយប្រើការគ្រប់គ្រងយន្តការសេដ្ឋកិច្ចទីផ្សារនេះ ឱ្យបម្រើផលប្រយោជន៍ប្រជាជនគ្រប់ស្រទាប់ សំដៅធានាឱ្យប្រជាជាតិកម្ពុជាតាំងមូល អាចក្លាយជាប់ជាប់ និងធ្វើជាម្ចាស់យ៉ាងពេញលេញ លើជោគវាសនារបស់ខ្លួន ក្នុងភាពថ្លៃថ្នូរ ឥតម្រើនុងរឿង។ មហាសមិទ្ធផលនេះ មិនអាចកើតឡើងដោយឯកឯង ឬក្នុងការលះបង់កំលាំងកាយចិត្តបានឡើយ ទាំងសំណាក់យុវជនជំនាន់មុន ជាពិសេសគឺក្រោមអត្តមត្ថទ្ទេសកំនត្តុង្គនត្ថមរបស់ អត្តមហាវរជ្ជបុរសនៃយើងទាំងអស់ក្នាតី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានលើកទឹកចិត្តឱ្យយុវជនទាំងអស់ក្នុងសិក្ខាសាលាយកចិត្តទុកដាក់លើខ្លឹមសារនៃបទបង្ហាញ និងចូលរួមក្នុងវគ្គពិភាក្សាឱ្យបានផុសផុល។

ឯកឧត្តម **សាយ សំអាត** បានថ្លែងអំណរគុណចំជ្រាលជ្រៅចំពោះការយាងនៃកំណែទម្រង់ទាំងបួនរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំកម្មវិធីដ៏មានន័យមួយ និងសារៈសំខាន់នេះ។ ឯកឧត្តម ក៏បានគូសបញ្ជាក់ផងដែរថា គោលបំណងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍយុវជនកម្ពុជា ពីប្រែក្លាយយុវជនទៅជាពលរដ្ឋល្អសម្រាប់ប្រទេសជាតិ តាមរយៈ÷

១. ការទទួលបានការអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
២. ការលើកទឹកចិត្តឱ្យមាន ឧត្តុសាហកម្ម ការច្នៃប្រឌិតផ្សេងៗ
៣. ការលើកកំពស់យេនឌ័រ
៤. ការអភិវឌ្ឍកាយសម្បទា ចំណេះដឹង និងសីលធម៌ និង
៥. ការបង្កឱ្យមានការចូលរួមបរិច្ចាគមតិ។

ឯកឧត្តម **លៅ សីលង់** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានគូសបញ្ជាក់ថាការរៀបចំសិក្ខាសាលានេះ ជាឱកាសមួយ ដែលអគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់ទាំងបួន បានប្រមូលផ្តុំបង្កើតជាសិក្ខាសាលាក្នុងក្របខ័ណ្ឌរួមដើម្បីចែករំលែកបទពិសោធន៍ដល់យុវជនដែលជាកំលាំងស្នូលនិងជាអ្នកបន្តវេនរបស់ប្រទេសជាតិ។

ខ. ឯកត្តមតបណ្ដាញ

វគ្គពេលព្រឹកនៃសិក្ខាសាលាបានប្រមូលផ្តុំដោយបទបង្ហាញអំពីការងារកែទម្រង់ស្នូលទាំង ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយវាគ្មិនដ៏មានគុណវុធិបរិបូរ ក្នុងនាមជាអ្នកកាន់ការដោយផ្ទាល់ លើការងារកែទម្រង់ជាតន្ត្រីទាំង ៤ ដែលមានដូចជា÷

១. ឯកឧត្តម **ឆាន់ សុគី** ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានបង្ហាញយ៉ាងជាក់ច្បាស់ថា ដើម្បីបុព្វហេតុនៃការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ឱ្យមានគុណវុធិនិងស្តង់ដារវិជ្ជាជីវៈស្របតាមនិន្នាការអន្តរជាតិ, ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងការអភិវឌ្ឍយន្តការស្ថាប័ន ប្រកបដោយវិចារណញ្ញាណ ប្រសិទ្ធភាព និងកិច្ចដំណើរការជាប្រព័ន្ធ នៃស្ថាប័នសាធារណៈ, ការកែទម្រង់បានសម្រេចជាសារវន្ត ឆ្ពោះការកែលម្អប្រព័ន្ធបៀវត្សនិងប្រាក់បំណាច់ឋានៈ (មានការដំឡើងបៀវត្សមន្ត្រីរាជការដល់លើសពីមួយលានរៀល, ការបើកបៀវត្សទៀងទាត់និងដល់សមិទ្ធនៃ)ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ការរៀបចំជាថ្មីនូវប្រព័ន្ធ

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

មុខងារសាធារណៈ អង្គវិជ្ជាធរ: ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីរាជការ ការគ្រប់គ្រងកិច្ចដំណើរការនៃវិចារណកម្ម/សមិទ្ធកម្មស្ថាប័ន ជាដើម។

២. ឯកឧត្តម **សាត់ សេដ្ឋា** រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរំលេចឡាស់ថា នៅក្នុងបុព្វហេតុនៃការលើកឧត្តេជ្ញាទ្វីប្រជាធិបតេយ្យសេរីពហុបក្ষ និងការផ្តល់សេវាសាធារណៈ រួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន, ការកែទម្រង់សម្រេចបានសមិទ្ធផលគួរជាទីកត់សម្គាល់ ជាអាទិ៍ ការរៀបចំក្របខ័ណ្ឌច្បាប់និងបទដ្ឋានអនុវត្តយន្តការស្ថាប័ននិងការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ កិច្ចដំណើរជាប្រក្រតីនៃការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចដំណើរការជាប្រក្រតីនៃការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចដំណើរការនៃការផ្ទេរនិងប្រតិភូកម្មមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការបង្កើតសិទ្ធិអំណាចនិងការទទួលទុនត្រូវ ក្នុងវិស្ថិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមៃជ្ឈការហិរញ្ញវត្ថុ នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជាដើម។

៣. ឯកឧត្តម **ម៉ូ ឌឌ្ឍសុទ្ធា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចង្អុលបង្ហាញថា ដើម្បីសម្រេចបានប្រព័ន្ធថវិកាមួយ ដែលមានប្រសិទ្ធភាពពេញលេញនៃការគោរពវិន័យថវិកា សុក្រិតិទ្ធភាពនៃការវិភាជន៍ថវិកា ព្រមទាំងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ, ការកែទម្រង់សម្រេចបានពេញលេញនូវ ភាពជឿទុកចិត្តបាននៃថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ព្រមទាំងកំពុងផ្សារភ្ជាប់កាន់តែជិតស្និទ្ធរវាងថវិកានិងគោលនយោបាយ ពោលគឺកំណើនសេដ្ឋកិច្ចរក្សាបាន ជុំវិញ ៧% ក្នុងមួយឆ្នាំ អតិផរណាទាបអាចគ្រប់គ្រងបានជុំវិញ ៣.៥% ក្នុងមួយឆ្នាំ មូលដ្ឋានចំណូលកាន់តែទូលាយនិងគ្រប់គ្រាន់កាន់តែមានប្រសិទ្ធភាព រីឯចំណាយកាន់តែមានលទ្ធភាពទូលំទូលាយជាងមុនទៅទៀត ជាមួយនឹងការគោរពវិន័យនិងនាគារប្រសិទ្ធភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ពិសេសជួយគាំទ្រដល់ការអនុវត្តគោលនយោបាយ និងលុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល កាន់តែចំគោលដៅអាទិភាព ធ្វើយ៉ាងបានទាន់សភាពការណ៍ចំពោះមុខ និងទាន់ពាក្យការចាំបាច់ ក្នុងជាការគាំទ្រដល់ការកែទម្រង់តាមវិស័យអាទិភាពនានាជាដើម។

៤. ឯកឧត្តម **ជ ម៉ារ៉ា** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានគូសបញ្ជាក់ថា នៅក្នុងបុព្វហេតុនៃការពង្រឹងនីតិរដ្ឋ និងការធានាយុត្តិធម៌សង្គម, ការកែទម្រង់សម្រេចបានសមិទ្ធផលយ៉ាងច្រើន ជាអាទិ៍ ការធ្វើទំនើបកម្មប្រព័ន្ធខ្នែងសំខាន់ៗនៃលក្ខណៈសម្បត្តិនៃនីតិរដ្ឋ ការពង្រឹងរចនាសម្ព័ន្ធស្ថាប័ននៃវិស័យយុត្តិធម៌ ការលើកកម្ពស់ការយល់ដឹងនិងការគោរពច្បាប់ ទាំងក្នុងកម្រិតក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ព្រមទាំងការផ្តល់សេវាយុត្តិធម៌ ទាំងក្នុងនិងក្រៅប្រព័ន្ធតុលាការ ដល់ប្រជាពលរដ្ឋ ឱ្យកាន់តែកៀកកិត ជិតស្និទ្ធ និងកាន់តែមានប្រសិទ្ធភាព តម្លាភាព នៅនឹងមូលដ្ឋាន ពិសេស ពលរដ្ឋជាយរងគ្រោះ។

ក្នុងស្មារតីជារួម ការដ្ឋានកែទម្រង់ទាំងបួន បានរំលេចយ៉ាងច្បាស់និងព្រមព្រាងនូវ ទស្សនវិស័យ តម្រៅអនាគត ប្រកបដោយគោលបំណងដ៏មហិច្ឆតា ដោយផ្សារភ្ជាប់ជាមួយនឹងលទ្ធភាពប្រកាសនិយមជាក់ស្តែង ឆន្ទៈនយោបាយ ហេតុផលកម្ពុជា សមត្ថភាពមនុស្សនិងស្ថាប័ន ស្មារតីនៃភាពជាម្ចាស់ ការទទួលទុនត្រូវគ្នាស់ សម្បជញ្ញៈនៃភាពបន្ទាន់និងស្មារតី

គម្រង់ឱ្យចំគោលដៅអាទិភាពនៃការកែទម្រង់ ក្នុងបុព្វហេតុរួមនៃវឌ្ឍនភាពសង្គមនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល លើកម្មវិធីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

គ. ឯកត្តជិតារក្សា ធ៥ សួ-ធ្លើយ

នៅក្នុងវេទិកាពិភាក្សា និង សួ-ធ្លើយ ត្រូវបានរៀបចំឡើងនាពេលរៀល ហើយសម្របសម្រួលដោយ ឯកឧត្តម បណ្ឌិត **ម៉ាលីណ ម៉ារ៉ែត** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ អ.ស.ហ ក្នុងរយៈពេល ២ ម៉ោង និងពាក់កណ្តាល, យុវជនជាសិក្ខាកាមរបស់យើង បានចោទជាសំណួរយ៉ាងច្រើនពាក់ព័ន្ធនឹងចាប់អារម្មណ៍ មកកាន់វាគ្មិន ដែលបង្ហាញពីការយកចិត្តទុកដាក់របស់យុវជនយើងលើការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា *(ខ្ទឹមសារសំណួរមានការភ្ជាប់មកជាមួយ)*។

ជារួម អង្គសិក្ខាសាលាបានជជែក ផ្លាស់ប្តូរ គិតគូ ពិភាក្សា ចោទសួរ ឆ្លើយស្រាយ ប្រកបដោយស្មារតីជាវិជ្ជាជីវៈ ទាន់ចិត្ត និងក្រមសីលធម៌ល្អ។ ជារួម ពាក់កណ្តាលនៃវេទិកាសួ-ធ្លើយ ខ្ទឹមសារសំខាន់ៗត្រូវបានផ្ទុះសេចក្តីឡើងជាទស្សនៈ ពាក្យប្រភេទជួចខាងក្រោម÷

១. **ពីពិតភាពនៃតំណាក់ការកែទម្រង់នានា÷** វេទិកាពិភាក្សា បានក្លាយទៅជាមូលដ្ឋាននៃការរៀនសូត្រ ដ៏ស្រស់ បិទពីសោធន៍ពីគ្នាទៅវិញទៅមក ប្រកបដោយភាពសម្ព្រះបែបនិងទុសប្លែកៗពីគ្នា រវាងយុវជន និងអ្នកកែទម្រង់ ក៏ជួចជារវាងអ្នកកែទម្រង់ ក្នុងការដ្ឋានទាំងបួន ដោយបានទម្លុះរនាំងតំនិត ទម្លាយរាំងវិជ្ជា នៃការកែទម្រង់ នៅតាមការដ្ឋានមួយ។ ផ្ទើម្ស ស្ដែងចេញនូវលំហូរមៀននិងបទពិសោធន៍ជាច្រើន ទាំងជោគជ័យ ទាំងការប្រឈមនានា ដែលមិនទាន់ទទួលបានជោគជ័យ ដែលក្នុងនោះមានបញ្ហាជាមូលដ្ឋានជាច្រើនមានលក្ខណៈប្រហាក់ប្រហែលគ្នា ជាអាទិ៍ ភាពជាអ្នកដឹកនាំ ធនធានដឹកនាំ ស្ថានភាពជាម្ចាស់ សមត្ថភាពមនុស្ស និងរចនាសម្ព័ន្ធស្ថាប័ន កិច្ចសម្រប សម្រួលស្ថាប័ន និងអន្តរស្ថាប័នជាដើម។

២. **អន្តរសកម្មនៃការពឹងផ្អែកគ្នាទៅវិញទៅមក រវាងការកែទម្រង់នានា÷** នៅក្នុងបរិការណ៍មួយចំនួន ការកែទម្រង់មួយ អាចសម្រេចវឌ្ឍនភាពទៅមុខបាន លុះត្រាតែត្រូវពឹងផ្អែកលើសមិទ្ធផលនៃការកែទម្រង់មួយទៀត ដែលមានទំនាក់ទំនងជ្យរភ្ជាប់គ្នាទៅវិញទៅមកជាប់មិនដាច់ និងឆ្លើយឆ្លងគ្នាទៅវិញទៅមក។ ជាក់ស្ដែង ការផ្ទេរមុខងារ ឬប្រតិភូកម្មមុខងារ ពីរដ្ឋបាលថ្នាក់ជាតិ ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាមទារឱ្យមានការគិតគូររៀបចំនិងអនុវត្ត ក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានមនុស្សនិងបញ្ជាធនធានហិរញ្ញវត្ថុភ្ជាប់ទៅជាមួយ។ ឯការផ្ទេរធនធានមានភ្ជាប់ លក្ខខណ្ឌ អាចចោទជាបញ្ហានៃការរៀបចំដំហានៃការកែទម្រង់រឿមជ្ជការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចលាតទៅដល់ គណនេយ្យភាពសមិទ្ធកម្ម មុនរដ្ឋបាលថ្នាក់ជាតិ ទៅក្នុងការកែទម្រង់ប្រព័ន្ធថវិកា។ ម្យ៉ាងទៀត សេវាយុត្តិធម៌ ក្នុងឬក្រៅប្រព័ន្ធតុលាការ អាចសម្រេចទៅបានដោយប្រសិទ្ធភាព លុះត្រាតែការតាំងត្រូវផ្ទែកហិរញ្ញវត្ថុ ត្រូវបានផ្ដល់ជូនទន្ទឹមគ្នានឹងការបង្កើតមុខងារផ្ដល់សេវាយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ ឬការពង្រឹងសមត្ថភាពរដ្ឋបាល តុលាការ ក្នុងការទទួលយកនូវសិទ្ធិអំណាចនិងការទទួលទុសត្រូវជាអង្គភាពថវិកា។

៣. **អន្តរសកម្មនៃការតាំងត្រឡប់ឱ្យគ្នាទៅវិញទៅមករវាងការកែទម្រង់នានា÷** ក្នុងបរិការណ៍មួយចំនួនទៀត វឌ្ឍនភាពនៃការកែទម្រង់មួយ នឹងផ្ដល់ជាកម្លាំងតាំងត្រ ដល់ការសម្រេចលទ្ធផលនៃការកែទម្រង់មួយទៀត នោះដោយផ្ទាល់ឬប្រយោលក្តី។ ភ្ជាប់ជាមួយ ការកសាងវិសាមញ្ញ ដែលបានមកពីការកែទម្រង់រដ្ឋបាលសារពើពន្ធ និងការពង្រឹងប្រព័ន្ធប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ជួចជាទ្រព្យសម្បត្តិដែលតុលាការរឹប

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

អ្នកសុកជាទ្រព្យសម្បត្តិរដ្ឋ នឹងផ្តល់លទ្ធភាពដល់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌កាន់តែមានថវិកាគាំទ្រប្រសើរឡើង។ រីឯការផ្តល់សិទ្ធិអំណាចនិងការទទួលទុសត្រូវលើការរៀបចំនិងអនុវត្តថវិកាដល់រដ្ឋបាលតុលាការ ជាមួយនឹងសមាជិកម្ចីនីតិវិធីហិរញ្ញវត្ថុ នឹងអនុញ្ញាតឱ្យស្ថាប័នតុលាការមានលទ្ធភាពបម្រើសេវាយុត្តិធម៌ កាន់តែមានប្រសិទ្ធភាព ឆាប់រហ័សជាងមុន។ ម្យ៉ាងទៀត ការកែទម្រង់ប្រព័ន្ធបៀវត្សនិងប្រព័ន្ធបុគ្គលិកសាធារណៈ បានផ្តល់ជូនភាពថ្មីដល់មន្ត្រីរាជការ ក្នុងការទទួលរួមចំណែកកាន់តែសកម្ម ក្នុងការងារកែទម្រង់ ពាក់ព័ន្ធរវាងភាពជាម្ចាស់ ជ្ងមជាវិស័យអប់រំ សុខាភិបាល សង្គមកិច្ច វប្បធម៌ បរិស្ថានជាដើម។

អាស្រ័យហេតុនេះ ទំនាក់ទំនងជាអន្តរសកម្ម នៃការកែទម្រង់នេះ ហាក់ដូចជាបានបង្កើតនៅជាសង្វាក់ផ្ទៃនៃគុណធម៌ ឬ គុណវុធ (Virtuous Circle) ដែលគុណបំណាច់នៃការកែទម្រង់មួយ នឹងផ្តល់ជាគុណប្រយោជន៍ដល់ការជ ំរុញល្បឿននៃការកែទម្រង់មួយទៀត នៅក្នុងរង្វង់នៃការគាំទ្រ ទាំងពីផ្នែកក្នុងនៅវិញនៅមក ទន្ទឹមនឹងនេះ ក៏ហាក់ដូចជាបានត្រូវគ្រាយមាត់ដោះស្រាយការប្រឈម ឆ្ពោះទៅរកនិន្នាការនៃការផ្សារភ្ជាប់ទំនាក់ទំនងនៃការកែទម្រង់ផ្សេងៗគ្នា ឱ្យកាន់តែជិតស្និទ្ធ ទៅលើមាត់ទឹកនាំពីអន្តរការដ្ឋានៃការកែទម្រង់ ទៅកាន់ការដ្ឋានអន្តរកែទម្រង់។

ដើម្បីវាយតម្លៃទៅលើការរៀបចំអង្គសិក្ខាសាលាទាំងមូល ក្រមសំណួរស្ទាបស្ទង់លើមតិរបស់យុវជនលើសិក្ខាសាលាទាំងមូល ត្រូវបានរៀបចំ សម្រាប់ប្រមូលជាទិន្នន័យសម្រាប់ការរៀបចំសិក្ខាសាលានេះឱ្យកាន់តែល្អប្រសើរ។ ជាលទ្ធផល អង្គសិក្ខាសាលា ទទួលបានការពេញចិត្តខ្ពស់ពីសំណាក់យុវជន ស.ស.យ.ក ដែលបានចូលរួម លើការរៀបចំ សម្របសម្រួល រៀបរៀងនូវ ខ្លឹមសារនៃអង្គសិក្ខាសាលា ជាពិសេសគឺការផ្តួចផ្តើមឱ្យមានសិក្ខាសាលានេះផ្ទាល់តែម្តង។ ជាពិសេស យុវជនលើសពី ៨០% បានយល់ថាសិក្ខាសាលានេះពិតជាមានសារៈសំខាន់ដល់ពួកគេ និងស្ទើរតែ ១០០% នៃយុវជននឹងចែករំលែកចំនេះ និងបទពិសោធន៍ទាំងនេះ ហើយនឹងចង់ឱ្យមានសិក្ខាសាលានេះបានទៅដល់សហគមន៍របស់ពួកគាត់។ ដោយឡែកអ្វីដែលជាចំណុចទុនៈអាចតម្រូវឱ្យការកែប្រែនោះគឺ តម្រូវបន្ថែមរយៈពេលនៃការរៀបចំកិច្ចពិភាក្សា និងបទបង្ហាញឱ្យបានច្រើនជាងនេះ។

យ. ការសន្និដ្ឋាន

ជាកិច្ចបញ្ចប់ បន្ទាប់ពីបានស្តាប់នូវរបាយការណ៍ក្រុមសរុបលទ្ធផលនៃសិក្ខាសាលា រួចមក **សម្តេចក្រឡាហោម ស ខេង** នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានសាទរនឹងលទ្ធផលនៃការរៀបចំសិក្ខាសាលានេះ ដែលជាទម្រង់នៃការបញ្ជ្រាបពុទ្ធិ ក៏ដូចជាកិច្ចដឹកនាំរបស់រាជរដ្ឋាភិបាលទៅកាន់យុវជន ជាពិសេស គឺជាសារជល់យុវជនឱ្យមានចំណាប់ខ្លាំង, ចូលរួម, ជួយ, ជ្រោមជ្រែង, កម្មវិធីកំណែទម្រង់ដែលសម្តៅដល់ការអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនតទៅទៀត។ លើសពីនេះ សម្តេចក្រឡាហោម ក៏បានគូសបញ្ជាក់នូវបុរេលក្ខខណ្ឌ និងលក្ខខណ្ឌសំខាន់ៗសម្រាប់ទីសង្គមនៃកម្មវិធីកំណែទម្រង់ ដូចជា÷

១. ការបន្តរក្សាបានសន្តិភាព ស្ថេរភាពនយោបាយ និងការពង្រឹងបានតួនាទីប្រជាធិបតេយ្យសេរីពហុបក្ស ជាបុរេលក្ខខណ្ឌដ៏ចាំបាច់សម្រាប់ការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយភាពជោគជ័យ។

២. តួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្តេជ្ញាលើកិច្ចការងារកំណែទម្រង់ ព្រោះថាវាមិនមែនជាកិច្ចការងារដោយស្រួលទេ គឺហាក់ដូចជាការុះជ ី និងជួសជុលផ្ទះ ដែលកំពុងមានមនុស្សស្នាក់នៅយ៉ាងណាមួយនោះដែរ។

ខ. ការរៀបចំ និងអនុវត្តយន្តការនៃការងារកំណែទម្រង់ទាំងបី ដែលមានកំណែទម្រង់រៀបចំការ និងវិសហមជ្ឈការ និងវិសហមជ្ឈ-ការ, កំណែទម្រង់រដ្ឋបាលសាធារណៈ, និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវតែមានភាពស៊ីសង្វាក់ និងប្រមាក់ក្រឡាគ្នា ហើយសម្រេចកំចាន់ស្មើ និងពង្រឹកបន្ថែមនូវពីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងកំណែទម្រង់ផ្សេងៗទៀត នៅតាមវិស័យសាធារណៈសំខាន់ៗនៅក្នុងយន្តការនេះផងដែរ។

ឃ. ការចូលរួមនៃគ្រប់ភាគីពាក់ព័ន្ធ ក៏ជាកត្តាកំណត់ជោគជ័យតែមួយគត់របស់កិច្ចការការងារកំណែទម្រង់ ហើយសូមលើកទឹកចិត្តដល់យុវជន ដែលជាធនធានកំមានសក្តានុពលរបស់ជាតិ ឱ្យចូលរួមក្នុងការងារកំណែទម្រង់ឱ្យកាន់តែសកម្ម និងស៊ីជម្រៅបន្ថែមទៀត។

ឥឡូវនេះ សម្តេចក្រឡាហោម ជានាយករដ្ឋមន្ត្រី ជានាយកប្រតិបត្តិ ជានាយកគ្រប់គ្រងការងារកំណែទម្រង់ទាំង ៣ ក៏ចាប់ផ្តើមសិក្សាលម្អិតអំពីលទ្ធភាពនៃការដាក់ឱ្យដំណើរការ នូវច្បាប់ស្តីពីការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាដំណាក់ការ២ ដែលមានការកែទម្រង់ផ្សេងទៀតនៅក្នុងយន្តការសម្រាប់ការកែទម្រង់ជាប្រព័ន្ធទាំង ៣ ដែលកំពុងមានស្រាប់ជាធម្មតា។

សិក្ខាសាលា ត្រូវបានបិទបញ្ចប់ជាផ្លូវការ នៅវេលាម៉ោង ៦ ល្ងាច ក្នុងថ្ងៃដដែល ប្រកបដោយលទ្ធផលត្រចះត្រចង់ និងស្ទាត់ជាសមត្ថភាព ភាពរហ័ត និងស្ទាត់ជីវិកែទម្រង់។

ភ្នំពេញ ថ្ងៃទី 19 ខែមិថុនា ឆ្នាំ២០១៨
អ្នកធ្វើរបាយការណ៍
ចុងធ្នូ សង្ហា

បានពិនិត្យ និង សូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការ អ.ភ.ម.
ភ្នំពេញ ថ្ងៃទី 20 ខែមិថុនា ឆ្នាំ២០១៨
អនុប្រធានលេខាធិការ ការងារ និងជា អគ្គលេខាធិការរង ២ អ.ភ.ម.
ម៉ាន្ធិត ម៉ៃលីន ម៉ារ៉ែត

បានពិនិត្យនិងសូមគោរពជូន
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧត្តមរដ្ឋមន្ត្រី
ជ្រុមរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់
ការកាត់ថ្លៃចំណាយហិរញ្ញវត្ថុសាធារណៈ
ភ្នំពេញ ថ្ងៃទី 22 ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការ ២ អ.ភ.ម.
អេ សីហា

ភ្នំពេញ ថ្ងៃទី 29 ខែ 6 ឆ្នាំ២០១៨
ឧត្តមរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការ
ជាតិដឹកនាំការងារកំណែទម្រង់ការកាត់ថ្លៃចំណាយហិរញ្ញវត្ថុសាធារណៈ
អគ្គបណ្ឌិតសភាចារ្យ អុន ច័ន្ទមុនីរ៉ា

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ឧបសម្ព័ន្ធទី១៨

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ឧបសម្ព័ន្ធទី១៨. សេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....

សេចក្តីសម្រេចរួម
ស្តីពី
ការបង្កើតយន្តការសម្របសម្រួលរវាង
កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

ក្រសួងមហាផ្ទៃ: កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ក្រសួងសាធារណការ និងដឹកជញ្ជូន: កម្មវិធីកែទម្រង់ផ្នែកដឹកជញ្ជូនសាធារណៈ

- យោងតាមច្បាប់ស្តីពីវិសាលភាពនៃក្រសួង-ស្ថាប័ន
- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/០០៤ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការកែតម្រូវ និងការបន្ថែមនូវមាត្រាមួយចំនួនក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង-ស្ថាប័ន
- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០០/០០៤ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលនិងបន្ថែមនូវមាត្រាមួយចំនួនក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមព្រះរាជក្រម លេខ ០២/ នស/ រក០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការជម្រះក្តី
- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០៥/១៤២៤ ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការនាំមុខរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការជាតិកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សម្រេច

ប្រការ...

ការបង្កើតការសម្របសម្រួល រវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការជាតិ ... ...

ក្នុងការ...

យន្តការសម្របសម្រួល ត្រូវបានកំណត់ ដូចតទៅ៖

- អនុលេខាធិការដ្ឋាន នៃគណៈកម្មាធិការនីតិកាលការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈប្រធានក្រុម និងតាមការចាំបាច់ នៃការនីតិកាលក្នុងណៈ ក្នុងរយៈពេលមួយ
- កិច្ចប្រជុំត្រូវធ្វើកន្លោងដោយអនុលេខាធិការ ឬប្រធានលេខាធិការដ្ឋាន ដែលជាប្រធានតាមរយៈ
- របៀបវារៈនៃកិច្ចប្រជុំ ត្រូវបានកំណត់ទៅតាមប្រធានបទនៃការស្នើសុំដោយអនុលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី
- ប្រធានក្រុមត្រូវប្រមូលព័ត៌មានពាក់ព័ន្ធទាក់ទងនឹងរបៀបវារៈនៃកិច្ចប្រជុំ ដើម្បីរៀបចំសេចក្តីកិច្ចប្រជុំប្រកបដោយផលិតភាពនិងប្រសិទ្ធភាព
- ប្រធានក្រុម ទទួលខុសត្រូវលើការកត់ត្រា ស្ថិតិ នៃសកម្មភាពការពាក់ព័ន្ធ ក្នុងកិច្ចប្រជុំ តាមការចាំបាច់។

ក្នុងការ...

ប្រធានគណៈកម្មាធិការនីមួយៗ អាចកោះប្រជុំអនុលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី តាមការចាំបាច់ក្រោមការណែនាំផ្ទាល់ ឬតំណាងប្រធានគណៈកម្មាធិការ។

ក្នុងការ...

រាល់កិច្ចប្រជុំនីមួយៗទាមទារចែងក្នុងប្រការ ២ និងប្រការ ត្រូវមានវត្តមានការណ៍ជូនប្រធានគណៈកម្មាធិការទាំងបី។

ក្នុងការ...

អនុលេខាធិការ នៃអនុលេខាធិការដ្ឋានគណៈកម្មាធិការនីតិកាលការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងប្រធានអនុលេខាធិការដ្ឋាន លេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី ត្រូវទទួលបន្ទុកអនុវត្តលទ្ធិសម្រេចនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះបានលេខាធិការ។

ធ្វើនៅភ្នំពេញ ថ្ងៃទី... ខែមិថុនា ឆ្នាំ២០១៥

ជ.ម.ប.ធ.ជ.ម.ប.ធ.
ប្រធានគណៈកម្មាធិការ
ជ.ម.ប.ធ.
ប្រធានលេខាធិការ
ជ.ម.ប.ធ.
ប្រធានលេខាធិការ

ស ១០១

ពេជ្ជ ចិន្តមិន

ឈ្មោះ. ហ៊ុន ណ្ឌីម្ហ៊ីង

ច្រកចេញ ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- លេខាធិការដ្ឋានជាតិ
- ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទីស្តីការគណៈកម្មាធិការ
- ប្រធានក្រុម ទាំងអស់
- ទ្រូបប្រធាន
- រដ្ឋលេខ
- ឯកសារ ការិយាល័យ

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

ឧបសម្ព័ន្ធទី១៩

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ឧបសម្ព័ន្ធទី១៩. សេចក្តីព្រាងបឋមទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រ កម្មវិធីកែទម្រង់ ៣ បូក ១ (សិក្សាបឋម)

សេចក្តីព្រាងបឋម
ទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រ
កម្មវិធីកែទម្រង់ ៣ បូក ១ (សិក្សាបឋម)

មាតិកានុក្រម

១. សេចក្តីផ្តើម ១
ក. ទិដ្ឋភាពរួមនៃកំណែទម្រង់ ១
ខ. គោលបំណងនៃឯកសារទស្សនាទាន ២
គ. កិច្ចដំណើរការរៀបចំឯកសារទស្សនាទាន ៣
២. សេចក្តីសង្ខេបកំណែទម្រង់សំខាន់ៗ ៣
ក. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣
ខ. កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៧
គ. កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ១៣
ឃ. កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ១៦
៣. ចក្ខុវិស័យ និងបេសកកម្មរួមនៃកម្មវិធីកែទម្រង់ ៣ ឫក ១ ..... ២០
៤. លទ្ធផលរំពឹងទុករួម និងយុទ្ធសាស្ត្រអនុវត្ត ២០
ក. លទ្ធផលរំពឹងទុករួមទីមួយ ២១
ខ. លទ្ធផលរំពឹងទុករួមទីពីរ ២៣
គ. លទ្ធផលរំពឹងទុករួមទីបី ២៤
៥. ការគ្រប់គ្រងនិងការអនុវត្ត ២៦
ក. យន្តការពិនិត្យសម្រេច ២៦
ខ. យន្តការអនុវត្ត ២៧
គ. យន្តការតាមដានការអនុវត្ត ២៧
៦. សេចក្តីសន្និដ្ឋាន ២៩
ផែនការកម្មវិធីនិងសកម្មភាព ២០២២ ដល់ ២០៣២ I

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

បញ្ជីតារាង

តារាងទី ១ ÷ ដំណាក់កាលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣

តារាងទី ២ ÷ ឯកសារចម្បងដែលជាលទ្ធផលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៥

តារាងទី ៣ ÷ អានុភាពនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដល់កម្មវិធីកែទម្រង់ផ្សេងៗ ៦

តារាងទី ៤ ÷ វឌ្ឍនភាពទៅលើចង្កោមសកម្មភាពនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ១៣

តារាងទី ៥ ÷ ការដំឡើងតម្លៃសន្ទស្សន៍ប៉ៃវ៉ាត្យមូលដ្ឋាន ១៥

តារាងទី ៦ ÷ វគ្គសិក្សា ១៥

តារាងទី ៧ ÷ ការងារស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល ១៨

១. សេចក្តីផ្តើម

ក. ទិដ្ឋភាពរួមនៃកំណែទម្រង់

ក្រោយពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានអនុម័តជាផ្លូវការនូវកម្មវិធីជាតិសម្រាប់ នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ (១៩៩១ ដល់ ២០០០) សម្រាប់កំណត់ចក្ខុវិស័យនៃការកសាងនិងការអភិវឌ្ឍប្រទេសជាតិឡើងវិញ ដោយផ្តោតជាសំខាន់លើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ។ បន្ទាប់ពីទទួលបានសន្តិភាពពេញលេញ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ (២០០១ ដល់ ២០០៥) ដោយចាប់យកនូវ "**យុទ្ធសាស្ត្រត្រីកោណ**" ដែលផ្តោតសំខាន់លើ ១) ការធានាឱ្យមានសន្តិភាព ស្ថិរភាព និងសន្តិសុខ ២) ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងការធ្វើឱ្យមានទំនាក់ទំនងល្អឡើងវិញជាមួយនឹងសហគមន៍ អន្តរជាតិ និង ៣) ការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច។ បន្ទាប់មក "**យុទ្ធសាស្ត្រត្រីកោណ**" ត្រូវបានជំនួសទៅដោយ "**យុទ្ធសាស្ត្រចតុកោណ**" ដែលផ្តោតសំខាន់ទៅលើ **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព**។ ការកែទម្រង់អភិបាលកិច្ច គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដែលក្នុងនោះមានមុំបីពាក់ព័ន្ធនឹងវិស័យសាធារណៈគឺ ១) ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន ២) ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ និង ៣) ការពង្រឹងប្រសិទ្ធភាពការងារ។

ដើម្បីជួយគាំទ្រដល់មុំទាំងបីនៃយុទ្ធសាស្ត្រចតុកោណខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវ ១)កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីឆ្នាំ២០០៤ ២) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចាប់តាំងពីឆ្នាំ២០១០ និង ៣) កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ចាប់តាំងពីឆ្នាំ២០១៥។ ដោយឡែកកម្មវិធីកែទម្រង់សេវាយុត្តិធម៌នៅមិនទាន់មានយុទ្ធសាស្ត្រ និងការអនុវត្តយ៉ាងក្បោះក្បាយនិងជាប្រព័ន្ធនៅឡើយទេ។

ជាយន្តការអនុវត្ត ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋដែលដឹកនាំដោយនាយករដ្ឋមន្ត្រី ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០០៤ ដើម្បីបំពេញមុខងារក្នុងកិច្ចការកែទម្រង់ទាំងមូល រួមមានលើកសំណើជូនរដ្ឋាភិបាល ក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងចេញសេចក្តីសម្រេចណែនាំកម្មវិធីកែទម្រង់។ ក្រុមប្រឹក្សាកែទម្រង់ផ្សេងៗតាមជំនាញត្រូវស្ថិតនៅក្រោមការតម្រង់ទិស សម្របសម្រួល និងត្រួតពិនិត្យ សកម្មភាពអនុវត្ត ការងារនិងវឌ្ឍនភាពនៃលទ្ធផល ដោយឧត្តម-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ។ ក្រោយមកទៀតនាឆ្នាំ ២០១៣ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋត្រូវបានរំសាយ ដោយផ្ទេរមុខងារកំណែទម្រង់រដ្ឋបាលទៅក្រសួងមុខងារសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ទៅក្រសួងយុត្តិធម៌។

នាពេលបច្ចុប្បន្ន រដ្ឋាភិបាលបានបង្កើតឱ្យមានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ រួមមាន ១) គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ ៣) គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និង ៤) គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ គណៈកម្មាធិការនីមួយៗ សុទ្ធតែមានអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋាន ជាសេនាធិការ។

ដោយមើលឃើញពីមុខងារពាក់ព័ន្ធគ្នារវាងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងនាមស្ថាប័នដឹកនាំការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងមហាផ្ទៃ ក្នុងនាមស្ថាប័នដឹកនាំការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងក្រសួងមុខងារសាធារណៈក្នុងនាមស្ថាប័នដឹកនាំការកែទម្រង់រដ្ឋបាលសាធារណៈ បានចេញសេចក្តីសម្រេចរួម ដើម្បីបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ទាំងបី ដោយកំណត់ការប្រជុំប្រចាំត្រីមាស និងតាមការចាំបាច់ ក្រោមការដឹកនាំរបស់ប្រធានបូរវេន។ ជាវឌ្ឍនភាព កិច្ចប្រជុំយន្តការសម្របសម្រួលរវាងកម្មវិធី

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

កែទម្រង់ទាំងបីបានសម្រេចបញ្ចូល ការកែទម្រង់សេវាយុត្តិធម៌បន្ថែម ដោយហៅថា «**កម្មវិធីកែទម្រង់ ៣ ឫក ១**»។

រហូតមកដល់កាលបរិច្ឆេទនៃទស្សនាទាននេះ កម្មវិធីកែទម្រង់ ៣ ឫក ១ នៅជួបបញ្ហាប្រឈមរួមគ្នាមួយចំនួន រួមមាន÷

- កម្មវិធីកែទម្រង់នីមួយៗនៅមិនទាន់ត្រូវបានយល់ដឹងពីបុគ្គលពាក់ព័ន្ធនឹងងសាធារណជន
- កម្មវិធីកែទម្រង់នីមួយៗនៅស្ថិតនៅក្រោមស្ថាប័នមានសមត្ថកិច្ចដាច់ដោយឡែកពីគ្នា ហើយមិនទាន់មានយន្តការសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាអន្តរស្ថាប័ន
- កម្មវិធីកែទម្រង់នីមួយ មានចំណុចផ្តើមនិងវឌ្ឍនភាពខុសគ្នា
- កម្មវិធីកែទម្រង់ ៣ ឫក ១ នៅមិនទាន់មានគោលដៅរួមនិងច្បាស់លាស់ និង
- កម្មវិធីកែទម្រង់ ៣ ឫក ១ មិនទាន់មានវិធាននិងនីតិវិធីចែករំលែកទិន្នន័យច្បាស់លាស់។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ កិច្ចប្រជុំតាមយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឫក ១ បានកំណត់សកម្មភាពរួម ប៉ុន្តែដំណោះស្រាយដែលពិភាក្សានៅក្នុងកិច្ចប្រជុំនោះមិនត្រូវបានយកមកអនុម័ត ដើម្បីអនុវត្តនិងតាមដាននោះទេ។ ដូចនេះ ថ្នាក់ដឹកនាំនៃគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ ៣ ឫក ១ ក៏បានសម្រេចរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ ឫក ១ សម្រាប់រយៈពេល ១០ ឆ្នាំ។

បញ្ហាបាត់បង់ជំនួយ និងបញ្ហាសេដ្ឋកិច្ច ក្នុងបរិបទកូវីដ បានចោទជាបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធី កែទម្រង់។ ទោះជាបែបនេះក្តី បញ្ហាទាំងនោះក៏អាចត្រូវបានចាត់ទុកជាកលានុវត្តភាពនៃការរៀបចំ អនុម័ត និងអនុវត្តទស្សនាទានចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ ឫក ១ នេះផងដែរ ដោយសារតែបញ្ហាប្រឈមទាំងនោះបាននិងកំពុងដាក់សម្ពាធផ្ទាល់ទៅស្ថាប័ននិងបុគ្គលពាក់ព័ន្ធ ឱ្យពន្លឿននិងបង្កើនប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ ដោយសហការគ្នាដើម្បីទប់ស្កាត់វិបត្តិនិងស្តារសេដ្ឋកិច្ចជាតិ។

ខ. គោលបំណងនៃឯកសារទស្សនាទាន

ទស្សនាទានចក្ខុវិស័យនិងយុទ្ធសាស្ត្រការងារកែទម្រង់ ៣ ឫក ១ ត្រូវបានរៀបចំឡើងនិងអនុម័ត ក្នុងគោលបំណង÷

- បង្ហាញអំពីភាពប្រទាក់ក្រឡាគ្នានិងការអនុវត្តកម្មវិធីកែទម្រង់ ៣ ឫក ១
- កំណត់ចក្ខុវិស័យនិងបេសកកម្មរួមនៃកម្មវិធីកែទម្រង់ ៣ ឫក ១ ដើម្បីធានាឱ្យបាននូវ ១) សង្គតិភាព នៃគោលដៅនិងគោលបំណងរួម ២) ការធ្វើសមាហរណកម្មនិងសុខដុមនីយកម្មនៃផែនការសកម្មភាព និង ៣) វិធាននិងនីតិវិធីសម្របសម្រួល កំណត់យុទ្ធសាស្ត្រនិងដោះស្រាយបញ្ហារួម និង
- ធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្ររបស់កម្មវិធីកែទម្រង់នីមួយៗ។

ជារួម ទស្សនាទានចក្ខុវិស័យនិងយុទ្ធសាស្ត្រការងារកែទម្រង់ ៣ ឫក ១ នេះ ត្រូវបានរៀបចំឡើង និងអនុម័ត ក្នុងទម្រង់ជាក្របខ័ណ្ឌគោលគំនិតនៃការអនុវត្តកម្មវិធីកែទម្រង់ ៣ ឫក ១ ដោយផ្តោតសំខាន់ទៅលើ ១) ការកំណត់ចក្ខុវិស័យនិងបេសកកម្មរួម ២) កំណត់នូវយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវនៃការអនុវត្តផែនការ សកម្មភាពដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាជារួមនិងប្រព័ន្ធ និង ៣) កំណត់យន្តការពិភាក្សាសម្រេច និងដោះស្រាយបញ្ហារួម ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ ដូចនេះ ទស្សនាទាននេះមិនវិភាគឬលូកលាន់ជ្រៅទៅក្នុងផែនការយុទ្ធសាស្ត្រសម្រាប់កម្មវិធីកែទម្រង់នីមួយៗនោះទេ។

ค. កិច្ចដំណើរការរៀបចំឯកសារទស្សនាទាន

ទស្សនាទានចក្ខុវិស័យនិងយុទ្ធសាស្ត្រការងារកែទម្រង់ ៣ ឫក ១ នេះ ត្រូវបានរៀបចំឡើងតាមដំណើរការ ដូចខាងក្រោម÷

- ការស្វែងយល់និងរៀបចំរបាយការណ៍វឌ្ឍនភាព ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមអំពីកម្មវិធីកែទម្រង់ ៣ ឫក ១ យោងឯកសារការជួបប្រជុំជាមួយអន្តរលេខាធិការដ្ឋានៃកម្មវិធីកែទម្រង់ ៣ ឫក ១ និងក្រសួងឬអគ្គនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធផ្ទាល់ ដើម្បីទទួលបានធាតុចូល ឯកសារ ទិន្នន័យ និងព័ត៌មានបន្ថែម
- ការរៀបចំជាសេចក្ដីព្រាងឯកសារទស្សនាទាន ស្ដីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ ឫក ១ ដើម្បីរាយការណ៍និងធ្វើបទបង្ហាញជូនអន្តរលេខាធិការដ្ឋានៃកម្មវិធីកែទម្រង់ ៣ ឫក ១ ពិនិត្យ និងផ្ដល់ជាមតិយោបល់
- ការផ្ដល់ជាធាតុចូលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់នីមួយៗ ដោយការដ្ឋានកែទម្រង់នីមួយៗ ដើម្បីធ្វើជាមូលដ្ឋាននៃការរៀបចំទស្សនាទាន និង
- ការពិនិត្យមើលលើសេចក្ដីព្រាងទស្សនាទានស្ដីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់៣ ឫក១ ដោយការដ្ឋានកែទម្រង់៣ ឫក១ ដើម្បីដាក់ជូនគណៈកម្មាធិការកែទម្រង់៣ ឫក១ ពិនិត្យនិងសម្រេចរួមគ្នា។

២. សេចក្ដីសង្ខេបអំណោទម្រង់សំខាន់ៗ

ก. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានចក្ខុវិស័យ "**ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ កម្ពុជាឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ**"។ ដើម្បីសម្រេចចក្ខុវិស័យនេះ កម្មវិធីកែទម្រង់នេះបានប្រើយុទ្ធសាស្ត្រកែទម្រង់ចោះជំហានជាដំណាក់កាល ដោយបែងចែកជាបួនដំណាក់កាល ដូចខាងក្រោម÷

តារាងទី ១ ÷ ដំណាក់កាលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដំណាក់កាល	ប្រធានបទ	សកម្មភាពគន្លឹះ	សមិទ្ធផល
ទី១ (២០០៤-២០០៨)	ការបង្កើនភាពជឿទុកចិត្តនៃថវិកា	ការពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា	សម្រេចបានទ្ធវមូលដ្ឋានគ្រឹះនៃការពង្រឹងការគ្រប់គ្រងនិងប្រមូលចំណូល។ ការបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសាច់ប្រាក់ ដោយការបង្កើតគណនីទោលរតនាគារជាតិ និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់។ យន្តការចំណាយត្រូវបានកែលម្អ ដោយកាត់បន្ថយនីតិវិធីស្នុគ្រស្ទាញ កែទម្រង់វិធាននិងនីតិវិធីលទ្ធកម្ម

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ដំណាក់កាល	ប្រធានបទ	សកម្មភាពគន្លឹះ	សមិទ្ធផល
			និងរៀបចំដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនីងនីតិវិធីចំណាយ។
ទី២ (២០០៩-២០១៥)	ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ	ការរៀបចំ ការកែលម្អ ព្រមទាំងពង្រឹងការកត់ត្រានិងការធ្វើរបាយការណ៍ គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដាអន្តរជាតិ	ការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី មាតិកាថវិកាថ្មី ថវិកាកម្មវិធីផែនការយុទ្ធសាស្ត្រថវិកា អង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។
ទី៣ (២០១៦-២០២០)	ការផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយ	ការកែទម្រង់ប្រព័ន្ធថវិកាទាំងមូល ដោយផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រង ដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើ លទ្ធផលឬសមិទ្ធ-កម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី និងការអនុវត្តអង្គភាពថវិកា ព្រមទាំងការពង្រឹងការរៀបចំគោលនយោបាយ ការព្យាករណ៍ និងការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈ	គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនបានអនុវត្តថវិកាកម្មវិធី។
ទី៤	ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម	គណនេយ្យភាពសមិទ្ធកម្ម ដែលជាលទ្ធផលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល	មិនទាន់ឈានដល់ការវាយតម្លៃ

ក្រៅពីវឌ្ឍនភាពជាសកម្មភាពគន្លឹះដូចបានបកស្រាយខាងលើ រាជរដ្ឋាភិបាលនិងស្ថាប័នមានសមត្ថកិច្ច ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំបង្កើតឱ្យមានច្បាប់ យុទ្ធសាស្ត្រ និងបទប្បញ្ញត្តិមួយចំនួន ដើម្បីបន្តតម្រង់ទិសនិងពង្រឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម ÷

តារាងទី ២ ÷ឯកសារចម្បងដែលជាលទ្ធផលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ប្រធានបទ	ឯកសារ
ការកែទម្រង់ប្រព័ន្ធថវិកា	យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥
	យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥
ការវិនិយោគសាធារណៈ	យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥
	អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពី ការគ្រប់គ្រងការវិនិយោគសាធារណៈ
	ព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
ការគ្រប់គ្រងចំណូល	យុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៩-២០២៥
លទ្ធកម្មសាធារណៈ	យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥
ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ	ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០
	ប្រកាសអន្តរក្រសួងលេខ១១៩៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យនិងធ្វើបច្ចុប្បន្នភាពទីតាំងដីរដ្ឋ ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងស្ថាប័ននៅថ្នាក់កណ្តាល
	ប្រកាសអន្តរក្រសួងលេខ១១៩៧ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបង្កើត គណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យនិងធ្វើបច្ចុប្បន្នភាពទីតាំងដីរដ្ឋ ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរអង្គភាពថ្នាក់មូលដ្ឋាន
សវនកម្ម	អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ស្តីពី ក្របខ័ណ្ឌមុខងារ ភារកិច្ច របស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ជាមួយគ្នានេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដាក់ឱ្យអនុវត្តនូវសកម្មភាពគន្លឹះ ដែលមានអានុភាពទៅដល់កម្មវិធីកែទម្រង់ ៣ ឫក ១ ដូចខាងក្រោម÷

តារាងទី ៣ ÷ អានុភាពនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដល់កម្មវិធីកែទម្រង់ផ្សេងៗ

វឌ្ឍនភាពគន្លឹះ	**អានុភាពដល់កម្មវិធីកែទម្រង់ ៣ ឫក ១**
ការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ត្រូវបានអនុវត្ត ទូទាំងប្រទេស	កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ÷ ការបើកប្រាក់បៀវត្ស តាមប្រព័ន្ធអេឡិចត្រូនិច ដែលនៅក្នុងចង្កោមសកម្មភាពបៀវត្សនិងប្រាក់ឧបត្ថម្ភ
ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានដាក់ឱ្យអនុវត្ត តាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រហាក់ប្រហែលផ្សេងៗទៀត	• កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ÷ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ • កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ÷ ការប្រើប្រព័ន្ធព័ត៌មានវិទ្យាក្នុងការបម្រើសេវាសាធារណៈ
ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញ-វត្ថុ សាធារណៈ (FMIS) ត្រូវបានដាក់ឱ្យ អនុវត្តនៅគ្រប់ក្រសួងស្ថាប័ន និងមន្ទីរសេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្ត និងផែនការ យុទ្ធសាស្ត្រ តម្រង់ទិសនីតិវិធីអនុវត្តការងារ តាមប្រព័ន្ធ FMIS ឆ្នាំ ២០២០ - ២០២៥ ត្រូវ បានដាក់ឱ្យអនុវត្ត	• កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ÷ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិ • កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ÷ ការប្រើប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ
ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបង្កើត	កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ÷ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ
ការព្យាករសាច់ប្រាក់តាមរយៈកម្មវិធី Web-Based Application ត្រូវបានដាក់ឱ្យអនុវត្ត ដោយក្រសួងស្ថាប័នចំនួន៣០ គិតត្រឹមឆ្នាំ ២០១៩	• កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ÷ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ • កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ÷ ការប្រើប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ

លើសពីសមិទ្ធកម្មដែលបានសម្រេចខាងលើ នៅមានសមិទ្ធផលផ្សេងៗទៀតក្នុងកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមិនទាន់ទទួលបានលទ្ធផលសម្រេចទាំងស្រុង តែមានវឌ្ឍនភាពល្អ រួមមាន ១) ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈនិងក្របខ័ណ្ឌថវិការយៈពេលមធ្យម ២) ការធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាមូលធន ៣) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដំណាច់ឆ្នាំ អនុលោមភាពជាមួយនឹង IPSAS Cash Basis និង ៤) ការរៀបចំសេចក្តី-ព្រាងច្បាប់និងបទប្បញ្ញត្តិផ្សេងៗ រួមមានច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ដើម្បីបន្តពង្រឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រាក់រង្វាន់និងការបន្តពង្រឹងសមត្ថភាព ត្រូវបានផ្តល់ឱ្យជាបន្តបន្ទាប់ ដល់មន្ត្រីដែលចូលរួមអនុវត្តកិច្ចការពាក់ព័ន្ធនឹងការកែទម្រង់។

ចាប់តាំងពីការអនុម័តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនាឆ្នាំ២០០៤ កម្មវិធីនេះត្រូវបានគ្រោងទុកថានឹងបញ្ចប់ឆ្នាំ២០១៥។ តាមការអនុវត្តជាក់ស្តែងរហូតដល់ដំណាក់កាលទីបី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវការពេលបន្ថែមទៀតរហូតដល់ទៅ ២១ ឆ្នាំ ដោយគ្រោងជាថ្មី ថានឹងត្រូវបញ្ចប់នៅឆ្នាំ២០២៥ ដើម្បីឱ្យប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាផ្តោតលើធាតុចេញឬលទ្ធផលនិងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ។ រហូតមកដល់ឆ្នាំ២០២១ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅមិនទាន់បោះទៅរៀបចំនិងអនុវត្តជំហានទីបួន ដែលជាជំហានចុងក្រោយ ដើម្បីចក្ខុវិស័យ« **សម្រេចបានជាមូលដ្ឋានន្ធវគណនេយ្យភាពសមិទ្ធកម្ម ដែលជាលទ្ធផលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល**» នៅឡើយនោះទេ ដោយនៅបន្តអនុវត្តផែនការយុទ្ធសាស្ត្រ នៅក្នុងជំហានទីបី ឱ្យបានសម្រេចនិងចប់សព្វគ្រប់សិន។

ជាក់ស្តែង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅមានបញ្ហាប្រឈមមួយចំនួនរួមមាន÷

- ការរៀបចំផែនការថវិកា និងនីតិវិធីចំណាយ នៅមិនទាន់រលូន ដោយសារបញ្ហារចនាសម្ព័ន្ធផ្ទៃក្នុង របស់ក្រសួង-ស្ថាប័ន និងបញ្ហាពេលវេលាឬប្រតិទិនៃថវិកានិងការរៀបចំផែនការផ្សេងៗ
- ការអនុវត្តថវិកាកម្មវិធីនៅមិនទាន់ធានាបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រោះការមិនបានរៀបចំគោលនយោបាយ សូចនាករ និងគោលដៅប្រទាក់ក្រឡាគ្នា និងការមិនទាន់សម្រេចបានន្ធវការធ្វើសមាហរណកម្មរវាងចំណាយចរន្តនិងមូលធន
- ការប្រើប្រាស់ប្រព័ន្ធ FMIS នៅមិនទាន់ធានានីតិវិធីស្វ័យប្រវត្តិកម្មនៅក្នុងប្រព័ន្ធគ្រប់ដំណាក់កាល ដោយសារនៅខ្វះបទប្បញ្ញត្តិគាំទ្រ និងការសម្រួលនីតិវិធីជាក់ស្តែង
- លទ្ធកម្មនៅមិនទាន់អនុវត្តបានតាមប្រព័ន្ធអេឡិចត្រូនិច ហើយមិនទាន់ផ្សារភ្ជាប់នឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ការមិនទាន់បានធ្វើសន្ធានកម្មប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានពេញលេញ
- ការមិនទាន់មានសុខដុមនីយកម្មន្ធវប្រព័ន្ធអធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុង និងទោសបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តអនុវត្តដើម្បីដោះស្រាយបញ្ហាខាងលើ ដើម្បីអាចឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្អែកលើសមិទ្ធកម្ម ដែលការអនុវត្តកម្មវិធីកែទម្រង់នេះ បានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនៗរួមមាន ១) ការខ្វះខាតកិច្ចសម្របសម្រួលនិងសហប្រតិបត្តិការ ២) គម្លាតនៃការអនុវត្ត ដោយខ្វះការគ្រប់គ្រងនិងសមត្ថភាពជំនាញ ក្នុងការរៀបចំនិងអនុវត្តសកម្មភាពគន្លឹះ ៣) ការមិនអាចសម្រេចបញ្ចប់បានន្ធវមូលដ្ឋានគ្រឹះនៃកម្មវិធីអាទិភាព និង ៤) ការជះឥទ្ធិពលពីកត្តាខាងក្រៅ រួមមានការបាត់បង់ជំនួយ និងបញ្ហាសេដ្ឋកិច្ច។

ខ. កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងរយៈពេល១០ឆ្នាំខាងមុខ (២០២១-២០៣០) គឺ "*ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និង ផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋាន ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ធ និងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបានន្ធវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០*"។

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទីពីរ មាន គោលបំណង "***លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ធ សមធម៌ និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលម្អនូវដំណើរការ ផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង*"។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលធំៗដូចខាងក្រោម ÷

- បង្កើតបាននូវមូលដ្ឋានគ្រឹះសំខាន់ៗនៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ នៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមាន ការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ តាមរយៈការបោះឆ្នោត ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រង ព្រមទាំងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមមាន នីតិវិធីរៀបចំកិច្ចប្រជុំនិងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា នីតិវិធីនៃការរៀបចំវេទិកាពិគ្រោះយោបល់ សាធារណៈរបស់ក្រុមប្រឹក្សា និងនីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌។ រចនាសម្ព័ន្ធនានានៃមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមណ្ឌលថែទាំកុមាររដ្ឋត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត។ ជាមួយគ្នានេះដែរ រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងវិញដោយផ្អែកតាមគោលការណ៍រដ្ឋបាលឯកភាព តាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានារបស់ក្រសួង ចំនួន២០ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីនេះនាឆ្នាំ២០១៩។
- បានរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនដែលត្រូវបានផ្ទេរទៅឱ្យចំនួនប្រមាណជាង ៤០.០០០នាក់។ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកទាំងនោះអំពីការទទួលខុសត្រូវតួនាទី ភារកិច្ច និងនីតិវិធីអនុវត្តការងារក៏ត្រូវបានផ្តល់តាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗ សិក្ខាសាលា និងការហ្វឹកហាត់ការងារជាក់ស្តែង។ ទន្ទឹមនោះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវាអភិវឌ្ឍសមត្ថភាពបុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។
- បានផ្ទេរមុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានផ្ទេរមុខងារ ក្នុងវិស័យសង្គមកិច្ចនិងសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមគោលការណ៍ វិមជ្ឈការ ដើម្បីបង្ហិតការផ្តល់សេវាឱ្យកៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើង ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់មួយចំនួនពីរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បង្កើតបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុ ដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាល ក្រុង ស្រុក ដើម្បី

គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ឥម្ភាភាព និងគណនេយ្យភាព។ ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើតឡើងដែលរួមមាន ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌដូចជា មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដូចជាប្រព័ន្ធផ្ទេរមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ព្រមទាំងប្រព័ន្ធចែករំលែកចំណូលសារពើពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងភាពជោគជ័យនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានបង្កើនការផ្ទេរថវិការដ្ឋជារៀងរាល់ ឆ្នាំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរហូតមកទល់ឆ្នាំ២០២០នេះ ថវិកានេះមានចំនួនសរុបប្រមាណជាង **៣.៨០០លាន ដុល្លារអាមេរិក** សម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

- បង្កើតបាននូវប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធី វិនិយោគ ៣ឆ្នាំរំកិល ស្របទៅតាមចរិតលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។
- បង្កើតបាននូវយន្តការគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលរួមមានដូចជា ការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ដើម្បីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានាក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការបំពេញមុខងារ និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល ដើម្បីផ្តល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធ នឹងការប្រើប្រាស់ថវិកាឃុំ សង្កាត់ និងអង្គភាពជំនាញនានា នៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបង្ក លក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់កែលម្អលើការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវានៅមូលដ្ឋានមួយចំនួន រួមមានដូចជា សាលាបឋមសិក្សា និងមណ្ឌលសុខភាពជាដើម ព្រមទាំង បានអនុវត្តសាកល្បងនូវការងារគណនេយ្យភាពសង្គមនៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ គោលដៅ មួយចំនួន។
- បាននិងកំពុងផ្តល់សេវារដ្ឋបាលប្រមាណជាង ៦០០ប្រភេទ ព្រមទាំងបានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង ២.០០០ គម្រោង ក្នុងមួយឆ្នាំៗ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងមូលដ្ឋាន ដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- បានបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់ដឹកនាំ សម្របសម្រួល និងគាំទ្រ ដល់ការរៀបចំនិងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រោមក្របខ័ណ្ឌនៃយន្តការនេះ គ.ជ.អ.ប. បានកៀរគរការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដល់ការអនុវត្តកម្មវិធីកំណែទម្រង់នេះ។ ក្រោម

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ការដឹកនាំនិងការសម្របសម្រួលរបស់ គ.ជ.អ.ប. ក្រសួងស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធចំនួន២៣ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហ-មជ្ឈការ។ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានសមាជិកសរុបចំនួន ១៥.៦៨៦រូប ត្រូវបានបង្កើតឡើង ដើម្បីធ្វើជាយន្តការតំណាងឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស សម្រាប់ការពារ គាំទ្រ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តនានាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ និងការលើកកម្ពស់ ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ ជាពិសេសបានបង្កើតនូវគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានធ្វើសវនកម្មយេនឌ័រក្នុងប្រព័ន្ធគ្រប់គ្រងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ ការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចជូនថ្នាក់ដឹកនាំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានបង្កើតនូវគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក.) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ដែលជាយន្តការដ៏មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាអាទិភាពរបស់ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ។
- ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សមត្ថភាពបន្សាំរបស់ប្រជាពលរដ្ឋទប់ទល់ទៅនឹងគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ស្របទៅតាមស្ថានភាពរងគ្រោះរបស់មូលដ្ឋាននីមួយៗ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយនិងជំងឺឆ្លងកាចសាហាវ នានាត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃការកសាងផែនការ និងការរៀបចំគម្រោងថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលក្រុង ស្រុកចំនួន៥០ ដែលស្ថិតក្នុងតំបន់ងាយរងគ្រោះពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាបានទទួលការគាំទ្រហិរញ្ញប្បទានអាកាសធាតុ តាមរយៈមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត សម្រាប់វិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ ការបណ្តុះ-បណ្តាល កសាងសមត្ថភាព និងពង្រឹងស្ថាប័ន។ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានទទួលស្គាល់ជាស្ថាប័នអនុវត្តជាតិសម្រាប់ មូលនិធិអាកាសធាតុបៃតងក្នុងការគៀរគរធនធានហិរញ្ញប្បទានអាកាសធាតុគាំទ្រដល់ការអនុវត្ត សកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។
- បានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងសុវត្ថិភាព បរិស្ថាន និងសង្គម ដើម្បីជាមូលដ្ឋានដល់ការរៀបចំនិងការអនុវត្តគម្រោងវិនិយោគសាធារណៈនានា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅធានាដល់ការចៀសវាងនូវផលប៉ះពាល់អវិជ្ជមានជាអតិបរមា ការគំរាមកំហែងទៅលើនិរន្តរភាពនៃលំនឹងបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី សង្គម វប្បធម៌ ប្រពៃណី ជនជាតិដើមភាគតិច ក៏ដូចជា

ផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាព សេដ្ឋកិច្ច សមភាពយេនឌ័រ និងការរំលោភបំពានផ្សេងៗដែលបណ្តាលមកពីកិច្ចការអភិវឌ្ឍន៍ទាំងនេះ។

ទន្ទឹមនឹងការសម្រេចបានន្យូវសមិទ្ធផលធំៗខាងលើនេះ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ រួមមាន÷

- កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺជាគោលនយោបាយដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាលដែលបានដាក់ឱ្យអនុវត្តជិតពីរទស្សវត្សមកហើយ ក៏ប៉ុន្តែការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានាទាំងស្ថាប័នសាធារណៈ សង្គមស៊ីវិល និងសាធារណជនអំពីកំណែទម្រង់នេះនៅមានកម្រិត និងមានការយល់ឃើញនិងបកស្រាយផ្សេងគ្នាៗអំពីចក្ខុវិស័យ និងគោលបំណងនៃកំណែទម្រង់នេះ។
- កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញសំញ៉ាំ ដែលទាមទារឱ្យមានការប្តេជ្ញាចិត្តយ៉ាងមុតមាំទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា។ ក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិទីមួយ ក្រសួង-ស្ថាប័នមួយចំនួននៅមានភាពស្ទាក់ស្ទើរក្នុងការផ្ទេរអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តមុខងារនិងធនធាននានា រួមមានធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្ស ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ពាក់ព័ន្ធនឹងបញ្ហាប្រឈមដ៏សំខាន់នេះ ចាំបាច់ត្រូវបន្តពង្រឹងការតាំងចិត្តទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសរបស់ក្រសួង-ស្ថាប័ននានាក្នុងកិច្ចដំណើរការកែទម្រង់ នេះឱ្យកាន់តែស៊ីជម្រៅនិងមានប្រសិទ្ធភាព។
- រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវបានរៀបចំឡើងវិញ និងកែសម្រួលជាបណ្តើរៗនាពេលកន្លងមក ក៏ប៉ុន្តែរចនាសម្ព័ន្ធនិងប្រព័ន្ធទាំងនេះនៅមិនទាន់មានលក្ខណៈសមស្របពេញលេញតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលមានលក្ខណៈជាទីក្រុងធំ លក្ខណៈទីប្រជុំជន និងលក្ខណៈតំបន់ជនបទ ព្រមទាំងផ្អែកទៅតាមលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចសង្គមខុសៗគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីកម្រិត។
- ផ្អែកតាមកម្មវិធីជាតិទីមួយ រដ្ឋបាលក្រុង-ស្រុក និងរដ្ឋបាលឃុំ-សង្កាត់ត្រូវបានរៀបចំឱ្យក្លាយទៅជារដ្ឋបាលមូលដ្ឋាន ដែលមានតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនដោយផ្ទាល់ជូនប្រជាពលរដ្ឋ និងរដ្ឋបាលខេត្តជារដ្ឋបាលថ្នាក់តំបន់ដែលមានតួនាទីសំខាន់ក្នុងការអនុវត្តមុខងារមួយចំនួន ក្នុងនាមជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័ន និងការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន ព្រមទាំងការផ្តល់សេវា សាធារណៈនិងគម្រោងវិនិយោគធំៗដែលរដ្ឋបាលមូលដ្ឋានពុំមានលទ្ធភាពអនុវត្ត។ ទោះបីយ៉ាងនេះ ក្តី ការសិក្សាអំពីការរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់នៅមិនទាន់បានអនុវត្ត នៅឡើយ។
- ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់បំពេញតួនាទីពេញលេញជាអង្គធ្វើសេចក្តីសម្រេចចិត្តលើផែនការនិងថវិការបស់ខ្លួន ព្រមទាំងបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋក្នុងការឆ្លើយតប ទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួននោះទេ។ បញ្ហានេះទាមទារឱ្យមានការកែលម្អកិច្ចដំណើរការពិនិត្យ អនុម័ត តាមដាន និងត្រួតពិនិត្យលើការអនុវត្តសេចក្តី សម្រេចនានារបស់ក្រុមប្រឹក្សា

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ព្រមទាំងការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តតួនាទី ទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តការងារ គណនេយ្យភាពសង្គម និងការបង្កើតការិយាល័យប្រជាពលរដ្ឋក៏ដោយ ក៏ប្រជាពលរដ្ឋនៅមិនទាន់យល់ដឹងច្បាស់លាស់អំពីសិទ្ធិរបស់ខ្លួនក្នុងការជំរុញឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះខ្លួនឡើយ។

- បើទោះបីជាមានការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ ក៏ការបែងចែកសិទ្ធិអំណាច តួនាទី ភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តមុខងារផ្តល់សេវា សាធារណៈ ចាំបាច់មួយចំនួនរវាងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាល ថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានភាពមិនទាន់ច្បាស់លាស់ ព្រមទាំងមិនទាន់មានភាពសមស្របទៅនឹងគោលនយោបាយវិមជ្ឈការក្នុងការបង្ហិតការផ្តល់សេវាសាធារណៈទៅ កៀកជិតជាមួយប្រជាពលរដ្ឋ។ ប្រការនេះធ្វើឱ្យប្រជាពលរដ្ឋនៅតែជួបការលំបាកក្នុងការទទួលបាននូវសេវាសាធារណៈចាំបាច់មួយចំនួន។
- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង-ស្រុកនៅពុំទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដោយហេតុថា សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលទាំងនេះ នៅមានកម្រិតដែលបានកំណត់ ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ចាំបាច់ត្រូវមានការពិនិត្យ និងការកែសម្រួលនូវលិខិតបទដ្ឋានគតិយុត្តទាំងនេះ ដើម្បីផ្តល់សិទ្ធិអំណាចច្បាស់លាស់ និងកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយ ក៏ការផ្ទេរធនធានានាទាំងធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ សម្រាប់អនុវត្តមុខងារទាំងនេះពុំទាន់មានលក្ខណៈសមស្របតាមចំនួនមុខងារ និងទំហំមុខងារនីមួយៗដែលផ្ទេរទៅឱ្យ ព្រមទាំងពុំទាន់មានដំណើរការដោយរលូននៅឡើយ។
- ការគ្រប់គ្រងនិងការអនុវត្តមុខងារផ្តល់សេវា ដែលត្រូវរ៉ាប់រងចំណាយជាសំខាន់ពីកម្រៃសេវាដែលប្រមូលបានពីអ្នកប្រើប្រាស់ក៏នៅជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន។ ជាក់ស្តែង មុខងារគ្រប់គ្រង សំរាមសំណល់ រឹងទីប្រជុំជនដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុកនៅមិនទាន់អាចអនុវត្ត បានល្អនៅឡើយទេ ដែលតម្រូវឱ្យមានការពង្រឹងយន្តការគាំទ្រ ការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលទាំងនោះ បន្ថែមទៀត។
- ទោះបីធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ក៏ទំហំធនធាននេះនៅមិនទាន់មានលក្ខណៈសមស្របទៅនឹងមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់និងជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឡើយ។ ប្រការនេះ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញដើម្បីបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុឱ្យមានទំហំសមស្រប ព្រមទាំងពិនិត្យ និងកែសម្រួលឡើងវិញនូវរូបមន្តនិងលក្ខណៈវិនិច្ឆ័យ សម្រាប់ការវិភាជធនធានហិរញ្ញវត្ថុ

ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយសមធម៌ សំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

- ទោះបីប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តជាបណ្តើរៗក៏ដោយ ក៏ការអនុវត្តជាក់ស្តែងនៅពុំទាន់មានប្រសិទ្ធភាព និងអនុវត្តពេញលេញតាមប្រព័ន្ធនោះនៅឡើយ ហើយសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានកម្រិតផងដែរ។ មន្ត្រីសាធារណៈមួយចំនួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់យល់ដឹងច្បាស់លាស់អំពីមុខងារនិងការទទួលខុសត្រូវរបស់ខ្លួន មិនទាន់ទទួលបានការបណ្តុះបណ្តាល ជំនាញជាក់លាក់ និងពុំទាន់មានការជំរុញលើកទឹកចិត្ត ឬចាត់វិធានការខាងវិន័យឱ្យបានម៉ឹងម៉ាត់ ក្នុងការបំពេញការងាររបស់បុគ្គលិក។
- បច្ចុប្បន្ននេះ បញ្ហាប្រឈមសំខាន់ៗមានលក្ខណៈជាអន្តរវិស័យមួយចំនួនដូចជា ការរៀបចំប្រព័ន្ធ អភិបាលកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម នៅពុំទាន់បានបញ្ជាបនិងអនុវត្តបានពេញលេញនៅក្នុងការបំពេញការងារជាទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ ប្រការនេះ ការរៀបចំនិងអនុវត្តនូវកម្មវិធីជាតិ ទីពីរ ចាំបាច់ត្រូវយកចិត្តទុកដាក់ដោះស្រាយឱ្យមានប្រសិទ្ធភាព។

គ. កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ

ស្របតាមកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ មានចក្ខុវិស័យប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលអាចជឿទុកចិត្តបាន សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង ដោយផ្តោតសំខាន់លើមុខងារបី ដែលមានវឌ្ឍនភាពដូចខាងក្រោម÷

តារាងទី ៤ ÷ វឌ្ឍនភាពទៅលើចង្កោមសកម្មភាពនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

ចង្កោមសកម្មភាព	វឌ្ឍនភាព
ការកែលម្អសេវាសាធារណៈ	- បានត្រួតពិនិត្យនិងវាយតម្លៃគុណភាព នៃការផ្តល់សេវាសាធារណៈរបស់ស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិ និងផ្តល់អនុសាសន៍កែលម្អទាំងនីតិវិធីនិងយន្តការ - បានធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាសាធារណៈ - បានជម្រុញឱ្យក្រសួងស្ថាប័នប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីផ្តល់សេវា - ការបង្កើតការិយាល័យឬយន្តការច្រកចេញចូលតែមួយក្នុងការផ្តល់សេវាសាធារណៈ - បានដាក់ចេញនូវអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគម្រូ
ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន	- បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍធនធានមនុស្សសម្រាប់រដ្ឋបាលសាធារណៈថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ - បានរៀបចំប្រព័ន្ធមុខងារសាធារណៈថ្មី ដោយលុបចោលក្របខ័ណ្ឌ ឃ - បានរៀបចំនិងដាក់ចេញនូវលក្ខន្តិកៈដោយឡែក ជាពិសេសសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងនីតិវិធីបែបបទក្នុងការគ្រប់គ្រងបុគ្គលិកថ្នាក់ក្រោមជាតិ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ចង្អោមសកម្មភាព	វឌ្ឍនភាព
	- បានធ្វើប្រតិភូកម្មអំណាចទៅឱ្យគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ (គ្រប់គ្រង តែងតាំង និងបញ្ចប់មុខតំណែង) - បានរៀបចំនិងដាក់ឱ្យអនុវត្តបទដ្ឋានគតិយុត្តនិងប្រព័ន្ធត្រួតពិនិត្យវត្តមាន ការបំពេញការងារ និងការបែងចែកភារកិច្ចដល់មន្ត្រី - បានអនុវត្តនូវការគ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន - បានកំណត់ចំនួនមុខតំណែងសម្រាប់មុខតំណែងគ្រប់គ្រង និងបង្កករចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន - បានសម្រួលនិងពន្លឿននីតិវិធីក្នុងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
ការគ្រប់គ្រងប្រព័ន្ធប្រាក់បៀវត្ស	- បានបន្តតម្លើប្រាក់បៀវត្ស និងបន្ថែមប្រាក់ឧបត្ថម្ភនិងប្រាក់លើកទឹកចិត្តជូនដល់មន្ត្រីរាជការ ដែលបៀវត្សនៃមន្ត្រីរាជការបច្ចុប្បន្នជាមធ្យមគឺ ១ ១៣២ ៥០០ រៀល - បានបើកប្រាក់បៀវត្សទៀងទាត់ តាមប្រព័ន្ធធនាគារ ជូនមន្ត្រីរាជការ - បានដាក់ឱ្យអនុវត្តគោលនយោបាយធានារ៉ាប់រងសុខភាពដល់មន្ត្រី - បានពង្រឹងវិធាននិងនីតិវិធីនៃការកំណត់និងបើកផ្តល់ប្រាក់បេសកកម្ម

ជារួម វឌ្ឍនភាពនៅក្នុងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈមានផលប៉ះពាល់ជាវិជ្ជមានផ្ទាល់ទៅដល់កម្មវិធីកែទម្រង់ផ្សេងៗទៀតនៅក្នុងកម្មវិធីកែទម្រង់៣ ឫក១។

ជាវឌ្ឍនភាពមួយគួរឱ្យកត់សម្គាល់នៃកម្មវិធីកែទម្រង់ ៣ ឫក ១ ប្រាក់បៀវត្សរបស់មន្ត្រីរាជការបានកើនឡើងប្រមាណ ៤០% គិតចាប់ពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០២០ ហើយតម្លៃឯកតាសន្ទស្សន៍នៃបៀវត្សមូលដ្ឋាន ត្រូវបានតម្លើងដល់ ២.៥០០ ក្នុងមួយសន្ទស្សន៍ ដែលប្រាក់បៀវត្សជាមធ្យមប្រមាណ ១ លានរៀល ត្រូវបានបើកជូនមន្ត្រីរាជការទៀងទាត់ពីរដងក្នុងមួយខែ តាមប្រព័ន្ធធនាគារ។ លើសពីនេះ មន្ត្រីក៏ទទួលបានប្រាកឧបត្ថម្ភ ប្រាក់រង្វាន់លើកទឹកចិត្ត ប្រាក់បេសកកម្ម និងគោលនយោបាយធានារ៉ាប់រងសុខភាពផងដែរ។ត្រឹមឆ្នាំ២០១៩ ចំនួនមន្ត្រីរាជការស៊ីវិលបានកើនឡើងដល់ប្រមាណម្ភៃម៉ឺននាក់ ដោយការចំណាយលើបុគ្គលិកមានប្រមាណ២៥%នៃចំណាយថវិកាសរុប។ ដើម្បីពង្រឹងគុណភាពមន្ត្រីការពិពណ៌នាមុខងារនិងដំណែងបាននិងកំពុងអនុវត្តដោយក្រសួងស្ថាប័ន ដែលក្រសួងមុខងារសាធារណៈបានដាក់កំហិតតាមបទប្បញ្ញត្តិ មិនឱ្យមានការចាត់តាំងបុគ្គលិកថ្មីនោះទេ ប្រសិនបើមិនមានការពិព័ណ៌នាមុខងារ ដើម្បីកម្រិតបរិមាណមន្ត្រី ឱ្យមានកំណើនតែក្នុងរង្វង់ ៦.៥% ក្នុងរយៈពេលពីឆ្នាំ ២០២០ ដល់ ២០២៣។ ជាងនេះទៅទៀត ទោសពិន័យរបស់មន្ត្រីរាជការមានចែងនិងបញ្ញត្តិនៅតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗគ្នា ដោយមិនទាន់បានធ្វើសមាហរណកម្ម នៅឡើយទេ។ ជាមួយគ្នានេះ រចនាសម្ព័ន្ធសាប់ននៅមិនទាន់មានគតិភាព ជាមួយនឹងប្រព័ន្ធដំណើរការងារថ្មី ដែលរួមមានផ្នែករដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងបច្ចេកទេស ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ទោះបី ជាមានអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ស្តីពី ក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

ក៏ដោយ ក៏ប្រព័ន្ធអធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅមិនទាន់មានសុខដុមនីយកម្ម ដោយមិនទាន់មានការបែងចែកច្បាស់លាស់និងធ្វើសវនកម្មដោយ ផ្អែកលើហានិភ័យនោះទេ។

តារាងទី ៥÷ ការដំឡើងតម្លៃសន្ទស្សន៍ប៉ៃវត្សមូលដ្ឋាន



ប្រភព: ក្រសួងមុខងារសាធារណៈ

សម្រាប់ការកសាងសមត្ថភាព វគ្គបណ្តុះបណ្តាលជំនាញត្រូវបានធ្វើឡើងជាវគ្គខ្ពស់ មធ្យម និងវែង។ កម្មវិធីកែទម្រង់ ៣ ឃ្លាក ១ បានអនុវត្តការបណ្តុះបណ្តាលតាមយន្តការផ្សេងៗគ្នា រួមមាន÷

- សាលាភូមិន្ទរដ្ឋបាល ដែលបានរៀបចំវគ្គបណ្តុះបណ្តាលទូទៅនិងជំនាញ ជាវគ្គសិក្សារយៈពេលខ្លីនិងមធ្យម សម្រាប់ផ្តល់ជូនមន្ត្រីតាមបណ្តាក្រសួងស្ថាប័ន
- សាលាជាតិរដ្ឋបាលមូលដ្ឋាន ត្រូវបានបង្កើតឡើង ដើម្បីរៀបចំការអប់រំអំពី ១) បច្ចេកទេសដែលមានក្នុងសេចក្តីណែនាំបច្ចេកទេសអំពីមុខងារ របៀបអនុវត្តមុខងារ និងនីតិវិធីអនុវត្ត និង ២) សេវារដ្ឋបាលនិងសេវាសាធារណៈ សម្រាប់រយៈពេលវែង មធ្យម និងខ្លី និង
- វិទ្យាស្ថានជាតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលរួមបណ្តុះបណ្តាលគ្រូបង្គោលជាមន្ត្រី នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបន្តបណ្តុះបណ្តាលមន្ត្រីនៅតាមបណ្តាស្ថាប័នផ្សេងៗ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

តារាងទី ៦÷ វគ្គសិក្សា

ល.រ	វគ្គសិក្សា	ចំនួនមន្ត្រីដែលបានចូលរួម
១	កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់	៣០៥៧ នាក់ (គិតចាប់ពីឆ្នាំ ១៩៩៣)
២	កម្មសិក្សាការីមន្ត្រីគ្រប់គ្រងរដ្ឋបាល	៨៧១ នាក់
៣	កម្មសិក្សាការីមន្ត្រីមធ្យម	២០១១ នាក់ (គិតចាប់ពីឆ្នាំ ១៩៩៦)
៤	កម្មសិក្សាការីមន្ត្រីក្រមការ	២១៧ នាក់
៥	វគ្គអភិបាលរាជធានីខេត្ត អគ្គនាយក	១៧០នាក់
៦	វគ្គដឹកនាំជាស្ត្រី	១៨៦នាក់

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ល.រ	វគ្គសិក្សា	ចំនួនមន្ត្រីដែលបានចូលរួម
	វគ្គសិក្សាខ្លីៗ ១២០ ម៉ោង	
៧	វគ្គរដ្ឋបាលសាធារណៈ	១១៤៤ នាក់
៨	វគ្គគ្រប់គ្រងអង្គភាពសាធារណៈ	៤៩០ នាក់
៩	នវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ	៦៨៣ នាក់
១០	ការរៀបចំថវិកា ក្នុងអង្គភាពសាធារណៈ	៨០ នាក់
១១	ការតាក់តែងលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្ត	១០៩ នាក់

ជារួម កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈនៅមានបញ្ហាប្រឈមចម្បងៗ ដូចខាងក្រោម÷

- សកម្មភាពអនុវត្តការងារជាប្រចាំមិនស្របជាមួយនឹងគោលដៅនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយការអនុវត្តមុខងារភាគច្រើនអាស្រ័យលើទម្លាប់ ដោយមិនទាន់មានការបែងចែកភារកិច្ចមុខងារច្បាស់លាស់
- ប្រសិទ្ធភាពនៃការអនុវត្តការងារពាក់ព័ន្ធនឹងការសម្របសម្រួលអន្តរស្ថាប័ននៅមានកម្រិត ដោយសារគណៈ-កម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈនៅមិនទាន់មានក្រុមការងារឬរចនាសម្ព័ន្ធកែទម្រង់ ច្បាស់លាស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិនិងតាមបណ្តាក្រសួងស្ថាប័ន។ ដូចនេះ សកម្មភាពកែទម្រង់ភាគច្រើន ត្រូវបានធ្វើឡើងក្នុងកម្រិតអន្តរក្រសួង ជាជាងអន្តរគណៈកម្មការឬគណៈកម្មាធិការកែទម្រង់
- សមត្ថភាពមន្ត្រីសាធារណៈក្នុងការអនុវត្តច្បាប់នៅមានកម្រិត ដោយមិនទាន់យល់ច្បាស់អំពីគោលនយោបាយដែលជាមូលដ្ឋាននៃការបង្កើតច្បាប់ និងលំហូរប្រតិបត្តិការនិងទំនាក់ទំនងការងារក្នុងរចនាសម្ព័ន្ធរដ្ឋបាលសាធារណៈ
- ការរៀបចំរចនាសម្ព័ន្ធ និងការផ្ទេរមុខងារនិងធនធានរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការ ជាពិសេសមុខងារជំនាញដែលទាមទារឱ្យមានមន្ត្រីដែលយល់ដឹងអំពីជំនាញ ច្បាស់លាស់ក្នុងការអនុវត្តនិងសម្រេច ដើម្បីផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា
- សេវាសាធារណៈមិនទាន់ទទួលបានទំនុកចិត្តពេញលេញពីសាធារណជន ទៅលើតម្លាភាពនិងគណនេយ្យភាពចំពោះពេលវេលានិងលទ្ធផលសម្រេច ហើយសេវាសាធារណៈមួយចំនួនដែលបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់មានភាពច្បាស់លាស់និងទទួលបានការយល់ដឹងពីសាធារណជននោះទេ និង
- ក្របខ័ណ្ឌបទដ្ឋានគតិយុត្តសម្រាប់សេវាសាធារណៈមិនទាន់គ្រប់គ្រាន់ ដោយការកំណត់សេវាសាធារណៈនៅស្ថិតក្រោមចំណុះច្បាប់ផ្សេងៗគ្នា និងមិនទាន់មានការបែងចែកច្បាស់រវាងសេវាសង្គមនិងសេវាធុរកិច្ច ដើម្បីធ្វើជាមូលដ្ឋាននៃការកំណត់ថ្លៃ នីតិវិធី និងស្ថាប័នផ្តល់សេវាឱ្យបានសមស្របនោះទេ។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលកំពុងរៀបចំធ្វើសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ។

ឃ. កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនិងអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ។ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នេះ ពាក់ព័ន្ធនឹងការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ រាជរដ្ឋាភិបាលផ្តោតជាសំខាន់លើការលើក-

កម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធភាពការងារមន្ត្រីអនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្តពីសាធារណជនលើវិស័យយុត្តិធម៌ និងប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌នៅក្នុងសង្គម តាមរយៈ÷

១. ការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ

២. ការពង្រឹងភាពស្អាតស្អំនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់

៣. ការពង្រឹងយន្តការវិនិយការងារ និងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌

៤. ការលើកកម្ពស់ការផ្តល់សេវាច្បាប់

៥. ការពង្រឹងនិងកែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបបានទៅនឹងស្ថានភាពជាក់ស្តែង របស់សង្គមប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលដាក់ចេញនូវកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ឆ្ពោះទៅសម្រេចចក្ខុវិស័យ **"ការទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា តាមរយៈការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និងសិទ្ធិទទួលបានយុត្តិធម៌របស់ពលរដ្ឋ"**។

ការអនុវត្តសកម្មភាពការងាររបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២១ បានសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចតទៅ÷

- វឌ្ឍនភាពក្នុងការអនុវត្តច្បាប់គោលទាំងបួន និងការរៀបចំអង្គការតុលាការ លក្ខន្តិកៈចៅក្រម ព្រះរាជអាជ្ញា ត្រូវបានរកឃើញថា មានភាពប្រសើរឡើងជាលំដាប់
- បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់គោលទាំងបួន និងការរៀបចំអង្គការតុលាការ លក្ខន្តិកៈចៅក្រម ព្រះរាជអាជ្ញា ត្រូវបានរកឃើញនិងដោះស្រាយជាបន្តបន្ទាប់
- កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងសមិទ្ធផលដែលសម្រេចបាន ត្រូវបានផ្សព្វផ្សាយដល់មន្ត្រីរាជការ សិស្ស និស្សិត មន្ត្រីពាក់ព័ន្ធ និងសាធារណជនយ៉ាងទូលំទូលាយ
- ការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមតុលាការ និងភាពចង្អៀតណែនក្នុងពន្ធនាគារ
- រៀបចំនិងអនុវត្តនូវយន្តការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ធ្វើការសម្របសម្រួលជាមួយមន្ត្រីអនុវត្តច្បាប់ផ្សេងទៀត ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់
- រៀបចំនិងអនុវត្តយន្តការចូលរួម និងពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ក្នុងការរៀបចំនិងអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលនិងសហការជាមួយដៃគូក្នុងធ្វើទំនើបកម្មរដ្ឋបាលតុលាការ តាមរយៈការចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធកុំព្យូទ័រនៅគ្រប់រាជធានីខេត្ត

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- រៀបចំយន្តការសហការជាមួយការដ្ឋានកែទម្រង់បីផ្សេងទៀតរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើតនូវយន្តការកែទម្រង់៣ ឬក១ និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់អង្គភាពពាក់ព័ន្ធទាំងអស់ក្នុងវិស័យយុត្តិធម៌។

ក្នុងទិសដៅពង្រឹងនីតិរដ្ឋឱ្យកាន់តែរឹងមាំថែមទៀត ក្រសួងយុត្តិធម៌បានសហការជាមួយអង្គការនានា នៃប្រទេសដែលជាដៃគូអភិវឌ្ឍ ដើម្បីតាក់តែងនិងរៀបចំឯកសារសេចក្តីព្រាងច្បាប់មូលដ្ឋានសំខាន់ៗជាច្រើន ដែលប្រទេសកម្ពុជាយើងកំពុងត្រូវការចាំបាច់បំផុត។ ក្នុងនោះ ក្រសួងយុត្តិធម៌បាននឹងកំពុងខិតខំរៀបចំនិងតាក់តែងនូវច្បាប់និងគោលនយោបាយចំនួន៦ ដែលជាអាទិភាព ក្នុងនោះរួមមាន÷

១. គោលនយោបាយស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា

២. សេចក្តីព្រាងច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម

៣. សេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ

៤. សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី

៥. សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលា និង

៦. សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី។

តារាងទី ៧ ÷ការងារស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ផ្នែក	បរិយាយ	ចំនួន	រាជធានី-ខេត្ត និងសិក្ខាកាម
ការងារស្រាវជ្រាវ	ចុះស្រាវជ្រាវ និងវាយតម្លៃ តាមសាលាដំបូងរាជធានី-ខេត្ត ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងការអនុវត្តច្បាប់គោលទាំងបីពាក់ព័ន្ធនិងវិស័យយុត្តិធម៌ នៅតាម បណ្តារាជធានី-ខេត្ត	២០ ដង	ទូទាំងប្រទេស
ការផ្សព្វផ្សាយ	សិក្ខាសាលាអំពីកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌	១២ វគ្គ	៩១៥ នាក់
	ផលិតស្គតអំពីកម្មវិធីកំណែទម្រង់និងសមិទ្ធផល ដើម្បីចាក់ផ្សាយតាមវិទ្យុនិងទូរទស្សន៍	១ ដង	ទូទាំងប្រទេស
ការបណ្តុះបណ្តាល	បណ្តុះបណ្តាលអំពីវិធីសាស្ត្រ បច្ចេកទេសស្រាវជ្រាវ សរសេរអត្ថបទវិភាគផ្នែកច្បាប់ និងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត	២ វគ្គ	១៣០ នាក់

ជាការឆ្លើយតបនឹងតម្រូវការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង ស្របតាមកំណើនប្រជាសាស្ត្រនិងការវិវត្តរបស់សង្គម ក្រសួងយុត្តិធម៌បានបង្កើនសមត្ថភាពការងារនិងពង្រឹង ការអនុវត្តការងារគ្រប់គ្រង ព្រមទាំងទាំងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្រសួងនិងតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ រួមមាន÷

- ការដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍តំបន់ចំនួនបី រួមមាន ឧទ្ធរណ៍បាត់ដំបង ឧទ្ធរណ៍ ព្រះសីហនុ និង ឧទ្ធរណ៍ត្បូងឃ្មុំ
- ការជួលកន្លែងធ្វើការបន្ថែមនៅអគារគយជាន់ទី២៩ និងជាន់ទី៣០ ដើម្បីឆ្លើយតបនឹងតម្រូវការសេវាមូលដ្ឋានរបស់មន្ត្រី
- ការដាក់ឱ្យដំណើរការសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកែប
- ការចាប់ផ្តើមសាងសង់នូវអគារថ្មីនៃសាលាឧទ្ធរណ៍ភ្នំពេញ
- ការចាប់ផ្តើមសាងសង់នូវអគារថ្មីនៃសាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្នុងការងារអនុវត្តនូវភារកិច្ចនិងការងារ រហូតសម្រេចបាននូវលទ្ធផល ដូចបានរៀបរាប់ជូនខាងលើ នេះ ក្រសួងបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជាធនធានមនុស្ស ធនធានហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ និងសំណង់អាគារសម្រាប់ធ្វើការជាដើម ដែលមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការនិងទំហំការងារ របស់ក្រសួងនាពេលបច្ចុប្បន្ន ជាពិសេសទំហំការងារតួនាទីនិងភារកិច្ចការទទួលខុសត្រូវរបស់ក្រសួងស្របតាម ច្បាប់មូលដ្ឋានទាំងបី ដែលតម្រូវឱ្យក្រសួងត្រូវមាន ថវិការច្រើនជាងមុន ចំនួនបុគ្គលិកដែលពោពេញដោយជំនាញនិងសមត្ថភាពច្រើនជាងមុន ព្រមទាំងសម្ភារៈ បរិក្ខា សំណង់ និងអាគារសម្រាប់មន្ត្រីធ្វើការច្រើននិងមានទំហំធំជាងមុន។ ជាមួយគ្នានេះ បញ្ហាជំងឺរាតត្បាតកូវីដ-១៩បានក្លាយជាឧបសគ្គដល់ការរៀបចំសកម្មភាព ជួបប្រជុំ ក្នុងការដំណើរការរៀបចំច្បាប់និងគោលនយោបាយអាទិភាពរបស់ក្រសួង ដែលធ្វើឱ្យមានការអូសបន្លាយរយៈពេលយូរផងដែរ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃការកម្មវិធីកែទម្រង់ច្បាប់និងយុត្តិធម៌ ក្រសួងយុត្តិធម៌បានដាក់ចេញនូវទិសអនុវត្តសកម្មភាពសំខាន់ៗ ដូចខាងក្រោម÷

❖ **បន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**
- ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន
- ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់
- ជំរុញលទ្ធភាពឱ្យទទួលព័ត៌មានអំពីច្បាប់និងតុលាការឱ្យកាន់តែប្រសើរឡើង
- ធ្វើឱ្យគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធឱ្យកាន់តែប្រសើរឡើង
- ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការនិងសេវាកម្មផ្នែកអយ្យការ
- បង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង
- ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់និងតុលាការ ឱ្យអាចបំពេញអាណត្តិរបស់ខ្លួនបានជោគជ័យ។

❖ **ការងារអភិវឌ្ឍច្បាប់**
- ពង្រឹងការរៀបចំច្បាប់ និងជម្រុញការអនុម័តច្បាប់
- ពង្រឹងនិងពង្រីកការផ្សព្វផ្សាយបទបញ្ញត្តិច្បាប់ និង
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់និងយុត្តិធម៌។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

❖ **លើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយរឿងក្តី**

- ពង្រឹងការបណ្តុះបណ្តាលច្បាប់និងជំនាញផ្សេងៗ ដល់មន្ត្រីអនុវត្តច្បាប់ រួមមាន មន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងអ្នកប្រកបវិជ្ជាជីវៈច្បាប់
- លើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ពិសេសនៅថ្នាក់មូលដ្ឋាន
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមសាលាជម្រះក្តី
- លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យយុត្តិធម៌ និង
- ពង្រឹងយន្តការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់។

❖ **លើកកម្ពស់សមត្ថភាពស្ថាប័ន**

- បង្កើនសមត្ថភាពការងារនិងពង្រឹងការអនុវត្តការងារ និង
- ពង្រីកនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្រសួង និងតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

៣. ចក្ខុវិស័យ និងបេសកកម្មរួមនៃកម្មវិធីកែទម្រង់ ៣ ឫក ១

យោងចក្ខុវិស័យនៃកម្មវិធីកែទម្រង់នីមួយៗ ក៏ដូចជាយុទ្ធសាស្ត្រចតុកោណ គោលដៅនៃកម្មវិធីកែទម្រង់ ៣ ឫក ១ គឺការសម្រេចឱ្យបាននូវអភិបាលកិច្ចល្អ ដើម្បីបម្រើប្រជាពលរដ្ឋ តាមរយៈការផ្តល់សេវាសាធារណៈ ក្នុងគោលបំណងជួយសម្រួលដល់សកម្មភាពសេដ្ឋកិច្ច ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍន៍ជាតិ។

ជារួម ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ ៣ ឫក ១ គួរផ្តោតសំខាន់ទៅលើ ១) គុណភាពសេវាសាធារណៈ ២) ប្រសិទ្ធភាពរដ្ឋបាលសាធារណៈ និង ៣) អភិបាលកិច្ចល្អ។

ដូចនេះ កម្មវិធីកែទម្រង់ ៣ ឫក ១ អាចកំណត់ចក្ខុវិស័យដូចខាងក្រោម ÷

«ពលរដ្ឋមានជំនឿលើគុណភាពនៃសេវាសាធារណៈ និងទំនុកចិត្តលើប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ នៅក្នុងមាគ៌ានៃសុខសន្តិភាពនិងការអភិវឌ្ឍ ក្នុងយុគសម័យបច្ចេកវិទ្យា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល»

ដោយសារកម្មវិធីកែទម្រង់នីមួយៗ សុទ្ធតែចាប់យកការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មជាយាន ដូចជាការគ្រប់គ្រងស្ថាប័នតាមអំណាចហិរញ្ញវត្ថុ ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមអំណាចត្រួតពិនិត្យ និងការគ្រប់គ្រងមន្ត្រីតាមអំណាចនៃការចាត់ចែង កម្មវិធីកែទម្រង់ ៣ ឫក ១ អាចយក «**ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម**» នេះ ជាយានរួម ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ។ ដូចនេះ បេសកកម្មនៃកម្មវិធីកែទម្រង់ ៣ ឫក ១ អាចកំណត់ ដូចខាងក្រោម÷

«ពង្រឹងប្រសិទ្ធិភាពនៃអភិបាលកិច្ចនិងរដ្ឋបាលសាធារណៈ ក្នុងគោលបំណងបង្កើនគុណភាព នៃសេវាសាធារណៈ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ តាមរយៈការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម»។

៤. លទ្ធផលរំពឹងទុករួម និងយុទ្ធសាស្ត្រអនុវត្ត

រាល់ផែនការសកម្មភាពកែទម្រង់របស់កម្មវិធីកែទម្រង់នីមួយៗនៃកម្មវិធីកែទម្រង់ ៣ ឫក ១ សុទ្ធតែជាផ្នែកមួយនៃការអភិវឌ្ឍតាមបែបផែនថ្មី ដោយយកការអនុវត្តក្នុងវិស័យឯកជនមកអនុវត្តក្នុងវិស័យសាធារណៈ:រួមមាន ក) ការកំណត់ស្ងួចនាការវាស់ស្ទង់លទ្ធផលការងារជាជាងការកំណត់អំពីរបៀបវារៈការងារលម្អិត ខ) ការប្រើប្រាស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម គ) ការបង្កើតគណនេយ្យភាពនិងការប្រកួតប្រជែង ដោយប្រើការលើកទឹកចិត្តនិងការទទួលយកយោបល់រិះគន់

ពីប្រជាពលរដ្ឋ និង ឃ) ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងរដ្ឋបាលសាធារណៈ និងការផ្តល់សេវាសាធារណៈ។ គន្លឹះនៃការអនុវត្តកម្មវិធីកែទម្រង់ឱ្យមានសក្តិសិទ្ធភាព គឺត្រូវរៀបចំកម្មវិធីកែទម្រង់តាមការអភិវឌ្ឍន៍តាមបែបផែនថ្មីនោះ ឱ្យស្របតាមបរិបទនិងតម្រូវការជាក់ស្តែងនៃនយោបាយ សេដ្ឋកិច្ច និងសង្គម។

ជារួម ការរៀបចំសកម្មភាពកែទម្រង់ត្រូវបែងចែកជាពីរប្រភេទធំៗគឺ ១) ខ្សែខាងលើ ដោយផ្តោតលើការរៀបចំគោលនយោបាយ ការដឹកនាំការអនុវត្ត និងការតាមដានការអនុវត្ត និង ២) ខ្សែខាងក្រោម ដោយផ្តោតលើការបង្កើតនិងការផ្តល់សេវាសាធារណៈផ្ទាល់ជូនប្រជាពលរដ្ឋ។ ទស្សនាទានចក្ខុវិស័យកម្មវិធីកែទម្រង់ ៣ ឃ្លុក ១ នេះ នឹងកំណត់សកម្មភាពកែទម្រង់ត្រឹមខ្សែខាងលើជាកម្រិតនយោបាយ ដោយទុកឱ្យកម្មវិធីកែទម្រង់នីមួយៗកំណត់សកម្មភាពកែទម្រង់ខ្សែខាងក្រោមវិញ។

ដូចនេះ ទស្សនាទានចក្ខុវិស័យកម្មវិធីកែទម្រង់ ៣ ឃ្លុក ១ នេះ កំណត់នូវលទ្ធផលរំពឹងទុក បី ដោយលទ្ធផលរំពឹងទុកនីមួយៗនឹងកំណត់អំពីយុទ្ធសាស្ត្រសម្រាប់អនុវត្ត និងសកម្មភាពជាអាទិភាព ដើម្បីសម្រេចលទ្ធផលរំពឹងទុក។

ក. លទ្ធផលរំពឹងទុករួមទីមួយ

តាមការបកស្រាយខាងលើ បញ្ហាដែលជាមូលដ្ឋានគ្រឹះរាំងស្ទះដល់ការអនុវត្តកម្មវិធីកែទម្រង់ ៣ ឃ្លុក ១ គឺ ១) អសង្គតិភាពនិងភាពមិនទាន់សមស្របនៃរចនាសម្ព័ន្ធ រួមមានរចនាសម្ព័ន្ធផ្ទៃក្នុងនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធការងារថ្នាក់ជាតិ ២) អសង្គតិភាពនៃលិខិតបទដ្ឋានគតិយុត្ត ដោយមានបទប្បញ្ញត្តិក្រោមច្បាប់ច្រើនដែលមិនមានសុខដុមនីយកម្ម ហើយបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពអនុវត្ត និង ៣) កង្វះធនធានក្នុងការអនុវត្តសកម្មភាពកែទម្រង់ផ្ទាល់ ក៏ដូចជាផែនការការងារដែលជាលទ្ធផលនៃសកម្មភាពកែទម្រង់។ បញ្ហាទាំងបីខាងលើ គឺជាបញ្ហាប្រឈមដែលជួបប្រទះដោយកម្មវិធីកែទម្រង់នីមួយៗ ហើយមានភាពប្រទាក់ក្រឡាគ្នា ដែលត្រូវការដំណោះស្រាយរួមគ្នាក្នុងយន្តការនៃកម្មវិធីកែទម្រង់ ៣ ឃ្លុក ១ នេះ។

លទ្ធផលរំពឹងទុករួមទី១ គឺ **«មានយន្តការជាក់លាក់ សម្រាប់កិច្ចសហការនិងសម្រុះសម្រួលគ្នាដោះស្រាយ បញ្ហារួមឱ្យមានសុខដុមនីយកម្ម ដើម្បីពង្រឹងមូលដ្ឋានគ្រឹះគាំទ្រសកម្មភាពកែទម្រង់»**។

ដើម្បីសម្រេចលទ្ធផលរំពឹងទុកខាងលើ ដើម្បីធានាសុខដុមនីយកម្មរចនាសម្ព័ន្ធ គតិយុត្ត និងធនធាន ការដ្ឋានកែទម្រង់ ៣ ឃ្លុក ១ ត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម÷

- រៀបចំផែនការកែសម្រួលរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយពិចារណារួមគ្នាទៅលើតម្រូវការនៃថវិកាកម្មវិធីនិងអង្គភាពថវិកា នីតិវិធីរដ្ឋបាល ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ
- រៀបចំឱ្យមានយន្តការរួមស្តីពីវិធាននិងនីតិវិធីនៃការរៀបចំនិងអនុម័តច្បាប់និងបទប្បញ្ញត្តិ ដើម្បីធានាសង្គតិភាពជម្រុញការផ្សព្វផ្សាយ និងបង្កើនប្រសិទ្ធភាពអនុវត្ត
- ពង្រឹងនិងសម្រួលយន្តការចែករំលែកព័ត៌មានក្នុងកម្មវិធីកែទម្រង់ ៣ ឃ្លុក ១ ដើម្បីបង្កើនការសិក្សាស្វែងយល់ពីគ្នា
- រៀបចំឱ្យមានផែនការកសាងសមត្ថភាពនិងបណ្តុះបណ្តាលមន្ត្រីជាប្រព័ន្ធនៅក្នុងកម្មវិធីកែទម្រង់ ៣ ឃ្លុក ១

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- រៀបចំឱ្យមានផែនការសកម្មភាពគាំទ្រការកសាងរដ្ឋាភិបាលឌីជីថល ក្នុងកម្មវិធីកែទម្រង់ ៣ ឫក ១ ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា។

ដើម្បីសម្រេចអនុវត្តយុទ្ធសាស្ត្រខាងលើ កម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវអនុវត្តសកម្មភាពគោលខាងក្រោម ជាអាទិភាព÷

- រៀបចំគោលការណ៍ណែនាំទូទៅស្តីពីការកែសម្រួលរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវមានវេទិកាសម្រាប់ពិភាក្សាកែសម្រួលរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយទៅដល់តម្រូវការ នៃកម្មវិធីកែទម្រង់នីមួយៗ
- ប្រមូលផ្តុំព័ត៌មាន ទិន្នន័យ និងឯកសារ អំពីរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីយកមកចែករំលែក វិភាគ ពិភាក្សា និងកំណត់នូវបញ្ហាប្រឈមរួម
- បង្កើតផែនការកែសម្រួលរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានសង្គតិភាព និងសុខដុមនីយកម្ម ឆ្លើយតបនឹងតម្រូវការនៃកម្មវិធីកែទម្រង់នីមួយៗនៃកម្មវិធីកែទម្រង់ ៣ ឫក ១
- រៀបចំគោលការណ៍ណែនាំរួមមួយស្តីពីវិធាននិងនីតិវិធីរៀបចំច្បាប់និងបទប្បញ្ញត្តិ ដោយពិភាក្សាបង្កើតឱ្យមាន ១) ការសិក្សាវាយតម្លៃអំពីផលប៉ះពាល់នៃសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិថ្មី ទៅលើ ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលមានជាធរមាន សេដ្ឋកិច្ច និងសង្គម ២) ការរៀបចំឯកសារគោលនយោបាយកំណត់អំពីបរិបទមូលហេតុ គោលបំណង និងគោលដៅ ជាក្របខ័ណ្ឌនៃការរៀបចំសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិថ្មី ៣) លក្ខខណ្ឌទម្រង់នៃឯកសារសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិ ៤) វិធាននិងនីតិវិធីនៃការប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិ ៥) យន្តការផ្សព្វផ្សាយនិងបណ្តុះបណ្តាលភាគីពាក់ព័ន្ធអំពីច្បាប់និងបទប្បញ្ញត្តិដែលបានអនុម័ត ៦) យន្តការតាមដាននិងវាយតម្លៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិដែលបានអនុម័ត និង ៧) យន្តការពិគ្រោះ ប្រឹក្សា និងបកស្រាយច្បាប់និងបទប្បញ្ញត្តិជូនភាគីពាក់ព័ន្ធនឹងសាធារណជន
- រៀបចំឱ្យមានកិច្ចប្រជុំចែករំលែកព័ត៌មាននិងពិភាក្សាលើសេចក្តីព្រាងនិងរបាយការណ៍អនុវត្តផែនការថវិកានិងធនធានមនុស្ស ក្នុងការអនុវត្តសកម្មភាពកែទម្រង់នីមួយៗ ក្រោមវេទិកានៃកម្មវិធីកែទម្រង់ ៣ ឫក ១ ដើម្បីអាចឱ្យការដ្ឋានកែទម្រង់នីមួយៗបានស្វែងយល់ពីគ្នា ហើយអាចកំណត់បានន្ធវ៉ុងចំណាយជាន់គ្នាដែលអាចកាត់ចោលបាន និងលទ្ធភាពក្នុងការផ្លាស់ប្តូរមន្ត្រីរវាងការដ្ឋានកែទម្រង់ ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹង
- រៀបចំគោលការណ៍ក្នុងការបង្កើតបញ្ជីរាយនាមគុណវុធិនិងការទទួលខុសត្រូវរបស់មន្ត្រីបង្គោលក្នុងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលកម្មវិធីកែទម្រង់នីមួយៗ ត្រូវការ
- កំណត់ទិសដៅនិងផែនការជាក់លាក់ ក្នុងការធ្វើសមាហរណកម្មទោសវិន័យដែលនៅរាយប៉ាយតាមបណ្តាបទប្បញ្ញត្តិ ហើយសម្រួលទោសវិន័យទាំងនោះឱ្យសក្តិសម ក្នុងកម្រិតដែលអាចអនុវត្តបានឱ្យមានប្រសិទ្ធភាព
- រៀបចំនិងអនុម័តរួមគ្នាលើយុទ្ធសាស្ត្រជាតិស្តីពីការបណ្តុះបណ្តាលមន្ត្រី ដោយផ្តោតសំខាន់លើ ១) ការរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធបច្ចេកវិទ្យា ២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងជំនាញទន់

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

៣) ការផ្សព្វផ្សាយនិងបណ្តុះបណ្តាលអំពីវិធាននិងនិតិវិធីថ្មី ដែលជាលទ្ធផលនៃកម្មវិធីកែទម្រង់ ៤) ការចែករំលែកឯកសារសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ៥) យន្តការបណ្តុះបណ្តាលបន្តផ្ទៃក្នុងនិងអន្តរស្ថាប័ន និង ៦) យន្តការផ្លាស់ប្តូរមន្ត្រីឱ្យធ្វើការតាមបណ្តាក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និង

- រៀបចំបង្កើតផែនការឌីជីថលក្នុងកម្មវិធីកែទម្រង់ ៣ ឬក ១ ដែលផែនការនោះអាចកំណត់អំពី ១) តម្រូវការថវិកាក្នុងការវិនិយោគនិងអភិវឌ្ឍន៍លើប្រព័ន្ធ និងទិញសម្ភារៈ ២) ស្តង់ដាបច្ចេកទេសនិងកម្រិតគុណភាពនៃសម្ភារៈបច្ចេកវិទ្យា ដែលត្រូវប្រើប្រាស់ ឱ្យមានសន្ទានកម្មនៃប្រព័ន្ធរដ្ឋបាលឌីជីថល ៣) វិធាន នីតិវិធី និងគោលការណ៍ណែនាំក្នុងការប្រើប្រាស់និងថែទាំសម្ភារៈ និងប្រព័ន្ធបច្ចេកវិទ្យា និង ៤) តម្រូវការបច្ចេកទេសក្នុងការកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា។

ខ. លទ្ធផលរំពឹងទុករួមទីពីរ

កម្មវិធីកែទម្រង់នីមួយៗនៃកម្មវិធីកែទម្រង់ ៣ ឬក ១ សុទ្ធតែមានគោលបំណងអនុវត្តការគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម។ ជាក់ស្តែង កម្មវិធីកែទម្រង់ ៣ ឬក ១ អាចធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់នូវការគ្រប់គ្រងផ្នែកលើសមិទ្ធកម្មជាប្រព័ន្ធ ដោយមានការគ្រប់គ្រងផ្នែកលើសមិទ្ធកម្មលើហិរញ្ញវត្ថុ មន្ត្រី និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចនេះ លទ្ធផលរំពឹងទុករួមទី២ គឺ **«សុខដុមនីយកម្មលើប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម»**។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកខាងលើ កម្មវិធីកែទម្រង់ ៣ ឬក ១ ត្រូវមានយុទ្ធសាស្ត្រខាងក្រោម÷

- រៀបចំសម្របសម្រួលឱ្យមានផែនការសកម្មភាពក្នុងការអនុវត្តការគ្រប់គ្រងផ្នែកលើសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់នីមួយៗឱ្យមានលក្ខណៈបន្ស៊ីគ្នាជាប្រព័ន្ធ
- រៀបចំបង្កើតឱ្យមានទម្រង់បទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តដែលមានសុខដុមនីយកម្ម សម្រាប់អនុវត្តការគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម
- កែសម្រួលប្រទិតិនៃការរៀបចំផែនការនិងគម្រូផែនការក្នុងការគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម រួមមានផែនការហិរញ្ញវត្ថុ ផែនការមន្ត្រី ផែនការអនុវត្ត ផែនការរដ្ឋបាល និងផែនការអភិវឌ្ឍន៍ ឱ្យមានសុខដុមនីយកម្ម
- កែសម្រួលមុខងារតាមដាននិងវាយតម្លៃ រួមមានអធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុង ឱ្យមានសមាណ-គតិភាព និង
- បង្កើនគណនេយ្យភាពសង្គម ដោយជម្រុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ។

ក្នុងការអនុវត្តយុទ្ធសាស្ត្រខាងលើ សកម្មភាពជាអាទិភាពមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម ÷

- ប្រមូលធាតុចូលពាក់ព័ន្ធនឹងបញ្ហាប្រឈមជាចាំបាច់ទៅលើការឈានទៅដល់ការអនុវត្តការគ្រប់គ្រង ផ្នែកលើសមិទ្ធកម្ម
- បង្កើតក្រុមការងារ ដើម្បីរៀបចំគោលការណ៍នៃការគ្រប់គ្រងផ្នែកលើសមិទ្ធកម្មជាប្រព័ន្ធ
- រៀបចំអនុវត្តការគ្រប់គ្រងផ្នែកលើសមិទ្ធកម្មនៅក្នុងបណ្តាការដ្ឋានកែទម្រង់នីមួយៗ ជាគម្រូ

- បង្កើតឱ្យមានយន្តការផ្ទេរឬធ្វើវិមជ្ឈការហិរញ្ញវត្ថុ មុខងារ និងអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរូបភាពជារង្វាន់លើកទឹកចិត្ត ឆ្លើយតបទៅនឹងការសម្រេចបាននូវសមិទ្ធផលដែលជាសូចនាកររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ
- ជ្រើសរើសក្រសួង-ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ ជាស្ថាប័នដែលត្រូវអនុវត្តការគ្រប់គ្រង ផ្អែកលើសមិទ្ធកម្មសាកល្បងក្រោមកម្មវិធីកែទម្រង់ ៣ ឃ្លីក ១ រួមគ្នា ដើម្បីវាស់ស្ទង់ប្រសិទ្ធភាពនិងបញ្ហាប្រឈមជាក់ស្តែង
- រៀបចំបង្កើតគម្រូលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មឱ្យមានសុខដុមនីយ-កម្មនិងសង្គតិភាព ជាប្រព័ន្ធ
- កែសម្រួលលើប្រតិទិនៃការរៀបចំសេចក្តីព្រាងផែនការក្រសួង-ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានរយៈពេលសមស្របក្នុងការទទួលបានព័ត៌មាននិងទិន្នន័យគ្រប់ជ្រុងជ្រោយ
- រៀបចំបង្កើតឱ្យមានគោលការណ៍ណែនាំការរៀបចំផែនការ ឱ្យមានសុខដុមនីយកម្មនិងតម្លាភាព
- ធ្វើសុខដុមនីយកម្មប្រព័ន្ធអធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុង ដើម្បីធានាថាការរៀបចំរបាយការណ៍និងការវាយតម្លៃ អាចធ្វើឡើងរួមនិងស្របគ្នា ដោយកាត់បន្ថយបញ្ហាការិយាធិបតេយ្យ នៃការរៀបចំរបាយការណ៍និងនីតិវិធីនៃការវាយតម្លៃច្រើនដង
- សម្របសម្រួលយន្តការគណនេយ្យភាពសង្គម និង
- ផ្សព្វផ្សាយអំពីយន្តការគណនេយ្យភាពសង្គម ដើម្បីបង្កើនការចូលរួម និងទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ។

គ. លទ្ធផលរំពឹងទុករួមទីបី

ក្តាចម្បងដែលគាំទ្រកម្មវិធីកែទម្រង់សាធារណៈទាំងមូល ក៏ដូចជាកម្មវិធីកែទម្រង់ ៣ ឃ្លីក ១ គឺ ១) ឆន្ទៈនយោបាយ ២) ការពង្រឹងសមត្ថភាពស្ថាប័ន ៣) ការលើកទឹកចិត្ត ៤) តម្លាភាព និង ៥) បច្ចេកវិទ្យា។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** មានឆន្ទៈនយោបាយខ្ពស់ក្នុងការកែទម្រង់ដ៏ស៊ីជម្រៅ តាមអភក្រម «**ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់**»។ ចំពោះបច្ចេកវិទ្យា រាជរដ្ឋាភិបាលបានអនុម័តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ក្នុងគោលដៅកែទម្រង់រដ្ឋបាលសាធារណៈទៅជារដ្ឋាភិបាលឌីជីថល ហើយនឹងមានការអនុម័តគោលនយោបាយរដ្ឋាភិបាលឌីជីថលដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយខាងលើ។ ដូចនេះ ទស្សនាទានចក្ខុវិស័យកម្មវិធីកែទម្រង់ ៣ ឃ្លីក ១ នឹងដោះស្រាយបញ្ហាសមត្ថភាពស្ថាប័ន ការលើកទឹកចិត្ត និងតម្លាភាព មកកំណត់យុទ្ធសាស្ត្រនិងសកម្មភាពជាអាទិភាពតែប៉ុណ្ណោះ។

ដូចនេះ លទ្ធផលរំពឹងទុករួមទី៣ គឺ **«កិច្ចសហការយ៉ាងជិតស្និទ្ធ និងភាពជាម្ចាស់ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ ៣ ឃ្លីក ១»**។

ដើម្បីសម្រេចលទ្ធផលរំពឹងទុកខាងលើ កម្មវិធីកែទម្រង់ ៣ ឃ្លីក ១ ត្រូវមានយុទ្ធសាស្ត្រខាងក្រោម ÷

- ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តផែនការសកម្មភាពកែទម្រង់ ៣ ឃ្លីក ១ ដោយបង្កើនថវិកា មុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាចនៃការអនុវត្តមុខងារ
- បង្កើននិងពង្រឹងសិទ្ធិអំណាចរបស់គណៈកម្មាធិការ និងអគ្គលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់

- បង្កើនកាតព្វកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ ៣ ឃ្លក ១ ដោយបង្កើតឱ្យមានយន្តការជម្រុញការប្តេជ្ញាចិត្ត ការសម្របសម្រួល និងកិច្ចសហការ
- បង្កើនប្រសិទ្ធភាពនៃការលើកទឹកចិត្ត ក្នុងការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ ៣ ឃ្លក ១
- បញ្ជាបចំណេះដឹងអំពីកម្មវិធីកែទម្រង់ ៣ ឃ្លក ១ និងបង្កើនគុណតម្លៃនៃកម្មវិធីកែទម្រង់ ៣ ឃ្លក ១ ដើម្បីទទួលបានការគាំទ្រនិងចូលរួមពីភាគីពាក់ព័ន្ធនឹងសាធារណជន និង
- បង្កើនតម្លាភាពនិងការចែករំលែកព័ត៌មានរវាងកម្មវិធីកែទម្រង់ ៣ ឃ្លក ១។

ដើម្បីគាំទ្រយន្តការខាងលើ កម្មវិធីកែទម្រង់ ៣ ឃ្លក ១ ត្រូវអនុវត្តសកម្មភាពខាងក្រោមជាអាទិភាព÷

- ធ្វើសមាហរណកម្មក្រុមការងារឬគណៈកម្មការកែទម្រង់នីមួយៗនៃកម្មវិធីកែទម្រង់ ៣ ឃ្លក ១ នៅតាមបណ្តាក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្ថិតនៅក្រោមក្រុមការងារឬគណៈកម្មការ តែមួយ
- រៀបចំឱ្យក្រុមការងារឬគណៈកម្មការកែទម្រង់ ៣ ឃ្លក ១ នៅតាមបណ្តាក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្លាយជាអង្គភាពថវិកា ដោយមាន ១) គម្រូលិខិតបទដ្ឋានគតិយុត្ត ដែលក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុម័ត ដើម្បីបង្កើតក្រុមការងារឬគណៈកម្មការកែទម្រង់ ៣ ឃ្លក ១ ដោយមានបញ្ជាក់ពីមុខតំណែងនិងគុណវុធិនៃសមាជិក ២) លក្ខខណ្ឌយោង ដែលបរិយាយអំពីមុខងារនិងសិទ្ធិអំណាចរបស់ក្រុមការងារឬគណៈកម្មការនោះ ៣) ថវិកាទ្រទ្រង់សកម្មភាព និងរង្វាន់លើកទឹកចិត្ត ដល់ការអនុវត្តមុខងាររបស់ក្រុមការងារឬគណៈកម្មការនោះ និង ៤) យន្តការរាយការណ៍ជូនអន្តរគណៈកម្មាធិការនិងលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ ៣ ឃ្លក ១
- បង្កើតយន្តការជ្រើសរើសក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមកធ្វើជាគម្រូ ក្នុងការអនុវត្តផែនការសកម្មភាពកែទម្រង់សាកល្បងរួមគ្នា ដើម្បីស្វែងយល់អំពីបញ្ហាប្រឈមក៏ដូចជាទទួលបានជាបទពិសោធន៍រួមគ្នា ហើយទទួលបានលទ្ធផលលឿន ក្នុងគោលដៅបង្ហាញជាករណីជោគជ័យជាក់ស្តែងទៅស្ថាប័នផ្សេងៗទៀត ឱ្យចូលរួមអនុវត្តនិងគាំទ្រកម្មវិធីកែទម្រង់
- រៀបចំឡើងវិញនូវគោលការណ៍កំណត់និងផ្តល់រង្វាន់ដោយ ១) ប្រាក់រង្វាន់ខ្លះអាចត្រូវផ្ទួបគ្នាដើម្បីបង្កើនបរិមាណនិងគុណតម្លៃ ២) កំណត់សូចនាករនិងកម្រិតគុណភាពការងារ ដើម្បីអាចវាយតម្លៃផ្តល់រង្វាន់ ៣) បង្កើតរង្វាន់ជាហិរញ្ញវត្ថុផងនិងមិនមែនហិរញ្ញវត្ថុផង ៤) កំណត់យន្តការផ្តល់រង្វាន់ជូន ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋានកែទម្រង់ និងមន្ត្រី និង ៥) កាត់បន្ថយការផ្តល់រង្វាន់ដោយប្រើប្រាក់ចំណូលជាមូលដ្ឋានជាបណ្តើរៗ
- បញ្ចូលកម្មវិធីកែទម្រង់ ៣ ឃ្លក ១ ទៅក្នុងកម្មវិធីសិក្សា
- បង្កើនការផ្សព្វផ្សាយជាសាធារណៈអំពីកម្មវិធីកែទម្រង់ ៣ ឃ្លក ១ ក៏ដូចជាលទ្ធផលនៃកម្មវិធីកែទម្រង់ ៣ ឃ្លក ១
- បង្កើនការបណ្តុះបណ្តាល និងសិក្ខាសាលាអំពីកម្មវិធីកែទម្រង់ ៣ ឃ្លក ១ ជាប្រចាំ ដល់បណ្តាមន្ត្រី បុគ្គលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ តាមរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- បង្កើតថ្នាលផ្ទុកនិងចែករំលែកព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិចរួមមួយ ជាផ្នែកមួយនៃមជ្ឈមណ្ឌល ទិន្នន័យ របស់រដ្ឋាភិបាល ដើម្បីរក្សានិងចែករំលែកឯកសារនិងទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពកម្មវិធីកែទម្រង់។

៥. ការគ្រប់គ្រងនិងការអនុវត្ត

យោងតាមការរបាយការណ៍ លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងផែនការសកម្មភាពអាទិភាពខាងលើ ផែនការសកម្មភាពជាច្រើននឹងត្រូវអនុវត្តរួមគ្នា ក្រោមយន្តការនៃកម្មវិធីកែទម្រង់ ៣ ឫក ១។ ដូចនេះ កម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវមានយន្តការច្បាស់លាស់ក្នុងការរៀបចំ ពិភាក្សា សម្រេច អនុវត្ត តាមដាន និងវាយតម្លៃ។

ក. យន្តការពិនិត្យសម្រេច

ទស្សនាទាន ចក្ខុវិស័យ និងយុទ្ធសាស្ត្រ កម្មវិធីកែទម្រង់ ៣ ឫក ១ នេះនឹងបែងចែកឱ្យការដ្ឋានកែទម្រង់នីមួយៗ ទទួលបន្ទុកអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ ក្រោមទស្សនាទាននិងយុទ្ធសាស្ត្ររួមនេះ ហើយដាក់ជូនអន្តរការដ្ឋានកែទម្រង់ ៣ ឫក ១ ពិនិត្យនិងកែសម្រួលរួមគ្នា ដើម្បីដាក់បន្តទៅក្នុងកិច្ចប្រជុំអន្តរគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ ៣ ឫក ១ ពិភាក្សានិងសម្រេច តាមជម្រើសដែលផ្តល់ជូនដោយអន្តរការដ្ឋានកែទម្រង់ ៣ ឫក ១។

សេចក្តីសម្រេចរបស់អន្តរគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវធ្វើឡើងដោយមតិឯកច្ឆន្ទ ជាសេចក្តី-សម្រេចលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខារួមគ្នាដោយប្រធានគណៈកម្មាធិការនៃកម្មវិធីកែទម្រង់នីមួយៗ។ ប្រសិនបើអន្តរគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ ៣ ឫក ១ មិនអាចសម្រេចបាន អន្តរគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវធ្វើរបាយការណ៍ទៅប្រមុខរាជរដ្ឋាភិបាល ដោយបរិយាយអំពីសារបាននិងជម្រើសនៃការសម្រេច ដើម្បីឱ្យប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច ក្នុងទម្រង់ជាសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

តារាងទី ៨ ៖ វិធាននិងនីតិវិធីនៃការរៀបចំនិងសម្រេចផែនការសកម្មភាព ក្នុងកម្មវិធីកែទម្រង់៣ ឫក១



ក្នុងក្របខ័ណ្ឌការងារជាកម្រិតបច្ចេកទេស ការដ្ឋានកែទម្រង់នីមួយៗត្រូវយកសកម្មភាពជាអាទិភាព ដែលខ្លួនទទួលបន្ទុក ទៅបែងចែកធ្វើជាកិច្ចការលម្អិត សម្រាប់មន្ត្រីបច្ចេកទេសអនុវត្តផ្ទាល់ ដោយកំណត់អំពីកាលកំណត់នៃការងារទាំងនោះ។

អន្តរអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១ ត្រូវនៅបន្តប្រជុំប្រចាំត្រីមាស តាមរបបប្តូរវេន ដើម្បីតាមដានការអនុវត្តផែនការសកម្មភាពដែលទទួលបន្ទុកដោយកម្មវិធីកែទម្រង់នីមួយៗ តាមកាលកំណត់។ ប្រសិនបើចាំបាច់ អន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១ អាចប្រជុំតាមការស្នើសុំរបស់ការដ្ឋានកម្មវិធីកែទម្រង់ណាមួយ ដើម្បីពិនិត្យនិងសម្រេចលើបញ្ហាផ្សេងៗ។

អន្តរគណៈកម្មាធិការកែទម្រង់ ៣ ឫក ១ ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ក្រោមវត្តមានរបស់ប្រធានគណៈកម្មាធិការនៃកម្មវិធីកែទម្រង់នីមួយៗ ដើម្បីពិនិត្យនិងសម្រេចលើរបៀបវារៈប្រជុំ ដែលរៀបចំដោយអន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១។

ខ. យន្តការអនុវត្ត

សេចក្តីសម្រេចរបស់អន្តរគណៈកម្មាធិការកែទម្រង់ ៣ ឫក ១ ឬរាជរដ្ឋាភិបាល ត្រូវអនុវត្តដោយការដ្ឋានកែទម្រង់នីមួយៗ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។ ដូចនេះ គណៈកម្មការឬក្រុមការងារកម្មវិធីកែទម្រង់ ៣ ឫក ១ នៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកផ្សព្វផ្សាយ បណ្តុះបណ្តាល និងតាមដានការអនុវត្ត ហើយធ្វើរបាយការណ៍អំពីការអនុវត្ត ជូនអន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១។ ក្រោយថ្នាលចែករំលែកព័ត៌មានអេឡិចត្រូនិចត្រូវបានរៀបចំហើយ គណៈកម្មការ ឬក្រុមការងារកម្មវិធីកែទម្រង់ ៣ ឫក ១ នៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក៏អាចចែករំលែកទិន្នន័យ ឯកសារ និងរបាយការណ៍ តាមថ្នាលចែករំលែកព័ត៌មាននោះផងដែរ។

ប្រសិនបើមានបញ្ហាប្រឈមដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា គណៈកម្មការឬក្រុមការងារកម្មវិធីកែទម្រង់ ៣ ឫក ១ តាមបណ្តាក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរាយការណ៍ទៅអន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១ ហើយអន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១ អាចយកបញ្ហានោះទៅពិភាក្សានិងរកដំណោះស្រាយនៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

ដើម្បីធានាឱ្យបានថា ការអនុវត្តសកម្មភាពអាទិភាពនីមួយៗក្នុងកម្មវិធីកែទម្រង់ ៣ ឫក ១ ធ្វើឡើងដោយយល់ច្បាស់អំពីកម្មវិធីកែទម្រង់ ៣ ឫក ១ និងបញ្ហាប្រឈម យន្តការកម្មវិធីកែទម្រង់ ៣ ឫក ១ អាចរៀបចំឱ្យមានការធ្វើវិបស្សនា រវាងស្ថាប័នពាក់ព័ន្ធនៃកម្មវិធីកែទម្រង់ ៣ ឫក ១។ ដើម្បីឱ្យវិបស្សនានេះមានប្រសិទ្ធភាព អន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១ អាចរៀបចំលម្អិតអំពីនីតិវិធីនៃការធ្វើវិបស្សនា ដោយយកបទពិសោធន៍វិបស្សនាបែបសមុទ្រខៀវ (blue ocean) របស់ប្រទេសម៉ាឡេស៊ី មកអនុវត្ត។

គ. យន្តការតាមដានការអនុវត្ត

ផែនការសកម្មភាពក្រោមកម្មវិធីកែទម្រង់ ៣ ឫក ១ មានការកំណត់សូចនាករតាមឆ្នាំ។ ជាផែនការការដ្ឋានកែទម្រង់ដែលទទួលបន្ទុកអនុវត្តកម្មវិធីសកម្មភាពនីមួយៗ ត្រូវរៀបចំផែនការប្រចាំឆ្នាំនៃការអនុវត្តរបស់ខ្លួន ដោយមានសូចនាករកំណត់ដាក់ជូនអន្តរការដ្ឋានកែទម្រង់ ៣ ឫក ១ ពិនិត្យ តាមដាន និងរាយការណ៍ បន្តទៅអន្តរគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ ៣ ឫក ១។ រៀងរាល់ចុងឆ្នាំ ការដ្ឋានកែទម្រង់ទទួលបន្ទុកអនុវត្តសកម្មភាពជាអាទិភាព ត្រូវរាយការណ៍អំពីវឌ្ឍនភាព ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនៃការអនុវត្តកិច្ចការរបស់ខ្លួន ជូនអន្តរអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកម្មវិធីកែទម្រង់ ៣ ឫក ១ ដោយមានភ្ជាប់ជូននូវរាល់ឯកសារព្រាងឬយោង ប្រសិនបើមាន។ ការរាយការណ៍

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

នេះក៏អាចធ្វើឡើងតាមថ្នាលចែករំលែកព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិចផងដែរ។ អន្តរការដ្ឋានៃកម្មវិធីកែទម្រង់ ៣ ឫក ១ អាចពិនិត្យមើលរបាយការណ៍នោះ ដើម្បីផ្តល់ជាអនុសាសន៍ឬកំណត់ចំណុចដែលត្រូវរាយការណ៍បន្តទៅអន្តរគណៈកម្ម-ធិការកែទម្រង់ ៣ ឫក ១ ពិភាក្សា និងសម្រេចទៅលើចំណុចគន្លឹះ។

ចំពោះការតាមដាននិងវាយតម្លៃការអនុវត្តកិច្ចការក្រោមកម្មវិធីកែទម្រង់ ៣ ឫក ១ គណៈកម្មការឬក្រុមការងារកម្មវិធីកែទម្រង់ ៣ ឫក ១ នៅតាមបណ្តាក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំជារបាយការណ៍វាយតម្លៃការអនុវត្តសកម្មភាពទាំងនោះ ដើម្បីដាក់ជូនអន្តរការដ្ឋានកែទម្រង់ ៣ ឫក ១ ពិនិត្យនិងវាយតម្លៃជារួម ដើម្បីកំណត់ការកែសម្រួល ប្រសិនជាចាំបាច់ ឬរាយការណ៍បន្តទៅអន្តរគណៈកម្មាធិការកែទម្រង់ ៣ ឫក ១។

៦. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក កម្មវិធីកែទម្រង់នីមួយៗ រួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាការសម្រេចបានន្ទវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលដែលផ្តោតលើអភិបាលកិច្ចល្អជាស្នូល។

ការដ្ឋានកែទម្រង់ទាំងបួនមានន្ទវយន្តការការងារមិនដូចគ្នា មានរចនាសម្ព័ន្ធការងារ និងកម្មវិធីជាតិមិនដូចគ្នា និងមានវឌ្ឍនភាពនិងក្របខ័ណ្ឌនៃការអនុវត្តការងារកែទម្រង់មិនស្មើគ្នា និងមិនមានយន្តការកំណត់ជាក់លាក់អំពីភាពប្រទាក់ក្រឡារវាងគ្នានិងគ្នា ដែលកត្តាទាំងនេះជាហេតុនាំឱ្យយន្តការសម្របសម្រួលការងារកែទម្រង់ ៣ បូក ១ ដំណើរការមិនរលូន និងមានប្រសិទ្ធភាពក្នុងកម្រិតមួយទាប។ ដោយឡែក ការគាំទ្ររវាងកម្មវិធីកែទម្រង់មួយនិងកម្មវិធីកែទម្រង់មួយ ជាកត្តាចាំបាច់មិនអាចខ្វះបាន និងផ្តល់ជាបច្ច័យជាវិជ្ជមានសម្រាប់ការអនុវត្តយន្តការសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ដោយឈរលើបូរណភាព ភាពជាម្ចាស់ និងឯករាជ្យភាពនៃកម្មវិធីកែទម្រង់នីមួយៗ។

ក្នុងមហិច្ឆតានៃការសម្រេចការងារកែទម្រង់ធំៗរបស់រាជរដ្ឋាភិបាល ដែលមានតួអង្គនៃកម្មវិធីកែទម្រង់ទាំងបួន និងការឈានទៅការសម្រេចបានន្ទវយុទ្ធសាស្ត្រជាគោលដៅរបស់រាជរដ្ឋាភិបាល គឺអភិបាលកិច្ចល្អ ការធ្វើសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ជាយន្តការមួយជាសារវ៉ន្តកំណត់កត្តាជោគជ័យលើមហិច្ឆតានេះ។ ក្នុងន័យនេះ ការកសាងចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមស្តីពីកម្មវិធីកែទម្រង់ ៣ បូក ១ ជាការកសាងមូលដ្ឋានគ្រឹះក្នុងការសម្រេចនិងដោះស្រាយបញ្ហាប្រឈមនៃការប្រទាក់ក្រឡានៃកម្មវិធីទាំងបួន។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ផែនការកម្មវិធីនិងសកម្មភាព ២០២២ ដល់ ២០៣២

ចក្ខុវិស័យរួម	ពលរដ្ឋមានជំនឿលើគុណភាពនៃសេវាសាធារណៈ និងទំនុកចិត្តលើប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ នៅក្នុងមាគ៌ានៃសុខសន្តិភាព និងការអភិវឌ្ឍ ក្នុងយុគសម័យបច្ចេកវិទ្យា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល
បេសកកម្មរួម	ពង្រឹងប្រសិទ្ធិភាពនៃអភិបាលកិច្ចនិងរដ្ឋបាលសាធារណៈ ក្នុងគោលបំណងបង្កើនគុណភាពនៃសេវាសាធារណៈ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ តាមរយៈការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

ល.រ	យុទ្ធសាស្ត្រ	សកម្មភាពអាទិភាព	ការដ្ឋានទទួលបន្ទុក
លទ្ធផលរំពឹងទុកក្រុមទី ១ «សុខដុមនីយកម្មរចនាសម្ព័ន្ធ គតិយុត្ត និងធនធាន»			
១	ការកែសម្រួលរចនាសម្ព័ន្ធ	រៀបចំគោលការណ៍ណែនាំទូទៅស្តីពីការកែសម្រួលរចនាសម្ព័ន្ធ	ការដ្ឋានអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ
២		ប្រមូលផ្តុំព័ត៌មាន និងទិន្នន័យ អំពីរចនាសម្ព័ន្ធ	ការដ្ឋានអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ
៣		បង្កើតផែនការកែសម្រួលរចនាសម្ព័ន្ធ	ការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ
៤	យន្តការរួមស្តីពីវិធាននិងនីតិវិធីនៃការរៀបចំនិងអនុម័តច្បាប់និងបទប្បញ្ញត្តិ	រៀបចំគោលការណ៍ណែនាំរួមមួយស្តីពីវិធាននិងនីតិវិធីរៀបចំច្បាប់និងបទប្បញ្ញត្តិ	ការដ្ឋានកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
៥	ពង្រឹងនិងសម្រួលយន្តការចែករំលែកព័ត៌មានក្នុងកម្មវិធីកែទម្រង់៣ ឬ១	រៀបចំឱ្យមានកិច្ចប្រជុំចែករំលែកព័ត៌មាននិងពិភាក្សាលើសេចក្តីព្រាងនិងរបាយការណ៍អនុវត្តផែនការថវិកា និងធនធានមនុស្ស ក្នុងការអនុវត្តសកម្មភាពកែទម្រង់	ការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ល.រ	យុទ្ធសាស្ត្រ	សកម្មភាពអាទិភាព	ការដ្ឋានទទួលបន្ទុក
៦	រៀបចំឱ្យមានផែនការកសាងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីជាប្រព័ន្ធ	រៀបចំគោលការណ៍ក្នុងការបង្កើតបញ្ជីរាយនាមគុណវុធិនិងការទទួលខុសត្រូវរបស់មន្ត្រីបង្គោល	ការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ
៧		រៀបចំផែនការជាក់លាក់ក្នុងការធ្វើសមាហរណកម្មទោសវិន័យ	ការដ្ឋានកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
៨		រៀបចំនិងអនុម័តរួមគ្នាលើយុទ្ធសាស្ត្រជាតិស្តីពីការបណ្តុះ-បណ្តាលមន្ត្រី	ការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ
៩	រៀបចំឱ្យមានផែនការសកម្មភាពគាំទ្រការកសាងរដ្ឋាភិបាលឌីជីថល	រៀបចំបង្កើតផែនការឌីជីថលក្នុងកម្មវិធីកែទម្រង់ ៣ ឬ ១	ការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លទ្ធផលរំពឹងទុករួមទី ២ « សុខដុមនីយកម្មលើប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម »			
១០	រៀបចំផែនការសកម្មភាពអនុវត្តការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មឱ្យមានលក្ខណៈបន្ស៊ីគ្នាជាប្រព័ន្ធ	ប្រមូលធាតុចូលពាក់ព័ន្ធនឹងបញ្ហាប្រឈមជាចាំបាច់ទៅលើការឈានទៅដល់ការអនុវត្តការគ្រប់គ្រង ផ្អែកលើសមិទ្ធកម្ម	ការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
១១		បង្កើតក្រុមការងារ ដើម្បីរៀបចំគោលការណ៍នៃការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មជាប្រព័ន្ធ	ការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ
១២		រៀបចំអនុវត្តការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅក្នុងបណ្តាការដ្ឋានកែទម្រង់នីមួយៗ ជាគម្រូ	ការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
១៣		បង្កើតឱ្យមានយន្តការផ្ទេរឬធ្វើវិមជ្ឈការហិរញ្ញវត្ថុ មុខងារ និងអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរូបភាពជារង្វាន់លើកទឹកចិត្ត	ការដ្ឋានអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
១៤		ជ្រើសរើសក្រសួង-ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយជាស្ថាប័នដែលត្រូវអនុវត្តការគ្រប់គ្រង ផ្អែកលើសមិទ្ធកម្ម	ការដ្ឋានអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លក្ខណៈវិនិច្ឆ័យ ១ ក្នុង ៣ ផ្នែកស្រាវជ្រាវ ១ ១ ១

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

លក្ខណៈវិនិច្ឆ័យ ១ ២ ៣ ៤ ៥ ៦ ៧ ២ ១ ២ ១ ២ ១

ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ ឫក ១ ត្រូវបានរៀបចំដោយបានពិភាក្សានិងពិគ្រោះយោបល់ជាច្រើនលើកនិងច្រើនកម្រិត រួមមានកិច្ចប្រជុំនៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ ចំនួន ២ លើក, វិបស្សនានៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ ចំនួន ២ លើក និងសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួងចំនួន ១ លើក ព្រមទាំងកិច្ចប្រជុំផ្ទៃក្នុងនៃលេខាធិការដ្ឋានកែទម្រង់នីមួយៗដោយឡែកពីគ្នាបន្ថែមទៀត។ សមាសភាពចូលរួមដឹកនាំ រៀបចំ ផ្តល់មតិយោបល់ និងសម្របសម្រួលមានដូចតទៅ÷

ក. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

១. ឯកឧត្តម **រស់ សីលវ៉ា**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
២. ឯកឧត្តមបណ្ឌិត **ហ៊ីល ចំរើន**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៣. ឯកឧត្តម **ម៉ែន ធ៊ីរុទ្ធ**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៤. ឯកឧត្តម **យ៉ែត ឌីណែល**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៥. ឯកឧត្តម **ហាស សុខសេនសាន**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៦. ឯកឧត្តម **ប៊ូ ឥន្ទ្រសុខា**	អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៧. ឯកឧត្តម **អ៊ុំ យុទ្ធី**	ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ
៨. ឯកឧត្តម **ណី ឌុ**ច	មន្ត្រីជំនាញជាន់ខ្ពស់
៩. លោក **ឌុ**ន្នី **ស**ត្រា	មន្ត្រីជំនាញ

១០. លោក **ស៊ុន គឹមហេង**	មន្ត្រីជំនាញ
១១. លោក **អ៊ូច សោភ័ណ**	មន្ត្រីជំនាញជាន់ខ្ពស់
១២. លោក **យន ម៉ាលីមរេង**	មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកថវិកា
១៣. លោក **ហ៊ីយ សុវណ្ណារ៉ា**	មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកលទ្ធកម្ម
១៤. លោកស្រី **លឿង សុវណ្ណឌី**	មន្ត្រីជំនាញថវិកា
១៥. លោកស្រី **តិប ឫរ៉ា**	មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
១៦. លោកស្រី **ហ៊ាង ស៊ីនួន**	មន្ត្រីគណនេយ្យករជាន់ខ្ពស់
១៧. លោកស្រី **ហ៊ុន ឈុំវិសច្ឆារ៉ា**	មន្ត្រីគណនេយ្យករ
១៨. លោកស្រី **សុន្ទរ: សូរិយា**	មន្ត្រីរដ្ឋបាលជាន់ខ្ពស់
១៩. លោកស្រី **សេង កញ្ញា**	មន្ត្រីរដ្ឋបាល
២០. លោក **ស៊ុន ឫទ្ធី**	មន្ត្រីព័ត៌មានវិទ្យា
២១. លោកស្រី **អ៊ុង ឥលក្ខទេវី**	ជំនួយការមន្ត្រីត្រួតពិនិត្យនិងវាយតម្លៃគម្រោង
២២. កញ្ញា **អ៊ុន សុវណ្ណគង់គា**	មន្ត្រីជំនួយការផ្នែកលទ្ធកម្ម
២៣. កញ្ញា **កែវ មល្លិកា**	លេខាធិការ។

ខ. លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

១. ឯកឧត្តម **ង៉ាន់ ចំរើន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន
២. ឯកឧត្តម **ចាន់ សុធា**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន
៣. ឯកឧត្តម **ភូច ពលពន្ធក**	ទីប្រឹក្សាក្រសួងមហាផ្ទៃ
៤. ឯកឧត្តម **ចេង ម៉ានី**	ទីប្រឹក្សាក្រសួងមហាផ្ទៃ
៥. លោក **ជ័យ សម្ផត្តិផល្លា**	ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ
៦. លោក **ម៉ុំ ណារ៉ែន**	អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ
៧. លោកស្រី **គង់ ប៊ុណ្ណា**	អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ
៨. លោកស្រី **ហេង សុវ៉ីចា**	អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ
៩. លោក **ប៊ុន ម៉ានិត**	ប្រធានការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ
១០. លោក **ង៉ាច់ សាវ៉ី**	ទីប្រឹក្សាហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

គ. លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

១. ឯកឧត្តម **ហួត ស៊ីនាដ**	រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

២. ឯកឧត្តម **ឈុន សុជាតិ**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងជាអនុប្រធានទី១ នៃ លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ រដ្ឋបាលសាធារណៈ
៣. ឯកឧត្តម **សយ រាសី**	អគ្គនាយករង និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
៤. លោក **យ៉ន សារ៉ែត**	អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ
៥. លោក **ចន់ ម៉ារ**	អគ្គនាយករង
៦. លោក **ង្ហាក់ ង្ហានីដ្ឋា**	ប្រធាននាយកដ្ឋាន
៧. លោក **សុខ សំណាង**	ប្រធាននាយកដ្ឋាន
៨. លោក **សៀត ទិចិត្រ**	ប្រធានាយកដ្ឋាន
៩. លោក **លន គឹមហេង**	ប្រធាននាយកដ្ឋាន
១០. លោក **សុខ សុវ៉ាត**	អនុប្រធាននាយកដ្ឋាន
១១. លោក **ម៉ុច សៀកឡេង**	អនុប្រធាននាយកដ្ឋាន
១២. កញ្ញា **អ៊ុត ផល្លីស**	អនុប្រធាននាយកដ្ឋាន

ឃ. លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

១. ឯកឧត្តម **ជិន ម៉ាលីន**	រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃ គ.ច.ប្រ
២. ឯកឧត្តម **ខាន់ ឥណ្ណៈ**	រដ្ឋលេខាធិការ និងជាអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃ គ.ច.ប្រ
៣. ឯកឧត្តម **ឃ្លោក ជារ៉ា**	អគ្គនាយករង និងជាអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃ គ.ច.ប្រ
៤. លោក **ង៉ូ សាឡុង**	ប្រធាននាយកដ្ឋាន
៥. លោក **ញ៉ឹម សុធា**	អនុប្រធាននាយកដ្ឋាន
៦. លោក **យ៉ឹម គុងខួង**	អនុប្រធាននាយកដ្ឋាន
៧. កញ្ញា **ហេង ស៊ីណែត**	អនុប្រធាននាយកដ្ឋាន
៨. លោក **ហួន ចំន្ទឌី**	ប្រធានការិយាល័យ និងជាមន្ត្រីជំនាញ។

ង. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. ឯកឧត្តម **ស៊ាង ផល្លា**	អនុរដ្ឋលេខាធិការនិងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
២. ឯកឧត្តម **ស៊ីសុវត្ថិ ជ្ជិងចំន្ទនោ**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា
៣. ឯកឧត្តមបណ្ឌិត **ឌី សុវណ្ណា**	អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
៤. ឯកឧត្តមបណ្ឌិត **ក៏ម កែវមុនីរ៉ូ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា

៥. ឯកឧត្តម **សៀក សុតំគ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
៦. ឯកឧត្តម **រស់ សុខណារុណា**	អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
៧. ឯកឧត្តម **ណាន សាមឌី**	អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
៨. ឯកឧត្តម **ជ្យៀប ពិសិដ្ឋ**	ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
៩. ឯកឧត្តម **សុខ ចំន្ទកិត្យា**	ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១០. ឯកឧត្តម **ហ៊ីល ម៊ុនថាន**	ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១១. លោក **ហ្ស៊ីត ឆ្ងីងហ្ស**	ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១២. លោក **ឈិត សុចន្ធា**	អនុប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១៣. លោក **ជ៉ុ សុក្រសេរី**	អនុប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១៤. លោក **អ៊ុក ម៉ិថុនា**	មន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១៥. លោក **យ៉ឹម សុបញ្ញា**	មន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
១៦. លោក **ស៊ុន ចំន្ទកក្ខដា**	ប្រធានអធិការកិច្ចរតនាគារនៃអគ្គនាយកដ្ឋានរតនាគារជាតិ
១៧. លោក **លឹម ចំន្ទពិសិដ្ឋ**	ប្រធានការិយាល័យផែនការនិងស្ថិតិនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
១៨. លោក **អេ សៀម**	មន្ត្រីនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ច. ក្រសួងមហាផ្ទៃ

១. លោក **ស៊ុន ឈុនហ្ស៊ីង**	អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត
២. លោក **ង៉ែន សំណាង**	ប្រធានការិយាល័យអភិវឌ្ឍន៍រាជធានី ខណ្ឌ និងខេត្ត

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

យន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ នៃរាជរដ្ឋាភិបាល

ចក្ខុវិស័យ

សុខដុមនីយកម្មការកែទម្រង់ ៣ ឫក ១

បេសកកម្ម

ធានាសង្គតិភាពនិងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឫក ១

អតិក្រម

ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីស័ក្តិសិទ្ធភាពនិងសុខដុមនីយកម្មនៃការកែទម្រង់ទាំង៤

យុទ្ធសាស្ត្រ

១. សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ ៣ ឫក ១

២. សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

៣. សុខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់ ៣ ឫក ១

ISBN-13: 978-9924-554-15-8

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

យន្តការសម្របសម្រួលការកែទម្រង់ ៣ ឫក ១ នៃរាជរដ្ឋាភិបាល

ចក្ខុវិស័យ

សុខដុមនីយកម្មការកែទម្រង់ ៣ ឫក ១

បេសកកម្ម

ធានាសង្គតិភាពនិងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ឫក ១

អភិក្រម

ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីស័ក្តិសិទ្ធភាពនិងសុខដុមនីយកម្មនៃការកែទម្រង់ទាំង៤

យុទ្ធសាស្ត្រ

១. សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ ៣ ឫក ១

២. សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

៣. សុខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់ ៣ ឫក ១

ឯកសារមន្ទីរសាធារណៈ | https://t.me/oa_channel

ISBN-13: 978-9924-554-15-8
9 789924 554158